




www.facebook.com/7khmer
ផ្តល់ជូននូវចំណេះដឹងគ្រប់វិនាទី

www.facebook.com/7khmer

វាយបញ្ចូលដោយខ្ញុំព្រះករុណាខ្ញុំបាទ ថៃ ប៊ុនឆាយ ជាធម្មទាន

# សុជីវធម៌

សំរាប់ **បុរស និស្ត្រី**

និពន្ធ និងស្រាវជ្រាវដោយ **កញ្ញា សាន់ នាង**
ធ្វើការនៅក្រសួងឃោសនាការជាតិ ការិយាល័យប្រែភាសា
**ក្រុមវិទ្យុជាតិ**

**បោះពុម្ពលើកទី១**

**ការផ្សាយរបស់**

## បណ្ណាគារ
## ពេជ្រនិល

ព.ស. ១៩៦៧ **រក្សាសិទ្ធិ** ព.ស.២៥១០



Facebook : Entertainment  And Knowledge

www.facebook.com/7khmer



# អារម្ភកថា

ដោយយល់ជាក់ច្បាស់ ឧត្តមគតិដែលប្រកាន់យកនូវសេចក្ដីថ្លៃថ្នូររបៀបរៀបរយ ការស្ទង់ចិត្តអោយយល់អធ្យាស្រ័យគ្នាទៅវិញទៅមកជាប្រភពនៃសេចក្ដីសាមគ្គី ជាសភាវសម្រាប់ទាញអន្ទងប្រមូលយកនូវឫសគល់ដួងចិត្តបងប្អូនរួមជាតិ ទៅទុកក្នុងស្ថានសប្បាយរីករាយក្នុងគ្រួសារ និងសង្គមជាតិទាំងខ្ញុំក៏ខំប្រមូលអត្ថបទតូចតាច ដែលប្រសូតចេញពីឧត្តមគតិ ធ្លាប់ជួបប្រទះតាមកន្លែងផ្សេងៗ ក្នុងសៀវភៅដឹកនាំខ្លះ ដើម្បីរៀបរៀងសៀវភៅនេះទុកជាកេរ្ដិ៍ដំណែលនៃស្នាមគំនូសជីវិតរបស់នារីម្នាក់ ដែលស្រឡាញ់សេចក្ដីថ្លៃថ្នូរការអប់រំសេចក្ដីស្មោះត្រង់ និងសភាពសុខសាន្តមនោរម្យ។

ជាការពិតណាស់ ទ្រព្យសម្បត្តិហូរហៀរ រូបសម្បត្តិល្អឥតខ្ចោះ តែខ្វះការអប់រំខាងផ្លូវចិត្តដោយខ្លួនឯង ខ្វះសុជីវធម៌ក្នុងជីវិតនោះឯងគ្មានក្លិនក្រអូបនៅក្នុងសង្គមទេ។

មិត្ត មិត្តនារី អ្នកអានជាទីមេត្រីទាំងឡាយ សៀវភៅ "សុជីវិតធម៌សំរាប់បុរសនិងស្ត្រី" ដែលជាស្នាដៃទី២របស់នាងខ្ញុំក្នុងការនិពន្ធសៀវភៅ ផ្នែកជួយអប់រំខាងចិត្តសាស្ត្រនេះ ជាកម្មវត្ថុនៃសេចក្ដីរិះគន់ និងសេចក្ដីរាប់អានរបស់មិត្ត មិត្តនារីហើយ។ នាងខ្ញុំអ្នកនិពន្ធសូមប្រសិទ្ធិពរសូមអោយយុវជនជាតិយើងបានប្រកបដោយរបៀបរៀបរយ មានសណ្ដាប់ធ្នាប់តាមលក្ខណៈជាតិនិយមថ្លៃថ្នូរ ហើយសូមអោយសភាវៈបរទេសនិយមព្រៃផ្សៃរៀសចៀសចេញឆ្ងាយពីដែនកម្ពុជរដ្ឋ។

ភ្នំពេញ ថ្ងៃអាទិត្យ ទី២២ មីនា ឆ្នាំ ១៩៦៧

ហត្ថលេខា **កញ្ញា សាន់ នាង**



Facebook : Entertainment And Knowledge

www.facebook.com/7khmer



# សុជីវធម៌នៅតាមវត្តអារាម

វត្តអារាមជាកន្លែងសក្ការៈបូជា ជាទីគោរព យើងមិនត្រូវសំដែងកិរិយាមិនគប្បីសោះឡើយ អ្នកជិះកង់ ម៉ូតូ ទោចក្រយានយន្តគ្រប់ធុន ត្រូវឈប់ ដឹក បណ្តើរ ចូលទៅក្នុងវត្តដោយគោរពព្រោះមិនឆាប់ លឿន រឺយូរជាងគ្នាប៉ុន្មានឡើយចំងាយប៉ុណ្ណឹង។ អ្នកពាក់មួកទទូក្រមា កន្សែង ត្រូវដោះចេញពីក្បាលនៅពេលដើរចូលក្នុងវត្ត។ មិនត្រូវនាំគ្នាជជែកឡូឡាក្នុងទីអារាមឡើយ។

នារីជាឧបាសិកា ត្រូវសង្រួមឫកពាអោយនឹងធឹង មុននឹងចូលទៅកាន់ទីអារាមកុំធ្វើភ្នែកក្រឡិបក្រឡាប់ កុំរពឹសភ្នែក កុំងាកឆ្វេងស្តាំរាប់រយផងពេក កុំញញឹមញញែមខិបកខុបពេកគួរមើលចាស់ទុំផង។ កុំពោលពាក្យអាវាសែនៅទីអារាម។ កុំស្លៀកខោជើងកំប៉ុងនៅពាក់កណ្តាលស្មង កុំស្លៀកសំពត់តឹងរបៀបខ្លី (robe sarree) ចូលទៅបត់ជើងថ្វាយបង្គំព្រះពុទ្ធបដិមារ រឺព្រះសង្ឃ។ ត្រូវពាក់អាវកតូច ហើយចង់ពានាក្រមាទៀតផងទើបពេញលក្ខណៈជាអ្នកចូលវត្ត។ កុំនិយាយចំអែចំអន់ព្រះសង្ឃដោយប្រការមិនគប្បី។ កុំពាក់គ្រឿងសំរើប។

បុរសជាឧបាសក ត្រូវប្រើពាក្យសំដីអោយសមរម្យ គោរពព្រះសង្ឃដែលស្មោះត្រង់ព្រះពុទ្ធសាសនា។ ពេលថ្វាយបង្គំព្រះពុទ្ធបដិមាករ រឺថ្វាយបង្គំព្រះសង្ឃ ត្រូវងាកទៅព្រះពុទ្ធបដិមាករ រឺព្រះសង្ឃ កុំថ្វាយបង្គំតិតតូង ហើយក្បាលកុំងាកមកចរចារជាមួយអ្នកឯណាមួយទៀតអោយសោះ ព្រោះការធ្វើដូច្នេះនាំអោយសៅហ្មងដល់អ្នកដែលគេគោរពបូជាចំពោះព្រះពុទ្ធសាសនា។ កុំឈោងដៃរឺតោងសណ្តោងយកអ្វីរំលងលើព្រះពុទ្ធបដិមាករ។ អ្នកដែលចូលទៅកាន់ទីវត្តអារាម មិនត្រូវលួចយករបស់អ្វីជាទ្រព្យដែលពុទ្ធសាសនិកជនបានខំរៃគ្នាទុកសំរាប់វត្តមកធ្វើជាទ្រព្យរបស់ខ្លួនទេ។

អ្នកមិនមែនជាពុទ្ធសាសនិកជន មិនត្រូវប្រមាថមើលងាយវត្តពុទ្ធបូជា រឺព្រះសង្ឃដែលស្មោះត្រង់ដោយប្រការណាមួយតេ។ អ្នកដែលប្រព្រឹត្តខុសនឹងបញ្ញត្តិព្រះពុទ្ធ មិនមែនមានឈ្មោះថាអ្នកគាំទ្រព្រះពុទ្ធសាសនាទេ ក្នុងករណីដែលបន្លំរបៀបណាមួយ ស្រេចនៅលើសំពាយបុណ្យបាបរបស់គេទៅចុះ។

យើងជាពុទ្ធសាសនិកជន ក៏មិនគប្បីត្មះតិះដៀលដល់សាសនាណាមួយ ដោយរំលោភលើព្រះវិហារនៃសាសនាផ្សេងៗនោះទេព្រោះគេមានសិទ្ធិគ្រប់គ្រាន់ខាងជំនឿ។

❁ ❁ ❁ ❁



Facebook : Entertainment And Knowledge

www.facebook.com/7khmer



# ជីវិត និងសេចក្តីស្នេហា

សុជីវធម៌សំខាន់បំផុតសំរាប់មនុស្សទូទៅគឺ សុជីវធម៌សំរាប់ប្រើប្រាស់សេចក្តីស្នេហានៃឃ្លាំងជីវិត។

ឋានៈនៃសុជីវធម៌ នឹងកើតមានឡើងតាមកំរិតនៃសេចក្តីស្នេហា។ មនុស្សដែលគ្មានសេចក្តីស្នេហាចំពោះមនុស្សទូទៅដែលរស់ដកដង្ហើមនៅក្រោមមេឃដូចគ្នា មនុស្សនោះឯងជាអ្នកកំណាញ់ស្វិតចំពោះយោបល់នៃសុជីវធម៌ រឺជាមួយអ្នកសុជីវធមតដោយពិតប្រាកដ។

អ្នកដែលចង់រស់នៅតែម្នាក់ឯង មិនរវល់ជាមួយមនុស្សនៅជុំវិញខ្លួន អ្នកនោះឯងមិនមែនមានឈ្មោះថា ជាមនុស្សនៅក្នុងសង្គមជាតិទេ តែជាសត្វមួយរូបដែលរស់គ្មានទីរំពឹងអ្វីទាំងអស់។ មុននឹងយើងគិតសល់សុជីវធម៌ចំពោះជនទូទៅ យើងគួរគិតសុជីវធម៌ចំពោះខ្លួនឯងជាមុនសិន។ មុននឹងយើងគិតអ្នកដែលនៅចំងាយមួយគីឡូម៉ែតពីយើង យើងគួរគិតពីយើង យើងគួរគិតពីអ្នកដែលនៅក្បែរយើង ជាប់នឹងទ្រូងយើងជាមុនសិន។ បើអ្នកជាមនុស្សដែលមានមនសិការសីលធម៌គ្រប់គ្រាន់ តើអ្នកមានលៃលកចែករំលែកសុជិវធម៌ជាមួយសង្សារ-ប្តី-ប្រពន្ធ-កូនរបស់អ្នកបានគ្រប់គ្រាន់ហើយរឺនៅ។ សុឆន្ទៈដែលអ្នកសំដែងចំពោះសាធារណៈជនគ្រប់រូបបាន តែផ្ទុយមកវិញអ្នកជាមនុស្សឆ្មើងកន្ទ្រើងរឹងរូស មាត់អាក្រក់ រឺមើលងាយមើលថោកចំពោះសង្សារ ប្រពន្ធ ប្តី កូនរបស់អ្នក តើអ្នកមានឈ្មោះថាជាជនថ្លៃថ្នូរហើយរឺ?។ មួយចំណែកទៀតមនុស្សដែលគ្មានប្តី ឬគ្មានប្រពន្ធប្រាកដប្រជា ជាអ្នកកសាងសុភមង្គលរបៀបណាខ្លះនៅក្នុងជីវិត។ តើការប្រទេចផ្តាសារពីអ្នកដែលខ្លួនយកមកធ្វើជាល្បែងនោះ ជាសុភមង្គលរបស់ខ្លួនរឺ?

តើសុភមង្គល សេចក្តីថ្លៃថ្នូរនៅត្រង់ណាបើគេឃើញតែការប្រេះឆា ឈ្លោះប្រកែកវាយដំប្រចាក់ បោកប្រាស តាមផ្ទះសំបែងបោកចានឆ្នាំង ព្រោះភ្លើងព្រោះសាំងដាក់គ្នា រវាងប្តីនិងប្រពន្ធដូច្នេះ។ អ្នកដែលមានសុជីវធម៌ ចេះរស់នៅដោយសុខសាន្ត មិនចេះប្រច័ណ្ឌឈ្នានីសចចើងចង់ឈ្នះ រឺចង់ធ្វើធំយកប្រៀបជាងគ្នានឹងគ្នានៅក្នុងឋានៈជាប្តីប្រពន្ធទេ។

ដើម្បីសេចក្តីសុខសាន្ត យើងត្រូវគិតថាប្រពន្ធ រឺប្តីជាភ្ញៀវថ្មីម្នាក់ដែលយើងត្រូវគោរពរាល់ពេលវេលា។ គឺសេចក្តីស្មោះត្រង់ចំពោះសេចក្តីស្នេហា រវាងប្តីប្រពន្ធនោះហើយដែលជាប្រភពដើមរបស់សុភមង្គល ហើយជាកាយវិការដែលប្រកបដោយសុជីវធម៌គ្រប់គ្រាន់ក្នុងគ្រួសារ ។



Facebook : Entertainment  And Knowledge

www.facebook.com/7khmer



# ដំណើរជីវិត

ផ្ទាំងជីវិតគឺជាជញ្ជាំងផ្ទះមួយដែលគ្មានដំបូល ហើយគ្មានកំពស់ពិតប្រាកដផង។ មនុស្សម្នាក់ៗប្រៀបបាននឹងជាងសង់ផ្ទះដែលរៀបជញ្ជាំងក្នុងមួយថ្ងៃរៀបឥដ្ឋមួយដុំ។ ជីវិតចេះតែធ្វើដំណើរទៅមុខ រីឯជញ្ជាំងផ្ទះក៏ចេះតែខ្ពស់ឡើងទៅលើដែរ។ នៅពេលដែលគេឡើងទៅដល់ខ្ពស់ ទើបមនសិកាសីលធម៌ និងការចេះដឹងរបស់គេបើកទស្សនវិស័យទៅរកទុទិដ្ឋិនិយម រឺសុទិដ្ឋិនិយមតាមទស្សនៈរៀបៗខ្លួន។ កាលបើគេត្រេចចរតាមស្នាមដានជីវិតដល់កំផែងខ្ពស់ហើយគេមិនត្រូវសំងំក្រាបក្បាលសុខសាន្តម្នាក់ឯង ធ្វើគធ្វើថ្លង់បិទប្រស្រីភ្នែកមិនសំលឹងមកមើលអ្វីៗខាងក្រោមនោះទេ។ ការពិសោធន៍ដ៏យូរអង្វែងតាមស្នាមជីបជុលប៉ះព័ទ្ធលើគន្លងផ្ទាំងជីវិត បានធ្វើអោយមនុស្សមានស្មារតី រឹងប៉ឹងមុះមុត តស៊ូ និងក្លាហាន។ ឡើងដល់ទីខ្ពស់នោះ គេនឹងងាកមកក្រោមឃើញឈូងសមុទ្រកម្មពៀរកោះសប្បាយ ភ្នំភ្លើងនៃការជំលោះចាក់ដោត ទីវាលវិយោគសង្រេង កំពោតព្រៃសុទ្ធសាត ព្រៃល្បាតបន្លាម្ជូរហ្មង ត្រពាំងទឹកភ្នែក ថ្លុកស្តាយក្រោយ ព្រែកបុណ្យ ស្ទឹងបាប ខ្ពង់រាបរមណីយ និងដែលដីសណ្តរនៃទន្លេស្នេហា។ កាលបើឡើងអោយខ្ពស់ៗទៅទៀតគេនឹងចោលនេត្រាបានឆ្ងាយជាងនេះ ហើយគេនឹងឃើញភ្នំធំៗឯនាយឆ្ងាយសន្លឹមមានជួរវែងៗជាប់គ្នា ដែលនៅពីក្រោយភ្នំនោះគេនឹងឃើញមានអាថ៌កំបាំងគួរអោយព្រឺក្បាលមិនខាន។ តើយើងធ្វើដូចម្តេចទើបមើលឃើញអាថ៌កំបាំងនៅខាងក្រោមភ្នំទាំងនោះ។ តើនរណាអាចឆ្លើយត្រូវថា អាថ៌កំបាំងនោះមានអ្វីខ្លះ? តើជួរភ្នំព្រឹប្រទល់ដែនភ្នែកនោះមានឈ្មោះថាអ្វីទៅវិញ? កាលបើគ្មាននរណាដឹងរឺក៏ការដឹងនោះមិនសូវមានតំលៃសំរាប់យើង នាទីសុជីវធម៌របស់យើងតម្រូវអោយយើងរង់ចាំ ជញ្ជាំងរបស់យើងផ្ទាល់សង់ដល់កំពស់ដែលអាចមើលឃើញ ហើយថាត្រូវពិតប្រាកដនោះចុះ។

ត្រដោកកម្មដែលព្យួរជាប់នៅនឹងមនុស្សគ្រប់រូប ជួនក៏ជំរុញអោយសង់ជញ្ជាំងបានខ្ពស់ ជួនក៏សង់បានទាប ហើយទីបំផុតក្រោលផ្នុកជីវិត ដែលយើងមិនដឹងនៅទីណា បានចុចកណ្តឹងរោទិ៍ហៅអោយជីវិតវិលទៅទីនោះវិញ ដោយទុកអោយរូបកាយទៅជាចំណីនៃអគ្គីរឺសត្វធាតុនានា។ អ្វីទៅជីវិតនេះ ? ។



Facebook : Entertainment And Knowledge

www.facebook.com/7khmer


# ទស្សនកិច្ចផ្សេងៗ

យើងជាភ្ញៀវសមរម្យដែលចង់ទៅលេងផ្ទះគេ ត្រូវប្រាប់ដំណឹង រឺជូនប័ណ្ណបញ្ជាក់សេចក្តីទៅម្ចាស់ផ្ទះជាមុន។ ភ្ញៀវអ្នកមានរបប មិនទៅលេងផ្ទះគេដោយមិនបានប្រាប់គេមុននោះឡើយ។

នៅក្នុងប័ណ្ណដែលជំរាបថាសុំមកលេងផ្ទះគេ យើងជាភ្ញៀវត្រូវសរសេរថ្ងៃ ខែ ឆ្នាំ ម៉ោង និងចំនួនមនុស្សដែលសុំមកលេងនោះអោយបានប្រាកដប្រជា។ បើយើងទៅលេងផ្ទះគេយើងមិនត្រូវធ្វើគំនិតមារយាទដូចយើងធ្លាប់ពោលថា "ផ្ទះអ្នក ផ្ទះលោកក៏ដូចផ្ទះខ្ញុំ" នោះទេ ។ កុំធ្វើអោយអ្នកផ្ទះមានការធុញទ្រាន់ រឺអៀនអន់ព្រោះតែទស្សនកិច្ចរបស់យើងអោយសោះ។

បើយើងទៅសួរសុខទុក្ខគេ នៅពេលដែលគេមានទុក្ខដូចជាមានបុគ្គលមរណៈលើផ្ទះ យើងមិនត្រូវញញឹមញញែមបញ្ចេញសម្ផស្ស ពាក់គ្រឿងអលង្ការ ជាម្ចង ហូលព្រែ ល្បើក ខ្សែសយនោះឡើយ យើងត្រូវរៀបចំជាអ្នកជួយរំលែកទុក្ខពីអ្នកផ្ទះ យើងគួរចេះលួងលោមក្មេងក្មាងដែលយំសោកមិនឈប់ដោយពាក្យប្រៀនប្រដៅផ្សេងៗ អោយគ្នាបានស្រាកស្រាន បាត់ទុក្ខសោកនេះ។ យើងត្រូវជួយឈឺឆ្អាលដល់ជនរងគ្រោះ។

បើយើងទៅលេងផ្ទះដូចតាចាស់ៗ ហើយយើងចង់ទិញនំនែកអ្វីផ្ញើ យើងមិនត្រូវរើសចំណីណាដែលរឹងហួសប្រមាណនៅពេលដែលគាត់បាក់ធ្មេញអស់នោះទេ គឺមិនត្រូវទិញអំពៅគ្រលីងឈូក ។ល។ ជាដើមឡើយ ។

បើយើងទៅសាកសួរអ្នកជំងឺនៅមន្ទីរពេទ្យ រឺនៅផ្ទះយើងមិនត្រូវលីមាត់ឡូឡាសាកសួរពីនាយមកទេ ជាពិសេសយើងមិនត្រូវទៅរុកគួន ដេញដោលអ្នកជំងឺល្អិតល្អៃនោះច្រើនទេ បើចង់ដឹងការអ្វី ត្រូវសាកសួរគ្រូពេទ្យ-គិលានុបដ្ឋាយិកា រឺអ្នកថែអ្នកជំងឺ។

បើមានការអ្វីចង់ជួបជាបន្ទាន់ជាមួយម្ចាស់ផ្ទះ យើងត្រូវសុំអភ័យទោសពីគេជាមុន បើម្ចាស់ផ្ទះមិនទាន់ចេញមកទទួលទេយើងជាភ្ញៀវត្រូវឈរចាំទទួលម្ចាស់ផ្ទះ មិនត្រូវដើរទៅអង្គុយនៅកន្លែងគួរសមសំរាប់ខ្លួនទេ បើម្ចាស់ផ្ទះអោយមនុស្សមកប្រាប់ថាអោយចាំមួយភ្លែត យើងជាភ្ញៀវមិនត្រូវដើរទៅផ្សារសិន រឺទៅទីណាសិនទេ យើងត្រូវអង្គុយកន្លែងសមគួរ។

ពេលគេអោយយើងអង្គុយចាំ យើងមិនត្រូវដើរទៅឈ្ងោកមើលរបស់របរក្នុងទូកញ្ចក់របស់គេ រឺរូបថតនៅក្នុងបន្ទប់ទទួលភ្ញៀវរបស់គេទេ យើងត្រូវអង្គុយចាំដោយរម្យទម ទោះបីផ្ទះដែលយើងទៅលេនោះ នៅស្រុកស្រែចំការក៏ដោយ ក៏យើងមិនត្រូវដើរទៅខ្វេះខ្វាចរបស់របរដូចជា បេះផ្លែត្របែក ពុទ្រា កន្ទួតរបស់ម្ចាស់ផ្ទះដែរ។ ម្យ៉ាងទៀតភ្ញៀវដែលមានរបបគេ


Facebook : Entertainment And Knowledge

www.facebook.com/7khmer


មិនជុះនោមប្រាសដើមផ្កាឬដើមឈើណានៅខាងមុខផ្ទះគេទេ យើងត្រូវមានការអៀនខ្មាស ចំពោះភ្នែកអ្នកផង ដែលសំឡឹងមកចំ។ តើម្ចាស់ផ្ទះត្រូវទទួលភ្ញៀវរបៀបណាខ្លះ?

ម្ចាស់ផ្ទះមិនត្រូវដំអក់ដកកចេញពីគ្រែស្រែកសួរថា នរណារកអ្វី? "មានការអី?" "គ្មាននរណានៅទេ" នោះឡើយ។

បើភ្ញៀវដែលមិនបានអោយដំណឹងជាមុននោះ បានជាមកផ្ទះរបស់យើងទៅហើយ យើងត្រូវមានសុជីវធម៌ក្នុងឋានៈជាម្ចាស់ផ្ទះ ហើយត្រូវគិតថាភ្ញៀវរបស់ប្តី របស់កូន របស់កូនប្រសារ ថាភ្ញៀវរបស់ខ្លួនផ្ទាល់។

នៅពេលភ្ញៀវអញ្ជើញមកដល់ នៅពេលសំពះសួរតតបជាមួយភ្ញៀវរួចហើយ យើងជាម្ចាស់ផ្ទះគួរអញ្ជើញភ្ញៀវអោយពិសាបារីដែលយើងជាម្ចាស់ផ្ទះ បានរៀបទុកលើតុទទួលភ្ញៀវរួចជាស្រេចហើយ។ ជាការគួរ យើងគួររកទិញបារីគ្រប់សញ្ញាសំរាប់ទុកទទួលភ្ញៀវ។ យើងមិនត្រូវដាក់បារី ដោយមិនដាក់ឈើគូស រឺដែកកេះជិតនោះផងទេ។ រីឯប្រដាប់សំរាប់ដាក់កំញ៉មបារី ក៏យើងមិនត្រូវភ្លេចដែរ។ បារី និងសំរាប់ទទួលភ្ញៀវអាចដាក់បានគ្រប់ពេល លើកលែងតែភ្ញៀវបដិសេធ។

នៅវេលាថ្ងៃត្រង់ រឺថ្ងៃរសៀលបន្តិច គេអាចទទួលភ្ញៀវដោយទឹកក្រូច ទឹកលីម៉ូណាត់ ស៊ីរ៉ូទឹកកក ទឹកតែ កាហ្វេ ភេសជ្ជៈ ផ្សេងៗ នំធ្វើអំពីម្សៅ រឺនំប្រអប់ផ្សេងៗក៏បាន។ ចាប់តាំងពីម៉ោង១៨ល្ងាចទៅ គេអាចទទួលភេសជ្ជៈខ្លះ ដូចជាកាហ្វេ ទឹកតែជាដើម។

❀ ❀ ❀ ❀


Facebook : Entertainment And Knowledge

www.facebook.com/7khmer



# របៀបទទួលភ្ញៀវ

យុវភរិយាទាំងឡាយ តែងបានទទួលការចេះដឹងខ្លះៗហើយពីរបៀបទទួលភ្ញៀវនៅប្រទេសយើង ដើម្បីធ្វើអោយភ្ញៀវរបស់អ្នកនាងមានភាពសប្បាយរីករាយ ហើយសរសើរអំពីអ្នកនាង អ្នកនាងគួរប្រកាន់ឥរិយាបថជាអ្នកថ្លៃថ្នូរ គ្រប់ពេលវេលាទាំងអស់។

**ការទទួលភ្ញៀវនៅផ្ទះ**

កាលបើអ្នកនាង និងស្វាមីអ្នកនាងស្រុះស្រួលចិត្តគ្នាអញ្ជើញភ្ញៀវ អោយមកពិសារភោជនាហារកំសាន្តនៅក្នុងផ្ទះអ្នកនាង អ្នកនាងជាម្ចាស់ផ្ទះដ៏ចំណាន ត្រូវមានកូនសៀវភៅតូចសំរាប់កត់សេចក្តីផ្សេងៗ ព្រោះភាពរវល់របស់អ្នកនាងអាចបណ្តាលអោយអ្នកនាងភ្លេចចំណងដែលគិតពីមុនថានឹងរៀបធ្វើអ្វីខ្លះ ។ នៅក្នុងកូនសៀវភៅនោះ អ្នកនាងត្រូវកត់ឈ្មោះភ្ញៀវដែលអ្នកនាងបានអញ្ជើញអោយមករួបរួម គឺមានប៉ុន្មាននាក់ កូនក្មេងប៉ុន្មាន ដើម្បីស្រួលគិតស្មានដល់ការធ្វើម្ហូបទុកបំរុង។ បុរសជាស្វាមីគួរជួយភារៈកិច្ចរបស់ភរិយាខ្លះៗផងក្នុងរឿងនេះ គឺត្រូវជួយពិគ្រោះជាមួយភរិយាលោកពីម្ហូបអាហារណាដែលលោកចូលចិត្ត។ តាមធម្មតាការលៀងភោជនាហារនៅតាមផ្ទះមួយកាលមួយគ្រានេះគេតែង អញ្ជើញភ្ញៀវអោយមកពិសារនៅវេលាល្ងាចគឺចាប់តាំងពីម៉ោង ៦ ទៅទល់នឹងម៉ោង ៨។ លុះជិតដល់ម៉ោងហើយ លោក និងលោកស្រីជាម្ចាស់ផ្ទះ គួរប្រុងខ្លួនចាំទទួលភ្ញៀវទាំងពីររូប។ បានសេចក្តីថា កាលបើភរិយាលោកស្លៀកពាក់យ៉ាងស្អាតបានត្រឹមត្រូវចាំទទួលភ្ញៀវ លោកមិនត្រូវទៅស្លៀកសារុងគគ្រុក សម្រាន្ត រឺធ្វើការអ្វីៗជាប់ដៃខ្លាំងទៀតឡើយព្រោះលោកបានសំរេចចិត្តរួចមកហើយថា លោកចំនាយពេលវេលាល្ងាចនេះដើម្បីទទួលភ្ញៀវ។ ពេលភ្ញៀវអញ្ជើញមកដល់ អ្នកនាងនិងលោកជាម្ចាស់ផ្ទះត្រូវក្រោកឡើងទទួលភ្ញៀវ ហើយជូនទៅរកកន្លែងសមគួរសិន មិនគប្បីបក់ដៃហៅភ្ញៀវអោយចូលមក ហើយយកនែចង្អុលអោយភ្ញៀវទៅរកកន្លែងអង្គុយនោះទេ។ អ្នកនាងគួររកកន្លែងមួយល្អប្រពៃមានបរិយាកាសស្អាតស្អំរៀបចំដោយស្នាដៃដ៏វិចិត្ររបស់អ្នកនាង ដើម្បីអោយភ្ញៀវអង្គុយលេងមួយស្របក់សិនក៏បាន រឺក៏អញ្ជើញទៅរកកន្លែងពិសារភោជនាហារតែម្តងក៏បាន។ អ្នកនាងជាម្ចាស់ផ្ទះ រឺលោកជាម្ចាស់ផ្ទះ មិនគប្បីហៅភ្ញៀវអោយយកចិត្តទុកដាក់មើលរបស់ចំឡែក រឺថ្លៃថ្នូររបស់អ្នកនាងឡើយ ហើយមិនគួរនិយាយថា "ផ្ទះខ្ញុំស្អាតណាស់ ល្អណាស់ ទូលាយណាស់រឺវត្ថុនេះទើបនឹងទិញមកពីបរទេស" ទេ អ្នកនាងគួរទុកអោយភ្ញៀវគេសម្លឹងឃើញខ្លួនគេចុះ បើគេឃើញ ហើយសារសួរដោយសរសើរអ្នកនាង អ្នកនាងមិនត្រូវបញ្ចេញឫកពារសប្បាយជ្រុល ព្រោះការ



Facebook : Entertainment And Knowledge

សរសើរនេះ រឺបញ្ចេញពាក្យថា "ខ្ញុំសប្បាយណាស់ ព្រោះខ្ញុំខំតុបតែង រឺខំសំអាត ។ល។" នោះទេ ។ អ្នកនាងគួរបញ្ចេញឥរិយាបថអោយភ្ញៀវឃើញថា អ្នកនាងសប្បាយចិត្តចំពោះភ្ញៀវមិនមែនសប្បាយចិត្តដោយអង្គុយលើចង្អេរលើកខ្លួនឯងនោះទេ។ តាមពិតតម្លៃទាំងអស់នេះ ភ្ញៀវរបស់អ្នកនាងបានយល់តាមឥរិយាបថរបស់អ្នកនាងដោយពិតប្រាកដ។ អ្នកនាងអញ្ជើញគេមកសប្បាយ សំរាប់បង្ហាញស្នាដៃរៀបចំរបស់អ្នកនាងក៏ពិតមែនហើយតែអ្នកនាងមិនមែនអញ្ជើញភ្ញៀវមកសំរាប់លើកតំកើងអ្នកនាង និងស្វាមីអ្នកនាង ហើយហាក់ខ្ញើមរអើម រឺមើលងាយភ្ញៀវដែលមានឋានៈទាបជាងអ្នកនាងនោះទេ។ អ្នកទាប អ្នកក្រដែលបានឃើញឥរិយាបថដ៏ប្រសើរគួរសមឥតខ្ចោះ របស់អ្នកនាង និងស្វាមីអ្នកនាងអ្នកនោះសរសើរពីអ្នកនាងជាងទ្រព្យសម្បត្តិដែលគេមិនដែលឃើញនោះទៅទៀត។

ការរៀបម្ហូបអាហារសំរាប់ភ្ញៀវ អ្នកនាងគួររៀបកុំអោយខ្វះ ហើយជាពិសេសទោះបីអ្នកនាងឃ្លានបាយក្តាំងយ៉ាងណាក៏ដោយក៏អ្នកនាងខំប្រឹងអត់ធ្មត់ទៅចុះកុំយក បាយក្តាំងមកអោយភ្ញៀវឃើញអោយសោះ ព្រោះខ្លាចក្រែងភ្ញៀវយល់ថាអ្នកនាងខ្វះបាយ។ កាលបើភ្ញៀវពិសារអស់សំល រឺឆា អ្នកនាងគួរយកចានមួយថ្មីទៀតដួសមកបន្ថែមលើចាន ដែលអស់នៅលើតុគឺមិនត្រូវយកចានដែលអស់នោះទោដួសពីឆ្នាំងមកទេ។ ម្យ៉ាងទៀតម្ហូបអាហារដែលទុកសំរាប់ថែម អ្នកនាងគួររៀបទុកមួយតុក្បែរនោះ សោះរវល់នឹងដើរចុះឡើងៗទៅឯចង្ក្រានបាយ។ បើអ្នកនាងចង់បន្ថែមអ្វីមួយ អ្នកនាងមិនចាំបាច់សួរភ្ញៀវទេ ព្រោះភ្ញៀវមានការចាំបាច់នឹងនិយាយតមមកវិញថា "គ្រប់គ្រាន់ហើយអរគុណហើយ"។ នៅពេលបន្ថែមម្ហូបអាហារ អ្នកនាងត្រូវមានការប្រុងប្រយ័ត្នអោយមែនទែន គឺមិនត្រូវលើកសំលទឹក រឺឆាអោយហៀរកំពប់ប្រឡាក់ខោអាវភ្ញៀវឡើយហើយគួររកចន្លោះល្មមសំរាប់ដាក់ម្ហូប គឺមិនត្រូវធ្វើអោយប៉ះកែវប៉ះចានរណ្តុងរណាំងសោះឡើយ។

លុះពិសារភោជនាហារហើយ អ្នកនាងមិនត្រូវបង្ខំអោយភ្ញៀវចេញទៅភ្លាមៗទេ ឯភ្ញៀវក៏មិនត្រូវនៅជំអក់ទាល់តែហួសអធ្រាត្រដែរ។ អ្នកនាងជាម្ចាស់ផ្ទះត្រូវធ្វើកិរិយាអោយរីករាយនឹងភ្ញៀវដរាប មិនត្រូវនិយាយប្រាប់ភ្ញៀវ ខ្ញុំរវល់ទៅនេះទៅនោះរឺចុកខ្នងរោយចង្កេះរឺស្វាបសារចុះឡើងឡើយ។

លុះភ្ញៀវអញ្ជើញចេញទៅ អ្នកនាង និងស្វាមីគួរជូនដំណឹងភ្ញៀវរហូតដល់មាត់ទ្វារផ្ទះ ហើយអ្នកនាងអញ្ជើញអោយគេមកលេងទៀតពេលទំនេរ ដែលគេអាចមកបាន។ ឯភ្ញៀវគឺគួរនិយាយអរគុណម្ចាស់ផ្ទះ ហើយនិយាយថានឹងមកលេងទៀតទោះបីខ្លួនជាភ្ញៀវមិនបានមកទៀត រឺក៏ជាប់រវល់ទៅខេត្តក្រៅឆ្ងាយៗក្តី។

❀ ❀ ❀ ❀

# របៀបបង្ហាញខ្លួនដល់ភ្ញៀវ

គេត្រូវបង្ហាញខ្លួនចំពោះភ្ញៀវរបៀបដូចម្តេច?

ការបង្ហាញខ្លួននេះបានពីរយ៉ាងគឺ បង្ហាញខ្លួនដោយខ្លួនឯងនិងបង្ហាញខ្លួនដោយអ្នកដទៃ។

**បង្ហាញខ្លួនដោយខ្លួនឯង** : តាមការនិយមថ្លៃថ្នូរ។

បុរសដែលបង្ហាញខ្លួនទៅស្ត្រី រឺទៅបុរសគ្នាឯង ត្រូវបង្ហាញខ្លួនដោយនិយាយថា ខ្ញុំបាទ រឺខ្ញុំឈ្មោះ ក ខ ដោយប្រាប់ទាំងគោត្តនាម និងនាមខ្លួន។

ស្ត្រីដែលបង្ហាញខ្លួនទៅស្ត្រីគ្នាឯង រឺទៅបុរសគួរនិយាយប្រាប់តែនាមរបស់ខ្លួនក៏ជាការគួរសមគ្រប់គ្រាន់ហើយ។

**បង្ហាញខ្លួនដោយអ្នកដទៃ** :

មនុស្សម្នាក់បង្ហាញខ្លួនមនុស្សម្នាក់ទៀត ទៅអ្នកដទៃត្រូវចេះគិតបន្តិចគឺត្រូវសំឡឹងគិត តើមនុស្សទាំងពីរនាក់ដែលយើងត្រូវបង្ហាញអោយស្គាល់គ្នានេះមានអាយុប៉ុន្មាន នរណាចាស់ជាងគេនរណាអ្នកមានបុណ្យសក្តិធំជាងនរណា។ គេត្រូវបង្ហាញមនុស្សក្មេងប្រាប់មនុស្សចាស់ អ្នកតូចប្រាប់អ្នកធំ។ តាមធម្មតាគេបង្ហាញមនុស្សប្រុសប្រាប់មនុស្សស្រី លើកលែងតែបុរសដែលត្រូវបង្ហាញជាប្រមុខរដ្ឋ រឺជាអ្នកបួសក្នុងសាសនា។ ក្នុងការបង្ហាញខ្លួននេះយើងជាអ្នកបង្ហាញគេ ត្រូវនិយាយកុំអោយមានការសង្ស័យចង់សួរខ្លាំងពេក គួរនិយាយប្រាប់ថា ៖ លោក ក ត្រូវជាប្អូន ជាបង ជាមា ជាឪពុក ជីតា រឺជាមិត្តរបស់ខ្ញុំ មុខងាររាល់ថ្ងៃរកស៊ីធ្វើការអ្វី។ បើយើងបង្ហាញខ្លួនស្រី ត្រូវនិយាយថានាងនេះ លោកស្រីនេះ។ល។ ឈ្មោះ ខ ត្រូវជាប្អូន បង ម្តាយ ជីដូន រឺជាមិត្តនារី ។ល។ របស់ខ្ញុំ សព្វថ្ងៃធ្វើការនៅកន្លែងណា។ល។ បើស្ត្រីនោះមិនបានធ្វើការអ្វីក្រៅពីនៅថែរក្សាផ្ទះ ក្នុងឋានៈជាមេផ្ទះ យើងមិនចាំបាច់និយាយថា នាងនេះធ្វើអ្វីៗឡើយបើនាងជាសិស្សសាលាយើងត្រូវប្រាប់ថា រៀននៅថ្នាក់ណាសាលាណា ។ល។

បើមនុស្សដែលយើងគួរបង្ហាញគេនោះត្រូវជាប្តី រឺត្រូវជាប្រពន្ធរបស់យើង យើងត្រូវនិយាយប្រាប់គេដោយត្រង់ដោយនិយាយថា ៖ លោកជំទាវ លោកស្រី ឯកឧត្តម លោកនេះត្រូវជាប្រពន្ធរបស់ខ្ញុំបាទ រឺនេះត្រូវជាប្តីរបស់នាងខ្ញុំ ។ល។ បើនិយាយអោយគួរសមតាមរបៀបជាតិយើង យើងគួរនិយាយអោយបានសមរម្យ អោយទន់ភ្លន់ ដោយនិយាយថា ជំរាបប្រសាសន៍លោកជំទាវ លោកស្រី ឯកឧត្តម លោក នាងនេះ រឺលោកនេះត្រូវជាប្រពន្ធ រឺប្តីរបស់ខ្ញុំបាទ រឺនាងខ្ញុំ ។

លុះបង្ហាញតាមលំដាប់ថ្នាក់ គួរសមមនុស្សម្នាក់ហើយយើងទៀតនោះត្រូវជាអ្វីៗដែរ។

នៅពេលដែលគេនាំអោយស្គាល់ដំបូងនេះ ភ្ញៀវម្ខាង រឺម្ខាងទៀត មិនគប្បីជជីកសាកសួរឫសគល់ កំណើតកើតជាតាំងពីតូចក្រូចឆ្មាររហូតដល់ចាស់សក់ស្កូវសោះឡើយ។ គេត្រូវសាកសួរគ្នាខ្លះៗដែរ ប៉ុន្តែអោយសមល្មមតាមការដែលយើងទើបនឹងស្គាល់គេដំបូង។

ដៅពេលដែលគេបង្ហាញខ្លួនយើង ដល់អ្នកម្នាក់ទៀតនោះយើងសំពះគួរសមគ្នាដោយសម្លឹងមុខអោយចំ ហើយយើងត្រូវបញ្ចេញទឹកមុខអោយញញឹមប្រិមប្រិយសំដែលអោយភ្ញៀវម្នាក់ទៀតនោះដឹងថា យើងចូលចិត្តការគួរសមតាមប្រពៃណីជាតិ យើងមិនត្រូវបញ្ចេញទឹកមុខក្រញូវសម្លឹង ខ្ញើមរអើមគេសោះឡើយគួរយើងយល់ថាគ្នាក៏ជាមនុស្សមានជីវិតតែមួយដូច យើងដែរ ហើយជាពិសេសគេក៏ជាមនុស្សមានចិត្តចេះយល់ល្អ អាក្រក់ដែរ ។

# សុជីវធម៌របស់ភ្ញៀវ

ភ្ញៀវគេមិនត្រូវដើរចូលទៅក្នុងផ្ទះអ្នក ដែលអញ្ជើញដោយមិនដោះមួករី មិនជូតស្បែកជើងលើទ្រនាប់កំរាលជូតស្បែកជើងទេ។

យើងជាភ្ញៀវ មិនត្រូវដើរចូលទៅរកកន្លែងកិត្តិយសដោយមិនទាន់បាន ទទួលពាក្យអញ្ជើញរបស់ម្ចាស់ផ្ទះទេ ។

មិនត្រូវទំលាក់គូថអង្គុយមុនម្ចាស់ផ្ទះ ។

មិនត្រូវអង្គុយយោលកៅអីទៅមុខ ទៅក្រោយដូចអង្រឹង រឺអង្គុយលើជើង កៅអីតែពីរទេ បើកៅអីនោះមានជើងបួន។

មិនត្រូវលាផ្ទត់កន្សែងទាំងអស់ត្រដាងលើតុទេ។

នៅពេលដែលម្ចាស់ផ្ទះនាំមុខអោយទទួលទានអាហារយើងមិនត្រូវ បួង មាត់លេបមិនមើលគេឯងទេ។

-គេមិនត្រូវផ្ដុំសំលដើម្បីអោយត្រជាក់ទេ

-សម ស្លាបព្រាសំរាប់បង្អែម ដែលមិនទាន់ប្រើ មិនត្រូវដាក់ច្រងេង ច្រងាង រឺនាំអោយធ្លាក់ទៅលើដីទេ គេត្រូវរៀបចំអោយស្រួលតាមលំនាំដែល ម្ចាស់ផ្ទះបានរៀប។

បើមានភ្ញៀវម្នាក់លូកហើយ យើងមិនត្រូវលូកជ្រែកដៃរទេត្រូវដកដៃ ចេញវិញ នៅពេលដកចេញនោះគេមិនត្រូវលៀនអណ្ដាតទៅលិទ្ធទេ ទោះ ពេលញុំារួចក៏គេមិនត្រូវលិទ្ធស្លាបព្រាដៃរគេមិនត្រូវយកសម ស្លាបព្រា រឺយក ចង្កឹះជ្រាវរករើសយកសាច់ រឺបន្លែដែលត្រូវចិត្តខ្លួននោះទេ បើម្ហូបដែលឆ្ងាញ់នៅ ឆ្ងាយពីយើងពេក យើងមិនត្រូវបង្ហើបគូថឈោងចាប់យកម្ហូបនោះឡើយគឺត្រូវ អាស្រ័យតែម្ហូបអាហារណាដែលនៅជិតខ្លួន។

នៅពេលម្ហូបពេញមាត់ គេមិនត្រូវនិយាយអោយឡុល រឺសើចក្អាកក្អាយ បណ្ដោយអោយឈ្លក់ចេញតាមមាត់រឺតាមច្រមុះទេ។

បាយ រឺអាហារ គេត្រូវញុំាអោយអស់ពីចានផ្ទាល់របស់ខ្លួនបើយល់ថាញុំា

មិនអស់ទេ គេមិនត្រូវជួសច្រើនឡើយ ។

លុះពេលទទួលទានហើយ គេមិនងើបក្រោកក្រេះដោយមិនរវល់ចាំអ្នកជិតខាងនោះទេ ព្រោះសញ្ញាដែលក្រោកចេញពីកៅអីនេះ ច្បាប់សុជីវធម៌តម្រូវអោយម្ចាស់ផ្ទះអោយសញ្ញាដល់ភ្ញៀវដោយដើរនាំមុខភ្ញៀវទៅរកកន្លែង ទទួលភ្ញៀវ។

នៅពេលខ្លួនទទួលទានហើយ អ្នកជិតខាងមិនទាន់ហើយយើងមិនត្រូវអុជបារីជក់បង្ហុយផ្សែងមុខគេទេ ការជក់បារីនៅតុបាយជាទំលាប់អាក្រក់មួយ។

❁ ❁ ❁ ❁

www.facebook.com/7khmer


# សុជីវធម៌ដែលគួរពិចារណា ដើម្បីញ៉ាំចំណីអាហារ

**បបរ** នៅចំពោះមុខភ្ញៀវជាច្រើន គេត្រូវមានការប្រុងប្រយ័ត្នជាច្រើន ព្រោះភ្នែកមនុស្សតែងសម្លឹងមករកយើងច្រើនណាស់។ នៅពេលដួសបបរពីចានតូច អ្នកនាងគួរធ្វើសឹមៗ កុំអោយស្រក់រលាក ហៀរគ្រប់អន្លើ អ្នកនាងមិនគួរលើកចាកធំចាក់ផ្ទឹងមកចានតូចតែម្តងទេ។ បើយើងត្រូវញ៉ាំ ស្លាបព្រានិងចានធំល្មម អ្នកនាងគួរដួសបបរបញ្ចូលទៅក្នុងមាត់អោយសឹមៗល្មមៗ កុំចាប់ភ្លាមកាយពេញស្លាបព្រា ហើយដាក់លេបៗមិនមើលគេឯងអោយសោះ អ្នកនាងត្រូវចេះស្ទង់ល្បឿនតាមអ្នកជិតខាង ឯការឃើតយូរហូតដល់យូរៗ លើកមួយស្លាបព្រានោះក៏ជាការមិនគួរសមដែរ ព្រោះនាំអោយអ្នកដែលគេអញ្ជើញយើងមកនោះ មានការព្រួយបារម្ភថាបបររបស់គេមិនឆ្ងាញ់។ បើម្ចាស់ផ្ទះដាក់ចានចង្កឹះអោយយើងបរិភោគ យើងត្រូវយកវែកដួសពីចានធំដាក់មកចានចង្កឹះ ហើយមិនត្រូវលើកចានដោយយកចង្កឹះ ទាត់បបរបញ្ចូលមាត់អោយលាន់លឺសូរគ្រូក! គ្រូកដូចអូសទូកនោះឡើយ។ បើម្ចាស់ផ្ទះដាក់បបរមាន់ បបរសាច់ត្រីក្តាមបបរសាមចូក មកអោយយើងដួស យើងមិនត្រូវរើសស្រង់យកតែដុំសាច់ដាក់ចានតូចរបស់យើងទេ។ បើម្ចាស់ផ្ទះដាក់បបរស និងសាច់ រឺចំណី បបរនៅចានមួយទៀតភ្ញៀវមិនគប្បីញ៉ាំបបរមួយស្លាបព្រា មួយហុត រួចចាប់យកចំណីសំរាប់បបរបីរឺបួនម៉ាត់មកទំពាលេបទេ។

ទោះបីបបរនោះឆ្ងាញ់យ៉ាងណាក៏ដោយ ភ្ញៀវមិនត្រូវធ្វើឫករហ័សរហួនដូចជាឃ្លានខ្លាំងពេកនោះឡើយ។

ទោះបីខ្វះបបរមិនគ្រប់គ្រាន់ក៏ដោយ ភ្ញៀវមិនត្រូវលើកចាកផ្ទឹងងើយដើម្បីស្រូបយកគ្រាប់បបរ មួយគ្រាប់-ពីរគ្រាប់នៅបាតចាននោះទេ។

**ចាប់យកត្រីមកបរិភោគ** ភ្ញៀវមិនគួរយកដៃលើកយកដៃលើកយកត្រីមកអង្កៀម រឺជញ្ជក់សាច់ពីឆ្អឹងអោយលឺសូរដូចជឹងចក់ស្រែកនោះទេ។ ភ្ញៀវត្រូវ


Facebook : Entertainment And Knowledge

www.facebook.com/7khmer


យកសមចាក់ពន្លាត់យកសាច់ត្រឹមកបរិភោគមិនត្រូវយកកាំបិតមកចាក់ រឺកាន់ទេ ។

**ចាប់យកសាច់** យើងគួរចាប់យកសាច់ដោយកាត់ម្តងមួយដុំតូចល្មមញ៉ាំ មិនត្រូវកាត់ចិញ្ច្រាំអោយអស់ ហើយចាំយកម្តងមួយដុំនោះទេ។ បើជាសាច់មាន់ សាច់ទា ។ល។ អ្នកនាងគួរយកតែសាច់ដែលល្មមញ៉ាំ មិនត្រូវលើកយកឆ្អឹងមកអង្អៀម សម្លឹងមេឃសម្លឹងផ្កាយចំពោះមុខភ្ញៀវកិត្តិយសឡើយ។

**សាឡាត់** គេមិនយកសាឡាត់មកកាត់ដាក់ចានទេ។ បើស្លឹកវាធំពេក គេត្រូវយកសមមកហែកវា គេមិនប្រើកាំបិតទេ។

**ញ៉ាំអន្លក់**-អន្លក់ ទឹកគ្រឿង គេតែងតែទទួលក្នុងពេលអញ្ជើញភ្ញៀវមកក្នុងការស្និទ្ធស្នាល ។ នៅឱកាសពិធិកិត្តិយសធំៗគេមិនប្រើម្ហូបអាហារនេះទេ ព្រោះធ្វើអោយភ្ញៀវមានការពិបាកច្រើនណាស់ តាំងពីចាប់វេញស្លឹកអន្លក់រហូតដល់ជ្រលក់នឹងទឹកត្រី។ នៅក្នុងឱកាសអញ្ជើញរបៀបស្និទ្ធស្នាល គេអាចរៀបចំអន្លក់ ដោយរៀបជាដុំៗអោយហើយស្រេច ដូចជាអន្លក់ត្រកួនជាដើម។ ត្រកួនគេពុះដើមជ្រៀកត្រាំទឹកអោយងល្អ។ អន្លក់ស្ពន់ គេត្រូវវេញទងស្ពន់ល្មមមួយម៉ាត់។ ដើម្បីស្រួលអោយភ្ញៀវចាប់យកទៅញ៉ាំ។

**ខ្យងសមុទ្រ** ភ្ញៀវអាចយកចន្ទាសមករុកយកសាច់ហើយអាចលើកហុតយកជាតិទឹក នៅក្នុងខ្យងនោះបានតាមចិត្តនិយម។

**ញ៉ាំពងមាន់** រឺពងទា អ្នកនាងត្រូវគោះបំបែកដោយស្លាបព្រា មិនត្រូវលើកកាំបិតមកពុះខ្លាំងតែម្តងទេ។ គេប្រើពងមាន់ រឺពងទានេះនៅឱកាសជប់លៀបស្និទ្ធស្នាលធម្មតា។

**ញ៉ាំក្រូច** បើគេអញ្ជើញអ្នកនាងទៅលេងកំសាន្តផ្ទះគេហើយគេដាក់ផ្លែក្រូចអោយញ៉ាំ អ្នកនាងត្រូវមានការប្រុងប្រយ័ត្នខ្លះដែរក្នុងការញ៉ាំផ្លែក្រូចនេះ បើគេដាក់ផ្លែក្រូចពោធិសាត់ទាំងសំបក កាំបិត និងសមមកអោយ អ្នកនាងត្រូវយកផ្លែក្រូចនោះមកចិតសំបកត្រឹមពាក់កណ្តាលខាងលើ មិនត្រូវចិតអោយអស់តែម្តងហើយមិនកាន់សាច់ក្រូចនៅនឹងដៃផ្ទាល់ទេ។ លុះចិតសំបកហើយគេចិតសាច់ក្រូចមួយចំណិតរួចសឹមយកសមមកចាក់ទៅញ៉ាំ។


Facebook : Entertainment And Knowledge

www.facebook.com/7khmer



បើក្រូចពណ៌លឿងទុំសំរាប់បកញ៉ាំ រឺក្រូចឃ្វិចអ្នកនាងត្រូវយកចុងសម មកកំចាត់ទំលុះមុខសំបកក្រូច ខ្ទាតទៅប៉ះភ្នែកអ្នកជិតខាងអោយសោះ បើក្រូចខ្លងធំៗ ម្ចាស់ផ្ទះត្រូវពុះបកសំបកអោយហើយជាស្រេច ហើយដាក់ក្នុងចានព្រមទាំងដាក់សមនៅជិតចាន អោយភ្ញៀវស្រួលចាប់យកមកញ៉ាំទៀតផង ភ្ញៀវមិនត្រូវចាប់ញ៉ាំម្តងមួយក្លែបធំ ដែលគេដាក់តម្រៀបសំរាប់អោយល្អមើលនៅលើចាននោះទេ គឺយកម្តងបន្តិចល្មមមួយម៉ាត់តូចទើបគួរសម។

**ផ្លែប៉ោម** ផ្លែប៉ោមត្រូវពុះជាពីរ ហើយជាបួន (ពុះបណ្តោយផ្លែ) ពុះដោយកាំបិត ហើយយកសមចាក់យកមួយជ្រុងពីចានធំមកដាក់ចានតូចសំរាប់យើងញ៉ាំ បន្ទាប់មកគេយកកាំបិតមកចិត ចូកយកសាច់មកកាត់ជាដុំតូចៗ ល្មមញ៉ាំសឹមយកសមមកចាក់យកញ៉ាំ។ បើចង់កាត់ផ្លែឈើមានទំរង់ដូចគ្នានេះ ចែកដល់អ្នកជិតខាង អ្នកនាងគួរយកមួយចំហៀងដែលគ្មានជាប់សន្ទង់ផ្លែ ហើយពុះអោយត្រង់ទៅខាងក្រោម កុំពុះទុកសន្ទង់អោយគេ ហើយពុះឆេវយកធំខាងក្រោមសំរាប់ខ្លួន។ បើគេយកផ្លែឈើដែលគេពុះនៅក្នុងចានមកអោយអ្នកនាង អ្នកនាងត្រូវយកមួយចំហៀងណាដែលមិនជាប់បណ្តូល និងសន្ទង់។

បើអ្នកនាងញ៉ាំផ្លែឈើជាបង្អែម ហើយមានគ្រាប់តូចៗដូចជាផ្លែមៀនសៅម៉ៅ ។ល។ អ្នកនាងមិនត្រូវព្រោះគ្រាប់នោះទៅលើកំរាលតុ រឺទំលាក់ទៅដីក្បែរជើងនោះទេ អ្នកនាងត្រូវយកដៃអ្នកនាងធ្វើជាតម្រង ហើយខ្ទាក់គ្រាប់នោះមកក្រៅ ដោយយកទៅដាក់លើចាន។

**របៀបរៀបចាន ស្លាបព្រា កែវ លើតុទទួលភ្ញៀវ**

**• ការនិយមតាមរបៀបអន្តរជាតិនៅអឺរ៉ុប**

នៅខាងមុខភ្ញៀវនីមួយៗ មានចានធំមួយសំរាប់ដាក់បាយនៅខាងឆ្វេងចានមានសម ដែលដាក់របៀបផ្កាប់ នៅខាងស្តាំមានកាំបិតសំរាប់ហាន់សាច់ដែលដាក់ចុងស្រួចទៅខាងមុខ ដងមករកភ្ញៀវស្លាបព្រាមួយដែលដាក់ផ្កាប់ទៅលើកំរាលតុ ជួនកាលគេដាក់ឈើរឺដែកបន្ទាសសំរាប់ចាក់យកសាច់ខ្យងផង។ នៅក្នុងពិធីជាកិត្តិយសគេមិនដាក់ស្រោមកាំបិតទេ នៅក្នុងពិធីនេះគេដាក់កាំបិត សមស្លាបព្រា សំរាប់បង្អែមនៅលើចានបង្អែម។ នៅពិធីជប់លៀងរបៀប



Facebook : Entertainment And Knowledge

www.facebook.com/7khmer


ស្អិទ្ធស្នាល គេអាចដាក់សម ស្លាបព្រា រឺកាំបិតសំរាប់ញ៉ាំបង្អែមនៅចន្លោះចាន និងកែវ។ កែវនេះគេដាក់ខាងមុខ គឺនៅចំពីមុខភ្ញៀវ ។ បើនៅក្នុងពិធីជប់លៀង ជាកិត្តិយសក្នុងពិធីបុណ្យអ្វីមួយហើយគេត្រូវការប្រើកែវច្រើនសំរាប់ភ្ញៀវម្នាក់ៗ គេត្រូវរៀបកែវអោយមានសណ្តាប់ធ្នាប់ល្អ គឺរៀបកែវធំពីខាងឆ្វេង បន្ទាប់មក កែវតូចៗរៀបដង្ហែគ្នាតាមលំដាប់បន្ទាប់ៗមកខាងស្តាំ។

**• ការនិយមរបៀបចិន ៖**

របៀបនេះ យើងចូលចិត្តរៀបចំពិធីជប់លៀងរបៀបស្អិទ្ធស្នាលគឺ គេត្រូវ ដាក់ចានចង្កឹះនៅពីមុខភ្ញៀវ ចង្កឹះត្រូវតម្រៀបគ្នាដាក់ចុងតូចចូលទៅក្នុង ហើយ ដាក់ពីខាងស្តាំចានស្លាបព្រាធ្វើអំពីជាតីដីដូចចាន សំរាប់ហុតដឹកសំលដាក់ពី ខាងស្តាំកែវស្រា រឺទឹកដាក់ពីខាងឆ្វេង កន្សែង រឺក្រដាសសំរាប់ជូតដាក់ពីខាង ឆ្វេង ។

❁ ❁ ❁ ❁


Facebook : Entertainment And Knowledge

# នៅតាមភោជនីយដ្ឋានធំៗ

សំលៀកបំពាក់តាមរបៀបទីក្រុង នារីស្លៀកសំលៀកបំពាក់តាមរបៀបព្រឹក រឺល្ងាចស្របតាមពេលដែលទៅកាន់ទីនោះបុរសស្លៀកពាក់ពណ៌ស្រគាំល្មម។ នៅពេលចូលទៅកាន់ទីសមរម្យនេះបុរសដើរចូលទៅមុន ហើយស្រ្តីដើរចូលតាមក្រោយ (បើទៅទាំងបុរស-ស្រ្តី) ។ បុរសជាអ្នករើសកន្លែងសមគួរ ។ បើកន្លែងរើសនោះនៅកៀន រឺជាប់នឹងជញ្ជាំងត្រូវអោយនារីអង្គុយកន្លែងខាងក្នុង។ បុរសជាស្វាមីតែង អោយភរិយាអង្គុយពីខាងស្តាំអ្នកដែលអញ្ជើញអោយគេទៅ រឺបុរសអ្នកនាំដំណើរ ជាអ្នកចាត់ចែងនាំមុខហៅម្ហូបអាហារ រឺស្រាដោយពិគ្រោះជាមួយស្រ្តី រឺអ្នកដែលខ្លួនអញ្ជើញទៅ។ គេមិនអង្គុយសញ្ជប់សញ្ជឹងអស់ពេលយូរយារ ដើម្បីសំរេចចិត្តហៅម្ហូបណាំមួយមុខនោះទេ នៅពេលដែលហៅរួចហើយ គេមិនត្រូវហៅអ្នកបំរើអោយផ្លាស់មុខម្ហូបវិញ ពីរ រឺបីដង មួយភ្លែតនោះទេ។ ភ្ញៀវ រឺអ្នកដែលគេអញ្ជើញអោយទៅ មិនគប្បីហៅម្ហូបណាផ្សេងពីអ្នកដែលអញ្ជើញយើងទេ។

នៅពេលញ៉ាំ គេត្រូវនិយាយគ្នាល្មមៗស្តាប់លឺ កុំសើចក្អាកក្អាយ កុំសម្លក់គេអ្នកតុជិតខាង អោយគេស្លាក់ម្ហូបអាហារកុំនិយាយឈ្មោះនរណាម្នាក់ប្រាប់គូសន្ទនារបស់យើងលឺពេក ពេលញ៉ាំត្រូវប្រុងប្រយ័ត្ន ដូចគេអញ្ជើញយើងអោយទៅលៀងភោជនាហារនៅទីផ្ទះរបស់គេក្នុងពិធីណាមួយដែរ។ ត្រូវឧស្សាហ៍ជូតមាត់ដែលប្រឡាក់ខ្លាញ់។ ធម្មតាញ៉ាំម្ហូបអាហារ តែងមានបែកញើសខ្លះ រឺលាត់ពណ៌ក្រែមបបូរមាត់ខ្លះមិនខាន នារីមិនគប្បីបញ្ចេញកញ្ចក់និងក្រែមលាបមាត់មកតុបតែងខ្លួនពេលកំពុងញ៉ាំដូច្នោះទេ នោះបីនៅក្នុងពិធីបដិសណ្ឋារកិច្ច រឺជប់លៀងរបៀបណាមួយ ក៏មិនគប្បីធ្វើដែរ ក្រាស់សិតសក់ម្សៅ ក៏មិនត្រូវយកមកបញ្ចេញលំអសម្ផស្សប្រាប់គេឯងនៅទីនោះដែរ។ កុំសម្លឹងសម្លក់ម្ហូបអាហារនៅក្នុងចានអ្នកដទៃ បើញ៉ាំមិនអស់ម្ហូបក្នុងចានដែលបានដួសរួចហើយ គប្បីទុកចោល រឺហៅអ្នកបំរើមកផ្លាស់ចានអោយ មិនត្រូវ

ចាប់អោយអ្នកជិតខាងខ្លួនទេ ឯអ្នកដែលគេចាប់អោយរួចហើយរបៀបនេះ គប្បីហៅអ្នកបំរើមកផ្លាស់ចានវិញនៅពេលដែលខ្លួនមិនត្រូវការម្ហូបនេះ មិនត្រូវចាប់អោយគេអ្នកដទៃទៀត រឺចាប់ដាក់ទៅអ្នកដើមវិញទេ។

អ្នកញ៉ាំមិនគប្បីអោយប៉ះកែវ រឺចានម៉ុងម៉ាំងទេ។ ប្រសិនបើពេលញ៉ាំនេះ មាននរណាម្នាក់ជាអ្នកស្គាល់យើង គេជំរាប់សួរយើង ហើយយើងកំពុងកាន់ម្ហូបបញ្ចូលទៅក្នុងមាត់ យើងមិនត្រូវប្រញឹមប្រញាប់របហ័សដៃទំលាក់សម ស្លាបព្រា រឺចង្កឹះណុងណាំងពេកទេ យើងគ្រាន់តែងក់ក្បាលទទួលបន្តិចក៏ជាការគួរសមល្មមគ្រប់គ្រាន់ហើយ។

នៅពេលញ៉ាំរួច អ្នកដែលអញ្ជើញគេត្រូវអោយអ្នកបំរើគិតថ្លៃម្ហូបអាហារលុះដល់គេយកជើងពានដែលគិតលុយនោះមកជូនអ្នកដែលអញ្ជើញគេ យើងជាភ្ញៀវដែលគេអញ្ជើញមិនត្រូវដកក រឺចោលកន្ទុយភ្នែកលបមើលចំនួនទឹកប្រាក់ដែលគេត្រូវបង់ទេ។ អ្នកដែលត្រូវគេអញ្ជើញ មិនត្រូវដណ្តើមចេញលុយជំនួសអ្នកដែលអញ្ជើញឡើយ ។ កុំដណ្តើមគ្នាចេញលុយ។

ម្យ៉ាងទៀត បើគ្មានលុយកាក់គ្រប់គ្រាន់ល្មមអញ្ជើញគេទេយើងមិនគប្បីហៅគេអោយទៅចេញលុយអោយខ្លួន រឺហោគេទៅលក់ចោលនៅផ្ទះចិន ហើយខ្លួនឯងដោះខ្លួននៅពេលញ៉ាំរួចដោយកុហកថាសុំទៅបត់ជើង រឺទៅក្រោយបន្តិចនោះទេ។

បើយើងដឹងខ្លួនថា យើងមិនមែនជាអ្នកដែលគេអញ្ជើញអោយចូលទៅញ៉ាំដោយគេចេញលុយអោយទេ យើងជាពួកម៉ាកមិត្តភក្តិនឹងគ្នាគប្បីចូលលុយគ្នាខ្លះតាមការគួរសម ។

❁ ❁ ❁ ❁


Facebook : Entertainment And Knowledge

www.facebook.com/7khmer


# នៅសណ្ឋាគារ

យើងគោងដឹងអោយជាក់ក្នុងចិត្តថា សណ្ឋាគារដែលយើងជួលសំណាក់នៅមិនមែនមានតែយើងម្នាក់នោះទេដែលជាអ្នកជួលសណ្ឋាគារនេះ។ ពិតមែនហើយថាយើងជួលគេដាច់ថ្លៃទុកសំរាប់ខ្លួនយើង តែយើងកុំភ្លេចថា ម្ចាស់សណ្ឋាគារមានសិទ្ធិនឹងរិះគន់ដល់យើងដែរ ក្នុងករណីដែលយើងរំលោភលើបទបញ្ជារបស់គេ ដែលមានថែងទុកក្នុងបន្ទប់នីមួយៗ ។ យើងត្រូវចេះគោរពសណ្តាប់ធ្នាប់ដល់ពេលនិទ្រារបស់អ្នកជិតខាង កុំហួចច្រៀង ទះដៃ ឡូឡា។ វិទ្យុទទួលសំលេងរបស់យើង យើងត្រូវបន្ថយសំលេងបន្តិចតាំងពីម៉ោង២២យប់ទៅ។ កុំប្រកាន់ច្រចាប់គ្នារវាងប្តីប្រពន្ធដោយលើកកៅអី រឺរបស់តាំក្នុងបន្ទាប់ចោលគ្នាគ្រវាត់គ្រវែងពេលបន្ទប់។

ចេះរក្សាគំនិតអនាម័យ និងសំអាត កុំស្តោះទឹកមាត់ពាសពេញកំរាលបន្ទប់ កុំដេកជាក់ពូកខ្នើយ។ កុំយករាំងននមាត់ទ្វាររឺមាត់បង្អួចរបស់គេ ទុកជាកំណាត់សំរាប់ជូតដៃ ជូតស្បែកជើង រឺជូតសំបោរ។ កុំបើកទឹកចោលអោយហូរហៀរពេញបន្ទប់ទឹក ពេលបត់ជើងហើយត្រូវបើកទឹកលាងបង្គន់។ កុំយកខ្នើយកើយមកធ្វើខ្នើយគង កុំយកភួយមកជូតជើង។ បើយើងខ្វះអ្វីៗត្រូវចុចកណ្តឹងហៅអ្នករក្សាបន្ទប់អោយយកអោយ។

❁ ❁ ❁ ❁


Facebook : Entertainment And Knowledge

www.facebook.com/7khmer


# សុជីវធម៌នៅក្នុងផ្ទះសំបែង

ផ្ទះរបស់យើងត្រូវរៀបចំអោយបានសមរម្យ តាមស្ថានភាពទឹកដី រៀបចំចានក្បានអោយនៅត្រង់ទីកន្លែង។ សំលៀកបំពាក់ទុកដាក់អោយមានសណ្ដាប់ធ្នាប់ កុំយកទៅព្យួរនៅបន្ទប់ទទួលភ្ញៀវ កុំយកស្រោមជើង រឺកំណាត់អ្វីទៅពាក់លើកៅអី រឺតុសំរាប់ទទួលភ្ញៀវកុំហាលខោអាវលើថ្នាក់ដៃជណ្ដើរ រឺបាំងបង្អួរខាងមុខផ្ទះ។ កុំចាក់សំរាមខាងមុខផ្ទះ ។ ផ្ទះនីមួយៗត្រូវមានសោរបិទរបងផ្ទះ ដើម្បីការពារមិនអោយចោរ រឺសត្វចូលបាន។ កុំមាត់ឡូឡាពេលគេចូលនិទ្រាគ្រប់គ្នា។

កុំស្រែកពន្យុះឆ្កែអោយដេញអ្នកដំណើរ តាមផ្លូវសាធារណៈ។ នៅពេលក្រោកពីដេក ត្រូវស្លៀកពាក់អោយស្រួលបួលហើយសក់ត្រូវជ្រង រឺសិតអោយបានសមរម្យ ។ កុំយកជើងបើករឺបិទទ្វារ។ កុំយកដៃដែលប្រឡាក់ទៅជូតជញ្ជាំង កុំហិះសំបោះជូតកៀនមាត់ទ្វារកុំស្រែកជេរវាយដំក្មេងក្មាងទ្រហឹងអឺងអាប់ ។

**របៀបជួលផ្ទះ**

បុរសជាស្វាមី និងនារីជាភរិយាត្រូវមានចិត្តស្របគ្នាមុននឹងសង់ផ្ទះ រឺជួលផ្ទះ ។

ការជួលផ្ទះ រឺសង់ផ្ទះគ្មានផ្ទះបាយ រឺផ្ទះបាយតូចពេកធ្វើអោយប្រពន្ធលោកមានការអាក់អន់ស្រពន់ចិត្ត ចំពោះលោកមិនខាន។ តទៅនេះយើងមិនបាច់និយាយពីការសង់ផ្ទះទេ ព្រោះនេះជាភារៈផ្ទាល់ដែលគួរតែលោក និងភរិយាលោកលៃលកអោយមែនទែន កុំប្រថុយអោយសោះ ព្រោះនេះជាសំបុកប្រចាំជីវិត ។ នេះជារបៀបជួលផ្ទះ ដែលគេយល់មុននឹងជួលផ្ទះណាមួយត្រូវគិតនិងលៃលកដល់ ៖

១. តំលៃឈ្នួលសមល្មមតាមថវិកាគ្រួសារ

២. ចំនួនបន្ទប់ដែលគិតអោយគ្រប់គ្រាន់ល្មមចំនួនគ្រួសារ


Facebook : Entertainment And Knowledge

៣. ទំហំបន្ទប់នីមួយៗ

៤. ទីតាំងនៃផ្ទះ តើបែរមុខទៅទីណា មានបរិយាកាសល្អះល្អភ្លាភ្លំទេ មានភ្នាក់ងាររក្សាសន្តិសុខនៅជិតទេ

៥. ស្ថិតនៅជិតកន្លែងធ្វើការ ជិតផ្សារ

៦. មានជណ្តើរត្រឹមត្រូវតាមក្បួនខ្នាត

៧. មានទឹក ភ្លើងសំរាប់ប្រើប្រាស់

៨. មានអនាម័យគ្រប់គ្រាន់ បន្ទប់ទឹក បន្ទប់សំអាតខ្លួន បង្គន់ល្អ

៩. មានសភាពតាមសម័យសមគួរ មានបន្ទប់ទទួលភ្ញៀវ ទូរស័ព្ទមាន រោងដាក់រថយន្ត រឺយានជំនិះទេ មានកន្លែងចិញ្ចឹមសត្វទីធ្លាដើមឈើទេ។

គេអាចជួលផ្ទះ ដោយមិនបាច់សរសេរលិខិតអ្វីក៏បានដែរអោយតែអ្នកម្ចាស់ផ្ទះសុខចិត្ត។

តែបើម្ចាស់ផ្ទះទារសុំអោយធ្វើ យើងត្រូវធ្វើតាមក្បួនខ្នាតតាមលក្ខខ័ណ្ឌ ៤ ខ ដូចតទៅនេះ ៖

១. ត្រូវសរសេរឈ្មោះម្ចាស់ផ្ទះនិងអ្នកជួលផ្ទះនិងចំនួនទឹកប្រាក់ដែលត្រូវប្រគល់អោយប្រចាំខែ

២. ត្រូវសរសេរចំនួនឆ្នាំដែលសុខចិត្តជួល ដោយដាក់ថាចាប់តាំងពីថ្ងៃណា ខែណា ទៅដល់ទីនថ្ងៃណា ខែណា ឆ្នាំណាតែបើជួលមានកំឡុងមិនពិតប្រាកដ គេត្រូវធ្វើចំនួនបីខែម្តង

៣. ផ្ទះដែលត្រូវជួល ត្រូវសរសេរយ៉ាងខ្លីថា ផ្ទះ រឺបន្ទប់នោះនៅសង្កាត់ ស្រុក ភូមិ ខេត្ត ក្រុងណា ផ្លូវណា លេខប៉ុន្មាន មានទីធ្លា នៅក្នុងដីប៉ុន្មានឡូ មានសួនច្បាររឺទេ? ហើយមានអ្វីខ្លះដែលសំខាន់

៤. ប្រាក់ថ្លៃជួលមានចំនួនប៉ុន្មានក្នុងមួយខែ តើត្រូវបង់មុនប៉ុន្មាន។

លក្ខណៈដ៏ត្រឹមត្រូវនេះ ត្រូវមានបង់ពន្ធជូនរាជការទៀតផងម្ចាស់ផ្ទះដែលបានអោយកូនសោរដល់អ្នកជួលមុនពេលដាច់ខែ រឺមុនពេលដែលបានកំនត់ក្នុងលក្ខណៈដែលព្រមព្រៀងគ្នា បានសេចក្តីថា ម្ចាស់ផ្ទះសុខចិត្តអោយគេមកស្នាក់នៅដោយមិនគិតថ្លៃក្នុងប៉ុន្មានថ្ងៃនោះ។

អ្នកជួល ត្រូវសរសេរក្នុងកូនសៀវភៅមួយតូចរបស់ខ្លួនតើមានរបស់អ្វីខ្លះដែលគេទុកអោយប្រើ ឯម្ចាស់ផ្ទះក៏ត្រូវធ្វើដូច្នោះដែរ ដើម្បីកុំអោយមានការឈ្លោះគ្នាបែកមេឃ ព្រោះតែជើងមាំរឹតុមួយតូច។ នៅពេលអ្នកជួលចេញទៅវិញ អ្នកជាម្ចាស់ផ្ទះត្រូវមកមើលការខុសត្រូវខូចខាតអ្វីខ្លះ ហើយអាចនិយាយជាមួយអ្នកជួល អោយគេសងខ្លួនវិញដោយស្រួល ។ នៅពេលដែលគេចេញផុតត្រឹមត្រូវជាយូរហើយ ម្ចាស់ផ្ទះគ្មានសិទ្ធិទៅទារ អំពីរឿងបែកពាងរឿងរបេះមាត់បង្គន់ បាត់សោ ខូចគន្លឹះទ្វារទេ។

អ្នកជួលផ្ទះគេ ក៏មិនត្រូវបង្ហិនទ្រព្យគេអោយប្រឡាក់ស្រមេមស្រមាម រឺថ្មែផ្ទះរបស់គេអោយទៅជាកន្លែងដែលគ្មានអនាម័យដែរ។ នៅផ្ទះរបស់គេ កុំធ្វើអោយគេដេញព្រោះតែខ្លួនមិនស្អាត។ លុះដល់ពេលកំនត់ ត្រូវសងលុយថ្លៃផ្ទះហើយត្រូវសងគេភ្លាមកុំបង្អង់ចាំគេមកទារ ពីរ រឺបីដង។ បើខ្វះខាតត្រូវនិយាយជំរាបម្ចាស់ផ្ទះជាមុន កុំគេចវេះពួនទៅនៅឯណា ។ រីឯម្ចាស់ផ្ទះក៏ត្រូវមានសីលធម៌គ្រប់គ្រាន់កុំអាងខ្លួនថាជាអ្នកមាន ។

❁ ❁ ❁ ❁



Facebook : Entertainment And Knowledge

www.facebook.com/7khmer


# សំលៀកបំពាក់និងការតែងខ្លួន

គ្មាននរណាមួយហ៊ានសួរយើងថា "តើអ្នកចេះស្លៀកពាក់ទេ?" ឡើយ។ តាមពិតនរណាក៏ចេះស្លៀកពាក់ដែរ គឺចេះតាំងពីតូចមកម្ល៉េះ ប៉ុន្តែអ្នកដែលសួរខាងលើនេះ ពិតជាមានបំណងចង់ដឹងដល់របៀបរៀប ចំស្លៀកពាក់អោយសមរម្យគួរជាទីពិតពិលរមិលមើលរបស់អ្នកផង។

**ការនៅលេងជាភ្ញៀវ**

ត្រូវស្លៀកសំលៀកបំពាក់ក្រុង ៖

- បើពេលព្រឹក ស្ត្រីត្រូវពាក់អាវបើកទំនើប ហើយពាក់អាវមានដៃទំលាក់បន្តិចផង ពណ៌សំពត់ និងអាវកុំរើសឆើតពេក។

- ពេលរសៀល ពាក់អាវករៀល ពណ៌ឆើតជាងសំពត់ ពាក់គ្រឿងអលង្ការតាមការគួរសម បើស្លៀកសំពត់ហូល ត្រូវពាក់អាវពណ៌ដែលឥតផ្កា។

- នារីក្រមុំមិនត្រូវស្លៀកសំពត់ខ្មៅទេ ត្រូវរើសពណ៌សំពត់អោយសមតាមពណ៌សប្បុរស្បែករបស់ខ្លួន ហើយអាវក៏ពាក់អោយសមនឹងពណ៌សំពត់ដែរ ។

- បុរសត្រូវពាក់អាវពណ៌សដៃវែង បិទឡេវដៃ និងឡេវកអាវធំ ចងក្រវ៉ាត់ តាមការសមរម្យ ។ កុំមូរដៃអាវ រឺជើងខោស្បែកជើងតាមពណ៌និយម ។

**កំណត់សំគាល់ ៖**

ការទៅលេងផ្ទះគេក្នុងឋានៈជាភ្ញៀវនេះ ម្ចាស់ផ្ទះមិនបង្ខំអោយយើងស្លៀកពាក់យ៉ាងណាៗឡើយ មានតែយើងជាភ្ញៀវប៉ុណ្ណោះដែលគួរអោយកិត្តិយសដល់ម្ចាស់ផ្ទះ។ បើយើងស្លៀកពាក់គឃា ខ្វេចខ្វីផ្ទត់រាប់ពាន់ឡើងផ្ទះគេ ម្ចាស់ផ្ទះគេក៏មានការជិនឆ្អន់ចំពោះយើងដែរ ។

អ្នកនាងជាស្ត្រីមានឥរិយាសមសួន គួរចេះរើសសំលៀកបំពាក់អោយបានថ្លៃថ្នូរផង។ គឺថាបើអ្នកនាងស្លៀកសំពត់ពណ៌ខៀវត្រូវពាក់អាវពណ៌ខៀវខ្ចីអាវស បើពាក់ បើពាក់អាវផ្កាស្រស់ ត្រូវរកពណ៌ផ្កាដែលមានសាច់ពណ៌ខៀវ


Facebook : Entertainment And Knowledge

បើស្លៀកសំពត់ពណ៌ស្វាយចាស់ត្រូវរកអាវពណ៌លឿងខ្ចី ពណ៌ស្វាយខ្ចី។ សំពត់ពណ៌បៃតងត្រូវពាក់អាវស៊ីលាប ពណ៌បៃតងខ្ចី ត្រួយចេកខ្ចី។ សំពត់ពណ៌ក្រហមឈាមជ្រូក ត្រូវពាក់អាវលឿងស្រគាំ ពណ៌កូលាប ក្រហមព្រឿង។ ឯសំពត់ពណ៌ខ្មៅ អាចពាក់ជាមួយអាវគ្រប់ពណ៌ ដូចជាអាវពណ៌សដែលអាចពាក់ជាមួយសំពត់គ្រប់ពណ៌នោះដែរ។ សំលៀកបំពាក់ដែលពាក់ទៅលើកផ្ទះគេក្នុងឋានៈជាភ្ញៀវពេលល្ងាចនេះ អាចពាក់ទៅទស្សនាខ្សែភាពយន្តពេលល្ងាចបានដែរ ។

**ការនៅក្នុងពិធីជប់លៀងតោជនាហារពេលល្ងាច** (Dinner labille)

ស្ត្រីត្រូវពាក់អាវកវាលធំ ដៃតូច គឺត្រូវស្លៀកពាក់អោយឆើតជាងពេលរសៀល លាបម្សៅ ក្រែមមាត់ គូសបកភ្នែក ចិញ្ចើមអោយច្រើនជាងពេលរសៀល ឯគ្រឿងអលង្ការក៏ត្រូវពាក់លើកសំរស់ដែរ។ សក់ត្រូវលើកអោយសមនឹងទំហំមុខ ហើយតាមសម័យនិយមផង។

បុរសត្រូវស្លៀកពាក់របៀបអាវធំ មួយប្រដាប់ពណ៌ក្រម៉ៅ(Complet somber) ពាក់ស្បែកជើងខ្មៅ ចងក្រវ៉ាត់បូ(Naud) ។

**ការនៅជប់លៀងជាឱឡារិក ពិធីមហោស្រព រឺពិធីសមោសរ** (Dinner ou soiree de gala)

អ្នកនាង ត្រូវស្លៀកពាក់សំពត់អាវដែលត្បាញដោយដៃជាតិអំបោះ ហើយកាត់តាមសម័យទំនើប ដូចជាសំពត់ខ្សែសយកំណាត់មានពណ៌ភ្លឺ រឺសំពត់អាវមានពណ៌ប្រហាក់ប្រហែលគ្នា។ កអាវវាលអោយធំ ខ្សែស្មាអាវតូចៗ សំពត់ជាមួងគ្រប់ពណ៌ត្រូវសៀករបៀបវែងដល់កែងជើង បើអ្នកនាងចង់បង់ប្រមាលំអ អ្នកនាងត្រូវរើសក្រមាខ្សែសយដែលមានពណ៌ ប្រហាក់ប្រហែលនឹងសំពត់-អាវ តែគេមិនត្រូវបង់ក្រមាដូចបង់ព័ទ្ធក្រវាត់ពានាសំរាប់សំពះព្រះសង្ឃសូត្រធមតក្នុងពិធីបុណ្យទេ គឺគ្រាន់តែបង់ពីខាងក្រោយទំលាក់ផាយខ្សែសយមកខាងមុខទាំងសងខាង រឺបង់លើស្មាទំលាក់ទៅខាងក្រោយមួយចំហៀង ហើយជាយកន្សែងខ្សែសយមួយចំហៀងទៀតទំលាក់មកខាងមុខ។

នៅក្នុងពិធីដ៏ឱឡារិកនេះ អ្នកនាងត្រូវលាបម្សៅ ថ្ពាល់ មុខ បបូរមាត់

www.facebook.com/7khmer


ត្របកភ្នែក កន្ទុយភ្នែក និងចិញ្ចើមជាងការកំសាន្តនៅពេលណាទាំងអស់ សក់ត្រូវធ្វើអោយសមរម្យ ស្អាតទាន់សម័យទំនើប ពាក់គ្រឿងអលង្ការ មាស ពេជ្រតាមសមត្ថភាពគ្រួសារលាបទឹកអប់សំរាប់ពេលរាត្រី ស្បែកជើងកែងកំនើច ។

បុរសពាក់សំលៀកបំពាក់ក្រវាត់ពណ៌ស រឺពណ៌សមរម្យស្បែកជើងខ្មៅលាបរំរែនីរលោង ស្រោមជើងពណ៌ខ្មៅ ។

**ការលៀងស្រា** (Cocktan)

ពិធីនេះ តែងទទួលភ្ញៀវពីចន្លោះវេលាម៉ោង១៨ និងម៉ោង២២។ ទោះបីការចាត់ចែងនេះ បានប្រព្រឹត្តទៅប្រកបដោយបរិយាកាសសប្បាយរីករាយយ៉ាងណាក៏ដោយ ក៏គេមិនត្រូវបង្ហួសរហូតដល់ម៉ោង២ រឺម៉ោង៣ភ្លឺដែរ ភ្ញៀវគប្បីទៅជំរាបសួរគួរសមចំពោះអ្នកចាត់ចែងពិធី (Cocktan) កុកតែនេះ។ យើងជាភ្ញៀវត្រូវរកគ្នីគ្នា ដែលស្គាល់គ្រាន់នឹងបានពីរនាក់ រឺច្រើននាក់នៅក្នុងចំណោមភ្ញៀវដែលគេអញ្ជើញ ដើម្បីនាំគ្នាទៅកាន់តុដាក់ម្ហូប និងស្រា។ ភ្ញៀវមិនត្រូវឈរសំកុកនៅខាងមុខតុនេះអោយយូរទេ គេត្រូវដើរមករួបរួមជាមួយភ្ញៀវដទៃទៀតដោយមិត្តភាព។ យើងជាភ្ញៀវត្រូវចេះយល់ដល់ចិត្តភ្ញៀវដទៃទៀត និងយល់ចិត្តម្ចាស់ផ្ទះ យើងមិនត្រូវឈរជជែកតែជាមួយម្ចាស់ផ្ទះ រឺអ្នករៀបចំពិធីបដិសណ្ឋារកិច្ចអោយជាប់មាត់ ព្រោកប្រាជ្ញតែម្នាក់ឯងដោយមិនទុកពេលអោយភ្ញៀវដទៃទៀតមកគួរសមផងនោះទេ។

កាលបើយើងអញ្ជើញភ្ញៀវអោយលើសពី៣០នាក់យើងគួរ ចាត់ចែងអោយអ្នកលក់អាហារ រៀបចំពិធីនេះជំនួសយើងព្រោះអ្នកលក់អាចផ្តល់ប្រដាប់ប្រដាប្រើប្រាស់ និងអ្នកកំដរគ្រប់គ្រាន់។ បើភ្ញៀវដែលយើងអញ្ជើញមានចំនួនច្រើន អ្នកចាត់ចែងត្រូវរៀបតុដាក់ម្ហូប និងស្រាយអោយបានពីរ រឺបី។ ភារៈដែលត្រូវគិតជាងគេគឺអ្នកចាត់តែងត្រូវនឹងគិតដល់ចំនួនភ្ញៀវនិង ចំនួនស្រាព្រមទាំងចំនួនម្ហូបក្លែម ។

នៅពេលបានមករួបរួមអស់មួយម៉ោង ភ្ញៀវអាចសុំលាម្ចាស់ផ្ទះរឺអ្នករៀបចំពិធីបដិសណ្ឋារកិច្ចនេះ ដោយថ្លែងអំណរគុណផង។

នៅលើតុក្នុងពិធីលៀវកុកតែនេះ អ្នករៀបចំត្រូវដាក់ស្រាសម្ប៉ាញ រឺស្គី


Facebook : Entertainment And Knowledge

www.facebook.com/7khmer


ភេសជ្ជៈមានជាតិឧស្ម័ន(Gaz) ដូចជាទឹកក្រូចប៊ិបស៊ី កូឡា កូកាកូឡា មិរិនដា បេសេអ៊ី ហៅឌី វិតា សេវេនអិប រឺភេសជ្ជៈនៃទឹកផ្លែឈើដូចជាតុបមូកាស៊ីត្រុង ទឹកស៊ីរ៉ូ ។ល។ នំនែកនំប៉័ងអាំងផ្ទាប់សាច់សង់វិច (Sandwichea) ។ល។ ចំណីទាំងនេះត្រូវមានម្ហូបប្រៃច្រើនជាងបង្អែម។ ចំណែកបារី និងប្រដាប់កំទេចបារីនោះ ក៏ត្រូវដាក់សំរាប់ទទួលភ្ញៀវដែរ។

**ការប្រជុំគ្នារាំលេង**

នៅប្រទេសយើងសព្វថ្ងៃនេះ គេសង្កេតឃើញមានយុវជនខ្លះចូលចិត្តប្រជុំគ្នារាំលេងកំសាន្តជាមិត្តភាព។

ការអញ្ជើញភ្ញៀវយុវជនដូចគ្នា អាចអញ្ជើញបានដោយផ្ទាល់មាត់ រឺដោយនិយាយទូរស័ព្ទហៅប្រជុំគ្នា។ បើការប្រជុំនេះធ្វើឡើងដោយស្មោះត្រង់គឺមិនបាច់គួរសមច្រើនពេក មិត្តនារីត្រូវរៃគ្នាទិញនំនែក រីឯយុវមិត្តត្រូវទិញគ្រឿងភេសជ្ជៈ ដោយហេតុថាការប្រជុំគ្នាបៀបនេះមានពេលរាំលេងយប់យូរគេអាចបំរុងភេសជ្ជៈនិងចំណីចំណុកកុំអោយខ្វះនៅពេលយប់យូរ រឺអធ្រាត្រនោះ។ បើការប្រជុំគ្នានេះធ្វើនៅជាន់ខាងលើ យើងគប្បីសុំសេចក្ដីអនុគ្រោះពិអ្នកដែលសំណាក់នៅពីក្រោមផ្ទះ ប៉ុន្តែបើកន្លែងប្រជុំគ្នានេះជាផ្ទះរបស់យើងផ្ទាល់ យើងគប្បីបិទបង្អួចអោយតូច ហើយបិទសំលេងម៉ាស៊ីនថតសំលេងដែលយើងបើកចំហនោះអោយបានតូច នៅពេលដែលអធ្រាត្របានឈានចូលមក។

**រាត្រីរាំលេង**

គេតែងអញ្ជើញភ្ញៀវអោយមកប្រូបរួមពីម៉ោង ៨.៣០នាទី រឺម៉ោង ៩ ទៅ ពិធីនេះមានសភាពឱឡារិកជាងការប្រជុំគ្នារាំលេងពីខាងលើ។ អ្នកចាប់ផ្ដើមរៀបចំពិធីរាំលេងកំសាន្តពេលរាត្រីនេះត្រូវអញ្ជើញភ្ញៀវអោយមកប្រូបរួម ដោយការជូនសំបុត្រអញ្ជើញ។

សំបុត្រអញ្ជើញនេះ អាចសរសេរដោយសរសេរអក្សរឆ្លាក់ពុម្ព អក្សរពណ៌ផ្សេងៗ តាមការស្រឡាញ់ តែគេសរសេរលើក្រដាស់ដែលមានពណ៌ស រឺពណ៌ផ្សេងៗតាមការនិយមលើកលែងតែពណ៌កូលាប។ អ្នករៀបចំត្រូវលៃរកបន្ទប់រាំលេងអោយធំល្មម កុំអោយចង្អៀតពេកបើមាន (Orchestere vivant)


Facebook : Entertainment And Knowledge

www.facebook.com/7khmer


ក្រុមតន្ត្រីករទៅរួបរួមជាមួយផងនោះ គេត្រូវលៃរកកន្លែងសមគួរសំរាប់ក្រុមនេះ។ គ្រឿងភ្លីផ្កាដែលត្រូវការរៀបចំ ក៏ត្រូវលៃអោយស្អាតរៀបរយ។ ឯការរៀបចំលើតុសំរាប់អោយភ្ញៀវញុំាលេងកំសាន្ត មានរបៀបប្រហាក់ប្រហែល នឹងការរៀបចំក្នុងពិធីកុកតៃ(Cocktan)។

បើយើងជាអ្នកទៅរួបរួមយកមិត្តនារី រឺអ្នករាំរបស់ខ្លួនទៅជាមួយផង យើងត្រូវជំរាបដល់អ្នករៀបចំពិធីនេះ។

ការរៀបចំរាត្រីរាំលេងនេះ ច្រើនធ្វើឡើងនៅឱកាសបុណ្យខួបរបស់នរណាម្នាក់ ពិធីភ្ជាប់ពាក្យ រឺក៏ពិធីរាប់អានគ្នាដ៏ថ្លៃថ្នូរណាមួយ។

**ការលៀបសាយភោជន៍របៀបឈរ**

សព្វថ្ងៃនេះមានបដិសណ្ឋារកិច្ចខ្លះ ចាត់តែងលៀងសោយភោជន៍របៀបឈរ ពិធីនេះគេតែងចាត់ចែងទទួលភ្ញៀវនៅពេលយប់ជ្រៅពីម៉ោង២១ រឺម៉ោង២២ទៅ។ តាមធម្មតានៅវេលាម៉ោង២២ស្ត្រីម្ចាស់ផ្ទះអញ្ជើញនាំមុខភ្ញៀវទៅកាន់តុដាក់ម្ហូបអាហារ ដែលនៅទីនោះម្នាក់ៗកាន់ចានមួយម្នាក់ និងសមស្លាបព្រា ហើយដួសម្ហូបអាហារដោយខ្លួនឯង។

នៅពេលចាប់ម្ហូបអាហារនោះ យើងជាភ្ញៀវត្រូវចាប់យកដោយឆាប់ល្មម កុំយកយូរពេកនាំរំខានដល់គេ ហើយកុំរហ័សពេកក្រែងមានការកំពប់ខ្ទាត់ខ្ទាយ។

គេមិនត្រូវយកចានមួយមករកកៀនដាច់តែឯងទេ គេត្រូវនៅរួមសប្បាយរីករាយជាមួយគ្នាទាំងអស់។

**ការលៀបភោជនាហារថ្ងៃត្រង់ និងការលៀងសាយភោជន៍ធម្មតា**

ភ្ញៀវដែលគេអញ្ជើញគប្បីមកអោយទាន់ពេល ការមកដល់ក្រោយគេកន្លះម៉ោង ជាការគួរអោយខ្មាសអៀន បើមានការជាប់រវល់រឿងអ្វីមួយយើងគប្បីនិយាយទូរស័ព្ទទៅជំរាបអ្នករៀបចំដោយសុំអភ័យទោសពីគេ ។ ម្ចាស់ផ្ទះត្រូវចាត់ចែងរៀបចំអោយភ្ញៀវពិសារតាំងពីពេលដែលភ្ញៀវម្នាក់មកដល់មុនគេ បើភ្ញៀវសុំអោយរង់ចាំគ្នីគ្នាក្រោយទៀត សឹមម្ចាស់ផ្ទះរង់ចាំ ។ នៅលើតុនីមួយៗមានរៀបចាន ស្លាបព្រាតាមរបៀប (ទំព័រទី៣៩) ត្រីចៀនធំៗ ត្រូវដាក់ក្នុង


Facebook : Entertainment And Knowledge

www.facebook.com/7khmer



ចានធំវែង ដែលដាក់បានគួរសមល្មមដាក់បន្លែតិចៗដូចជាប៉េងប៉ោះ ចិតចំណិតតូចៗពីលើមើលទៅគួរអោយឃ្លាន។

សាច់រ៉ូទីដូចជាមាន់ ទា រឺសាច់កូនជ្រូករ៉ូទី ត្រូវដាក់ក្នុងចានធំរឺក្នុងថាសមួយល្មម ការរៀបបន្លែតាក់តែងចាន រឺថាសនេះស្រេចលើការចូលចិត្តរបស់ស្ត្រីម្ចាស់ផ្ទះ បន្លែសំរាប់ញ៉ាំនឹងទឹកគ្រឿង ត្រូវដាក់ក្នុងចានមូលវែងមួយជិតសាច់ ឯទឹកគ្រឿងត្រូវដាក់ក្នុងកូនចានតូចៗល្មម ហើយលៃតាមការគួរសមអោយភ្ញៀវ ។ សម្លឆ្នាំងក្តៅដែលគេចូលចិត្តប្រើដើម្បីធ្វើអោយសម្លនៅក្តៅដែលនោះគេត្រូវដាក់ចំកណ្តាលតុ។ បើសម្លមានជាតិជូរហើយ ត្រូវកុំយកឆា រឺញ៉ាំអ្វីដែលមានជាតិជូរមកថែមទៀត។

សាឡាត់ និងទឹកគ្រឿង ត្រូវដាក់ពីខាងស្តាំដៃរបស់ភ្ញៀវរបៀបរៀបភ្ញៀវអង្គុយនៅជុំវិញតុមានដូចខាងក្រោមនេះ ៖

ស្ត្រីម្ចាស់ផ្ទះនាំភ្ញៀវទៅរកកន្លែងអង្គុយ។ បុរសម្ចាស់ផ្ទះត្រូវអង្គុយនៅទល់មុខនឹងភរិយារបស់ខ្លួន គឺនៅចំកណ្តាលជាយតុបើ តុជ្រុងត្រូវអង្គុយនៅទល់មុខគ្នាចុងម្ខាងម្នាក់ ។

បើបុរសម្ចាស់ផ្ទះមិននៅ ស្ត្រីម្ចាស់ផ្ទះអាចអោយកូនប្រុសរឺកូនប្រសារប្រុស រឺភ្ញៀវកិត្តិយសអង្គុយនៅទល់មុខ បើស្ត្រីម្ចាស់ផ្ទះមិននៅក៏មានរបៀបដូចគ្នានេះដែរ។ ម្ចាស់ផ្ទះអាចនឹងជូនកន្លែងរបស់ខ្លួនដល់នរណាម្នាក់ដែលខ្លួនគោរពជាងគេ ដូចជាប្រមុខរដ្ឋព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ជាដើម ។

ស្ត្រីម្ចាស់ផ្ទះត្រូវអញ្ជើញបុរសជាកិត្តិយសធំ អោយអង្គុយពីខាងស្តាំហើយបន្ទាប់មកភ្ញៀវឋានៈបន្ទាប់នៅខាងឆ្វេង ។ បន្ទាប់ពីនោះបើតុរៀបចំនោះធំល្មមដាក់បាន គេនឹងរៀបបុរសនិងស្ត្រីឆ្លាស់គ្នា។ គេមិនដែលបំបែកគូសាមីភរិយាដែលទើបនឹងរៀបការបានមួយឆ្នាំ រឺគូដណ្តឹងអោយបែកពីគ្នានៅពេលរួមការលៀងភោជនាហារនេះទេ។

បើពិធីបដិសណ្ឋារកិច្ច ក្នុងការលៀងភោជនហារនេះមានច្រើនតុ តុដែលមានម្ចាស់ផ្ទះជាអ្នកចាត់ចែងនេះ ត្រូវរៀបនៅចំកណ្តាលតុនានា រឺជួនកាលគេរៀបស្ត្រីម្ចាស់ផ្ទះនៅតុមួយហើយបុរសម្ចាស់ផ្ទះតុមួយទៀត។



Facebook : Entertainment And Knowledge

www.facebook.com/7khmer


តាមការគួរសមគេតែងដាក់ភ្ញៀវ ៧ រឺ ៨ នាក់ក្នុងមួយតុតូចល្មម។ ឯរបៀបបំរើភ្ញៀវមានដូចខាងក្រោមនេះ ៖

ត្រូវបំរើតាមលំដាប់តាមឋានន្តរសក្តិ និងតាមអាយុរបស់ភ្ញៀវ។ ដំបូងត្រូវបំរើដាក់ទឹកកក ភេសជ្ជៈជាដើម ចំពោះស្ត្រីភេទតរៀងមក ស្ត្រីម្ចាស់ផ្ទះក្រោយគេ បើស្ត្រីម្ចាស់ផ្ទះនេះមានបុត្រី រឺក្មួយស្រី ថៅស្រី។ល។ ត្រូវបំរើម្ចាស់ផ្ទះនេះមុនអ្នកនាងទាំងនោះបន្ទាប់ពីបំរើស្ត្រីមក គេបំរើបុរសជាភ្ញៀវរហូតដល់បុរសជាម្ចាស់ផ្ទះក្រោយគេបំផុត ។

មុននឹងដាក់បង្អែមជូនភ្ញៀវ គេត្រូវបោសតុតិចៗ រឺរៀបចំលើតុអោយស្រួលបួល តែគេមិនត្រូវយកអីវ៉ាន់ទាំងអស់ចេញទេគេទុកកែវស្រា-ភេសជ្ជៈនៅលើនេះសិន ។

លុះភ្ញៀវពិសាររួចហើយ ស្ត្រីម្ចាស់ផ្ទះត្រូវអោយសញ្ញាដល់ភ្ញៀវដោយក្រោកឈរ ហើយនាំមុខភ្ញៀវដើរតម្រង់ទៅបន្ទប់ទទួលភ្ញៀវ។

❁ ❁ ❁ ❁


Facebook : Entertainment And Knowledge

# របៀបសរសេរសំបុត្រ

ក្រដាសដែលគេត្រូវរើសយកមកសរសេរ ត្រូវរើសពណ៌ថ្លាល្អ គឺពណ៌ស ខៀវ លឿង និងពណ៌កូលាប ។ល។ ក្រដាសប្រើបានគ្រប់កាលៈទេសៈ ក្រដាសខៀវត្រូវសរសេរសំរាប់វ័យនៅក្មេងហើយផ្ញើទៅកាន់មិត្តភក្តិ ទាក់ទងធម្មតា។ ក្រដាសលឿងសរសេរទៅជូនអ្នកមានគុណ និងអ្នកគួរគោរពដោយស្និទ្ធស្នាល។ ក្រដាសពណ៌កូលាបគេប្រើសំរាប់ទាក់ទងខាងផ្លូវស្នេហា រវាងបុរស និងស្ត្រីមិត្តប្រុស រឺមិត្តនារីមិនត្រូវប្រើក្រដាសពណ៌កូលាបនេះ សំរាប់ទាក់ទងជាផ្លូវមិត្តភាពទេ។ ផ្ញើសំបុត្រតាមយន្តហោះ គេត្រូវប្រើកដាសស្តើងពិសេសសំរាប់យន្តហោះ ។ អ្នកសរសេរសំបុត្រត្រូវកាត់ក្រដាសអោយបានរៀបរយ។ កុំហែកក្រដាសអោយតែរួចពីដៃ ហើយបណ្តោយអោយមានស្នាមឆកឆែកគ្រប់អន្លើអោយសោះ។ ក្រដាសដែលសំរាប់សរសេរត្រូវអោយមានភាពរលីង កុំអោយខ្ទេចខ្ទីដូចគេធ្លាប់ក្រញីម្តងហើយអោយសោះ។ គេមិនត្រូវសរសេរសំបុត្រដោយប៊ិច រឺទឹកពណ៌ក្រហម បៃតងទេ គេត្រូវសរសេរដោយស្លាបប៉ាកាហើយសរសេរដោយទឹកខ្មៅ ។

ថ្ងៃ ខែ ត្រូវសរសេរនៅខាងលើទំព័រសំបុត្រកៀនខាងស្តាំ។ ត្រូវចោលក្រដាសមួយចន្លោះល្មមនៅផ្នែកខាងឆ្វេងដើម្បីទុកអោយអ្នកអានកាន់ មើលហើយថាការល្អមើលម្យ៉ាងផង។

កាលបើសរសេរចប់មួយវគ្គ ត្រូវចុះបន្ទាត់ហើយខ័ណ្ឌសេចក្តីអោយស្រួលស្តាប់។ សំបុត្រនីមួយៗមិនត្រូវសរសេរដោយសង្កត់ពាក្យភ្ជាប់ជាមួយនឹងនឹងសញ្ញា (!) និងសញ្ញា (?) … ច្រើនទេ។

បើអ្នកនាងចង់សង្កត់ពាក្យអ្វីមួយ អោយអ្នកអានស្តាប់ឆាប់យល់តាមបំណងអ្នកនាង សូមសរសេរអោយច្បាស់ហើយកុំគូសពីខាងក្រោមអក្សរអោយមានគំនូសពីរ រឺបីបន្ទាត់។ ពាក្យណាមិនយល់ច្បាស់ត្រូវមើលវចនានុក្រមអោយច្បាស់កុំស្មានអោយសោះ ។

www.facebook.com/7khmer


ត្រូវសរសេរអោយច្បាស់អោយអ្នកអានយល់តាមសេចក្តីផង។ សរសេររួច ត្រូវចុះហត្ថលេខាអោយច្បាស់ប្រាប់ឈ្មោះរបស់ខ្លួនពិតប្រាកដ។

កើតមកជាជាតិខ្មែរត្រូវសរសេរអក្សរខ្មែរ និយាយគ្នាជាខ្មែរ ការនិយាយរឺសរសេរភាសាបរទេសមិនមែនជាភាពខែងអ្វីទេ។

សរសេរសំបុត្ររួចត្រូវបត់អោយស្អាតជាពីរផ្នត់ រឺជាបួនផ្នត់ដាក់ក្នុងស្រោមអោយបានស្អាតល្អ។ នៅប្រទេសបារាំងគេនិយមចុះហត្ថលេខា រឺដាក់នាមខ្លួន និងគោត្តនាមថែមទៀត ស្ត្រីដែលមានប្តីហើយ ចុះហត្ថលេខាអក្សរដើមនៃគោត្តនាមរបស់ខ្លួន និងនាមរបស់បុរសជាប្តី។ ប៉ុន្តែមានអ្នកខ្លះគេចុះឈ្មោះគេ និឈ្មោះបុរសជាស្វាមីដែរ គឺគេមិនសរសេរគោត្តនាមគេ និងស្វាមីគេទេ ។

នារីក្រមុំ និងស្ត្រីមេម៉ាយត្រូវសរសេរគោត្តនាម និងនាមខ្លួនទាំងអស់។ បើអ្នកទទួលសំបុត្រ សំណាក់នៅផ្ទះរបស់អ្នកដទៃគេត្រូវសរសេរឈ្មោះអ្នកទទួលនោះ ហើយដាក់ថានៅផ្ទះឈ្មោះ...។ បារាំងគេសរសេរថា (Aux bons soins de) រឺ (Chez) ... រឺសរសេរ C/O ជាពាក្យកាត់របស់អង់គ្លេសដែលមានន័យថា Care of... ។ សរសេររួចគេយកទៅដាក់ប្រៃសណីយ៍ ។

ប្រសិនបើសំបុត្រនោះត្រូវបញ្ជូនដល់ដៃផ្ទាល់ខ្លួន ដល់ទីកន្លែងអ្នកទទួលគេដាក់ថា (E.V) បានសេចក្តីថានៅទីក្រុង (Envillo) ។

**របៀបបិទតែមប្រ៍**

តែមប្រ៍គេបិទនៅខាងស្តាំ ខាងលើ នៅខាងមុខ។ គេមិនត្រូវបិទនៅខាងក្រោម រឺនៅខាងក្រោយខ្នងសំបុត្រទេ។

អ្នកសរសេរសំបុត្រសរសេរឈ្មោះខ្លួន និងអាស័យដ្ឋានអោយបានច្បាស់លាស់ ព្រមទាំងឈ្មោះ និងអាស័យដ្ឋានអកទទួលអោយបានច្បាស់លាស់ផងដែរ ដើម្បីងាយយល់ដល់អ្នកបញ្ជូនសំបុត្រ។

ផ្ញើសំបុត្រតាមប្រៃសណីយ៍ដោយមិនបិទតែមប្រ៍ ជាអំពើឈ្លើយគ្មានសណ្តាប់ធ្នាប់អ្វីសោះ។

ការផ្ញើរបៀបនេះ នាំអោយអ្នកទទួលសង់ពិន័យប្រៃសណីយ៍ដោយក្តៅ


Facebook : Entertainment And Knowledge

www.facebook.com/7khmer


ក្រហាយឥតគណនា ។

មនុស្សត្រឹមត្រូវមានការចេះដឹង មានលក្ខណៈជាមនុស្សពេញច្បាប់ខុសពីសញ្ញាតិសត្វធាតុ គេត្រូវប្រាប់ឈ្មោះគេពិតប្រាកដដល់អ្នកទទួលសំបុត្រ ។ សំបុត្រអនាមិក ជាសំបុត្រដែលប្រសូតចេញពីគំនិតរបស់មនុស្សកំសាក។

❁ ❁ ❁ ❁


Facebook : Entertainment  And Knowledge

www.facebook.com/7khmer


# អំពីប័ណ្ណអញ្ជើញ

ប័ណ្ណអញ្ជើញភ្ញៀវមកកំសាន្ត រឺមកជប់លៀងភេសជ្ជៈ រឺភោជនាហារផ្សេងៗ គេត្រូវនិយាយពាក្យខ្លះៗ ហើយគួរសមប្រាប់ពេលវេលាដែលអញ្ជើញអោយមក និងលេខផ្ទះ រឺទីកកន្លែងដែលអញ្ជើញទៅនោះអោយបានច្បាស់លាស់។ បើអញ្ជើញក្នុងពិធីកិត្តិយសក៏ដូចជាជប់លៀងក្នុងឱកាសរៀបអាពាហ៍ពិពាហ៍ជាដើម គេអាចសរសេរអក្សរពុម្ពស្អាតៗ រឺអក្សរក្បាច់ផងក៏បាន។

ប័ណ្ណជូនពរសព្វសាធុការ ក៏គួររចនាអោយមានភាពសង្ហារគួរជាទីរីករាយដល់អ្នកបានទទួល ។

ការចារស្រោមសំបុត្រដាក់ប័ណ្ណ គេនិយមតាមរបៀបដូចខាងក្រោមនេះ

បើអ្នកផ្ញើជាបុរសនៅលីវ រឺមានប្រពន្ធហើយគេត្រូវដាក់នាម និងគោត្តនាម និលេខទូរស័ព្ទ ។

បើអ្នកផ្ញើជាស្ត្រីមានប្តីហើយ គេត្រូវដាក់នាម និងគោត្តនាមរបស់ប្តីហើយដាក់ឋានៈស្ត្រីនោះនៅពីខាងមុខ ដូចជាលោកជំទាវ ក ខ លោកស្រី គ ឃ រឺ អ្នកស្រី ង ច ជាដើម គេមិនចាំបាច់ដាក់អាស័យដ្ឋាន រឺលេខទូរស័ព្ទទេ។

បើអ្នកផ្ញើជានារីក្រមុំ គេដាក់តែនាម និងគោត្តតាមប៉ុននោះ មិនចាំបាច់ដាក់ "កញ្ញា" ក ខ ទេ ហើយលេខទូរស័ព្ទ និងអាស័យដ្ឋានក៏មិនបាច់ដាក់ដែរ។

បើស្ត្រីជាអ្នកធ្វើការរាជការ គេអាចដាក់អាស័យដ្ឋាននិងលេខទូរស័ព្ទបាន។ ឯស្ត្រីមេម៉ាយ ក៏មិនបាច់បញ្ជាក់នៅលើស្រោមសំបុត្រថាជាស្រីមេម៉ាយដែរ ។

បើអ្នកផ្ញើជាប្តីប្រពន្ធពីរនាក់ គេអាចដាក់នាម និងគោត្តនាមលោកប្រុសហើយសរសេរថា លោក និងលោកស្រី...។ ក្នុងករណីនេះគេអាចដាក់អាស័យដ្ឋាន និងលេខទូរស័ព្ទភ្ជាប់ជាមួយផងដែរ ។

**អំពីប័ណ្ណប្រៃសណីយ៍** (Cartes postales)

ប័ណ្ណរបៀបនេះគេអាចមើលបានគ្រប់គ្នា ហេតុនេះគេមិនសរសេរការ


Facebook : Entertainment And Knowledge

www.facebook.com/7khmer


អាចកំបាំងអ្វីមួយឡើយ គេនិយាយតែអំពីអ្វីដែលមានសភាពទូទៅធម្មតា។ បើផ្ញើប័ណ្ណប្រៃសណីយ៍ទៅជូនមនុស្សដែលមានវ័យចាស់ រឺជាមនុស្សដែលគួរគោរពគេត្រូវដាក់ក្នុងស្រោមសំបុត្រ ។

**អំពីទូរលេខ**

គេទាក់ទងគ្នាតាមទូរលេខ នៅពេលដែលមានដំណឹងប្រញាប់ដូចជាពិធីរៀបអាពាហ៍ពិពាហ៍ បុណ្យខួប ហៅទៅចូលរួបរួមក្នុងពិធីអ្វីមួយជាប្រញាប់ រឺទទួលដំណឹងមរណភាព នៃបុគ្គលនាម្នាក់។ នៅក្នុងទូរលេខគេសរសេរអក្សរកាត់ៗខ្លីៗល្មមស្តាប់បាន។ គេមិនបញ្ជូនទូរលេខទៅអោយមនុស្សដែលមានជំងឺខ្សោយបេះដូងខ្លាំងនោះទេ។

**ទូរស័ព្ទ**

បើប្រើទូរស័ព្ទ ត្រូវមានសុជីវធម៌ក្នុងខ្លួនអោយគ្រប់គ្រាន់អ្នកមានចរិយាជាអ្នកមានពូជ គេមិនប្រើទូរស័ព្ទសំរាប់បិទមុខ ហើយបញ្ចេញសំលេងនោះទេ គេប្រើតាមគុណភាពដែលបានមកពីការលូតលាស់នៃវិទ្យាសាស្ត្រ។ សំលេងរោទ៍របស់ទូរស័ព្ទញឹកញយ ធ្វើអោយមានការតានតឹងចិត្តជាងស្នូរគោះទ្វារទៅទៀត។ គេមិនត្រូវនិយាយទូរស័ព្ទទៅរុកគួនអ្នកដទៃនៅវេលាម៉ោង១១យប់ទេ ។

ដើម្បីជាការគួរសម គេមិននិយាយទូរស័ព្ទទៅអ្នកណានៅពេលមុនម៉ោង៩ព្រឹក ហើយក្រោយម៉ោង១១យប់ទេ។ នៅពេលដែលគេនិយមបរិភោគអាហារ យើងមិនត្រូវទូរស័ព្ទទៅរំខានគេទេបើមានការចាំបាច់ខ្លាំងទុកមិនបានគេត្រូវនិយាយសុំទោសអោយអ្នកនៅម្ខាងទៀតនោះអនុគ្រោះ ។

នៅពេលដែលគេសួរចំឈ្មោះយើងជាអ្នកសុំគេ យើងត្រូវមានសេចក្តីក្លាហាននឹងប្រាប់ឈ្មោះគេដោយត្រង់ តាមសភាវៈជាមនុស្សសុចរិត ។

នៅបន្ទប់ទូរស័ព្ទនៃក្រុមប្រៃសណីយ៍ គេមិនត្រូវនិយាយអោយយូរហួសពេករហូតដល់ជាងកន្លះម៉ោងនោះទេ ។

បើយើងច្រឡំលេខទូរស័ព្ទ យើងប្រញាប់សុំអភ័យទោសគេវិញដោយស្រួល កុំទំលាក់គ្រឿងទូរស័ព្ទដូចជាមនុស្សមិនដឹងអ្វីសោះ។


Facebook : Entertainment And Knowledge

www.facebook.com/7khmer


បើគេច្រឡំលេខទូរស័ព្ទមកត្រង់លេខរបស់យើង  យើងជាម្ចាស់ផ្ទះត្រូវអភ័យទោសអោយគេតាមពាក្យថ្លៃថ្នូរ កុំស្រែកជេរគេតាមតែចិត្តខ្លួនខឹង ហើយនឹកឃើញអោយសោះ។

នៅជិតទូរស័ព្ទ គេត្រូវមានទុកសៀវភៅកត់ហេតុ និងខ្មៅដៃមួយជាដរាបសំរាប់កត់នៅពេលមានគេរាយការណ៍អ្វីមួយដោយប្រញាប់ ។

❁ ❁ ❁ ❁


Facebook : Entertainment  And Knowledge

www.facebook.com/7khmer


# នៅតាមវិថីតូចធំក្នុងក្រុង

ចិញ្ចើមវិថីខាងក្នុងត្រូវទុកអោយស្ត្រី រឺអោយបុរសដែលមានអាយុច្រើន។ បើបុរសចង់ដើរចៀសហ្វូងនារី រឺមនុស្សចាស់គេត្រូវចៀសខាងឆ្វេងដៃដែលមានចន្លោះធំ ។

បើបានជាដើរចៀសរួច ទាំងទើសទាស់ចិត្តដោយប្រការណាមួយ គេគប្បីបន្តដំនើរទៅមុខទៀតដូចធម្មតា មិនត្រូវងាកក្រោយសំលក់សំលឹងប្រកាសសង្គ្រាមប្រស្រីភ្នែក រឺធ្វើមាត់ម្ជួបៗតាមដោយចិត្តនឹកឃើញនោះទេ។ ឯអ្នកដើរខាងមុខគេ បើដឹងថាខ្លួនចង់ដើរតិចៗ គប្បីដើរចូលមកចិញ្ចើមវិថីខាងមុខគេ បើដឹងក្រដីក្រទាមួយជំហានទៅឆ្វេង មួយជំហានទៅស្តាំ កុំដើរជ្រែងកណ្តាលវិថីដែលមានអ្នកដំណើរច្រើន ហើយបោះជំហានមួយៗរង្វើលៗខ្លាំងពេក ។

ចិញ្ចើមវិថីដ៏ចង្អៀតនៅទីក្រុង គេមិនទុកបំរុងតែអ្នកលេងកុនគ្មានអ្នកថតរឺអ្នកលេងល្ខោនក្រៅឆាកដោយដើរដូចរាំនោះទេព្រោះអ្នករកស៊ីចិញ្ចឹម ជីវិតផ្សេងៗទៀត គេត្រូវការចិញ្ចើមវិថីនេះដើម្បីទូល រែក ជាដើមដែរ។

កាលបើឃើញនារីបីនាក់ធ្វើដំណើរមកជិតដល់ លោកជាបុរសមិនត្រូវស្ទុះទៅចាប់ដៃគួរសម និយាយជាប់មាត់ជាមួយមិត្តភក្តិលោកច្រងាងពេញផ្លូវបង្អាក់ដំណើរគេទេ លោកគួរចេះលៃចន្លោះគួរសមជាមួយមិត្តលោក ហើយលៃចន្លោះអោយអ្នកផងដើរបានស្រួល។

បើឃើញមនុស្សមានគ្រោះថ្នាក់នៅតាមវិថី យើងគួរជួយសង្គ្រោះជីវិតគ្នាដោយជូនដំណឹងទៅភ្នាក់ងារប៉ូលិសមានសត្ថកិច្ចភ្លាម។ បើឃើញមានមនុស្សខ្យល់ចាប់ រឺខ្យល់គនៅតាមវិថីនេះលោកអ្នកនាងជាសប្បុរសជន គួរជួយចាប់ស្រង់ជីវិតជនទុកទុគ៌តនេះដោយជួយផ្តល់ប្រេងខ្យល់ រឺថ្នាំសង្កូវផ្សេងៗដែលលោកអ្នកនាងអាចផ្តល់អោយបាន ។

លោកជាបុរសមិនត្រូវនាំគ្នាឈរតំរៀបជាជួរក្បែរចិញ្ចើមវិថីស្រែកឡេឡូ


Facebook : Entertainment And Knowledge

www.facebook.com/7khmer


ជាភាសាជាតិ រឺភាសាបរទេស ដើម្បីទទួលនារីមួយម្នាក់ដែលគ្នាទើបនឹងដើរមក ដល់នោះទេ។ លោកអ្នកនាងមិនគប្បីដើរឆ្លងវិថី ដោយមិនសំលឹងមើលភ្លើងក្រហមពីខាងមុខនោះទេ។ រីឯភ្លើងលឿង ក៏មិនទាន់អនុញ្ញាតអោយអ្នកដំនើរឆ្លងកាត់ដូចភ្លើងពណ៌បៃតងនោះដែរ។ ទោះបីគ្មានអ្វីបើកកាត់ ក៏លោកអ្នកនាងជាអ្នកដំណើរ មិនគប្បីឆ្លងកាត់ដោយមិនទាន់ឃើញភ្លើងពណ៌បៃតងដែរ។

ម្យ៉ាងទៀត ទោះបីមានការប្រញាប់យ៉ាងណាក៏ដោយ ក៏គេមិនត្រូវរត់ឆ្លងកាត់រឹងនៅមុខមុខរថយន្ត រឺយានជំនិះគ្រប់យ៉ាងបណ្តាលអោយអ្នកបើកបរជាន់រឺចាប់ហ្វ្រាំងលាន់កក្រើកធរណីនោះឡើយ កាលបើឆ្លងមិនផុតទេ អ្នកឆ្លងកាត់រួចនោះនឹងបំផ្លាញសេចក្តីសុខរបស់អ្នកបើកបរម្នាក់ រឺច្រើននាក់អោយខូចខាតពេលវេលា ទៅវាយការណ៍ រឺក៏ជាប់ឃុំនៅស្នងការដ្ឋានប៉ូលិស ។

❁ ❁ ❁ ❁


Facebook : Entertainment  And Knowledge

www.facebook.com/7khmer


# នៅតាមផ្លូវថ្នល់

អ្នកបើកបរទាំងឡាយ គួរចេះប្រណីដល់ជីវិតរបស់ខ្លួននិងអ្នកដែលផ្ញើវាសនាទៅលើរថយន្ត រឺយានជំនិះរបស់ខ្លួន ។

អ្នកជិះរថយន្តឈ្នួលនៅបាំងខាងមុខ មិនគប្បីស្តោះទឹកមាត់ក្រៅមាត់ទ្វារ នៅពេលរថយន្តកំពុងបើកទៅមុខទេ ព្រោះខ្យល់នឹងបក់អោយចូលមកប៉ះមុខ រឺចូលមាត់អ្នកនៅខាងក្រោយគេត្រូវស្តោះទឹកមាត់ រឺស្លេស្មដាក់ទៅក្នុងកន្សែងរបស់ខ្លួន ហើយរៀបអោយស្អាតដាក់ក្នុងហោប៉ៅ។ កំញ៉ូមបារីក៏មិនគប្បីគោះនៅខាងក្រៅដែរ ព្រោះវាអាចត្រូវខ្យល់បកដូចទឹកមាត់ដែរ ហើយកំញ៉ូមបារីនោះនឹងហើរមកប៉ះភ្នែកច្រមុះអ្នកនៅខាងក្រោយ ជួនកាលកំទេចភ្លើងអាចហើរមកដែរ ។

បើនិយាយអោយខ្លីទៅ អ្នកជិះរថយន្តមិនត្រូវចោលអ្វីបន្តិចបន្តួចដូចជាកាកអំពៅ សំបកក្រូច សំបកត្របែក ។ល។ ទៅក្រៅរថយន្តដែលខ្លួនជិះឡើយ ។ គេត្រូវចោលក្នុងរថយន្តនេះផ្ទាល់ ព្រោះម្ចាស់រថយន្តមានអ្នកបោស ជូតនៅពេលដល់ចំណតនៅពេលជិះរថយន្តទៅណាមកណាផ្លូវឆ្ងាយ គេតែងព្រួយបារម្ភគ្រប់យ៉ាងចំពោះគ្រោះថ្នាក់ ដែលមិនដឹងជានៅឯណា រឺផ្ញើនរណាឡើយ ដូច្នេះគេតែងមានការប្រុងប្រយ័ត្នជាប់ក្នុងខ្លួនជានិច្ច គេមិនត្រូវដេករងាកបង្អើរព្រលឹងទៅបាត់ ទុករូបអោយយោលចុះយោលឡើង ម្តងទៅឆ្វេង ម្តងទៅស្តាំប៉ះលើគេឯងជិតនោះ រឺជួនកាលហៀរទឹកមាត់រឡាក់ដាក់គេឯងផងនោះទេ នៅពេលខ្លះដែលរថយន្តឈ្នួលនេះត្រូវឈប់ដោយបន្ទាន់ អ្នកដេករបៀបនេះក៏ជ្រុលអាត្មាបុកក្បាលមកប៉ះនឹងជញ្ជាំងឡាន រឺដែករបាំងរថយន្តក៏សឹងមាន។

នៅគ្រប់កន្លែងសំណាក់នីមួយៗ រឺគ្រប់កន្លែងដែលហៅរថយន្តឈប់ បុរសជាអ្នកដំណើរត្រូវលៃលកអោយនារីរឺមនុស្សចាស់ជាអ្នកដំណើរឡើងទៅលើរថយន្តមុន ។ គេមិនត្រូវហៅរថយន្តដែលដឹកមនុស្សជាច្រើនអោយឈប់ចាំខ្លួន ដែលមិនទាន់ងូតទឹកហើយនោះទេ ។


Facebook : Entertainment And Knowledge

គេមិនត្រូវជំនុំគ្នាពីរនាក់លើរថយន្ត ដោយសំលេងចេកចាចបូបាច់តាំងពីផែនដីកកើត រហូលដល់សតវត្សទី មួយម៉ឺនដោយធ្វើអោយគេថ្លង់ធុញទ្រាន់ពេលមួយរថយន្តនោះទេ ។

អ្នកជិះរថយន្ត មិនត្រូវជំរុញអោយអ្នកបើកឈប់នៅទីកន្លែងដែលខ្លួនចូលចិត្ត ទោះទីនោះមានគ្រោះថ្នាក់ដលគេឯងជាច្រើនទៀតក៏ដោយនោះទេ។ គេមិននាំចូលទៅជាមួយខ្លួននូវឆ្កែឆ្មាកូនរ៉ាលីស កន្ត្រកពីរ បីដោយទិញសំបុត្រតែមួយកន្លែងនោះទេ។ នៅពេលឈប់ មុននឹងចុះត្រូវក្រឡេកមើលឆ្វេងស្តាំដឹកនាំកូនទៅដាក់កន្លែងអោយស្រួល កុំអោយវារត់ប្រសេកប្រសាចធ្វើអោយអ្នកដែលប្រើប្រាស់ផ្លូវនេះដែរ ភ័យព្រួយដោយសារខ្លួន។

យើងទាំងអស់គ្នាត្រូវស្រឡាញ់ផ្លូវជាតិ និងផ្លូវសាធារណៈរបស់យើង យើងមិនត្រូវបណ្តោយអោយគោក្របី សេះរបស់យើងឆ្លងកាត់ចុះឡើងតាមអំពើចិត្តទេ ព្រោះនាំអោយមានគ្រោះថ្នាក់ដល់អ្នកដំណើរដែលមានជីវិតតែមួយហើយមួយគត់ដូចយើងដែរ។

កាលបើមានសត្វឆ្កែ ឆ្មា ជ្រូក មាន់ ទា ងាប់នៅតាមផ្លូវយើងត្រូវនាំគ្នាយកទៅកប់ចោល រឺយកទៅទីណាអោយបាត់ពីមុខពីមាត់។

យើងមិនត្រូវចោលអំបែងកណ្តាលផ្លូវសាធារណៈទេ បើឃើញមានស្ពានណាខូច រឺបម្រុងនឹងខូច យើងជាអ្នកស្នេហាជីវិតមនុស្សដូចគ្នា ត្រូវបញ្ជូនដំណឹងទៅរាជការមានសមត្ថកិច្ចភ្លាម។ យើងមិនត្រូវយកដែកគោល ទៅបោះបង្ហើបចុងស្រួចត្រង់ស្ពានដែលកង់រថយន្តត្រូវបើកពីលើទេ ព្រោះការខូចខាត រឺខកខានដំណើរអាចហុចផលអាក្រក់ដល់អ្នកដំណើរ បើដែកគោលនោះប៉ះលើរថយន្តរបស់រាជការ រឺរថយន្តយកការណ៍របស់យុទ្ធជននៅប្រទល់ដែនរឺរថយន្តសំរាប់ប្រតិបត្តិការសំងាត់ ដើម្បីរក្សាសេចក្តីសុខរបស់ប្រជាពលរដ្ឋ តើការខូចប្រយោជន៍នេះនឹងមានទំហំប៉ុណ្ណាទៅវិញ ។

# ទស្សនាខ្សែភាពយន្តនិងល្ខោន

ត្រូវទៅអោយទាន់ម៉ោង។ បើអ្នកទៅក្រោយម៉ោងបញ្ជាំងអ្នកដើរកាត់មុខគេ ត្រូវសុំអភ័យទោសពីគេ ត្រូវក្រោកឈរអោយអ្នកដទៃចូលដោយស្រួល។ អ្នកមានកូនខ្ចីមិនគប្បីយកកូនទៅជាមួយទេ ព្រោះវាអាចយំស្រែកទ្រហឹងអឺងអាប់រំខានដល់គេឯង បើក្មេងតូចត្រូវបត់ជើង ត្រូវជូនវាទៅកន្លែងបត់ជើង មិនគប្បីទុកអោយវាជុះនោមក្បែរកៀនកៅអីទេ ត្រូវរក្សាសេចក្តីស្ងាត់ស្ងៀមកុំព្រោកប្រាជ្ញច្រើនពេក កុំធ្វើអត្ថាធិប្បាយមុនដំណើររឿងដែលនឹងត្រូវបង្ហាញនៅពេលជាបន្ទាប់។ បើរឿងល្ខោន រឺកុននេះខ្លួនបានមើលរួចម្តងហើយ មិនគប្បីមកមើលម្តងទៀត ដើម្បីទិទានរឿងអួតប្រាប់គេឯងក្នុងរោងថាជាអ្នកគ្រាន់បើនោះទេ។ កាលបើគេហាមមិនអោយជក់បារី យើងមិនត្រូវលបលួចជក់ទេ។ ចេញ រឺចូលក្នុងបង្គន់ត្រូវបិទទ្វារអោយជិត ហើយត្រូវលាងទឹកអោយជ្រះនៅពេលបត់ជើងរួច កុំបត់ជើងតូច រឺធំក្រៅបង្គន់អោយសោះ។ កុំយកជើងសណ្តូកដាក់លើកៅអីគេអង្គុយ កុំអង្គុយចោងហោងលើពូកកៅអី រឺកៅអីធម្មតាណាមួយឡើយ។ បើត្រូវការក្អកខ្លាំងហើយយូរផងច្រើនដង យើងគប្បីចេញទៅក្អក រឺសុំគេចេញទៅញុំាទឹកខាងក្រៅ។ មិនត្រូវច្រៀងលីៗតាមបទល្ខោន រឺកុននោះទេ។ បើសប្បាយយ៉ាងណាក៏ដោយមិនត្រូវស្រែកឡូឡាម្នាក់ឯងទេ។ បើឃើញនារីក្រមុំអង្គុយមើលខាងមុខ រឺខាងឆ្វេង ស្តាំ បុរសមិនគប្បីឈ្ងោកទ្រោបជិតពេកទេ អង្គុយអោយត្រង់ខ្លួនបានហើយ ។

www.facebook.com/7khmer



# ការនាំគ្នាទៅកំសាន្តតាមទីណាមួយនៅឆ្ងាយដាច់ស្រយាល រឺកន្លែងទេសចរណ៍

យើងត្រូវស្លៀកពាក់អោយសមរម្យតាមការចូលចិត្តគឺស្លៀក តាមរបៀបស្រួលដើរ អង្គុយ ហក់លោត រត ។ល។

បើយើងនាំគ្នាវេចបាយ អង្ករ ចំណីចំណុកទៅរៀបចំនៅវាលស្រែ រឺក្នុងព្រៃ រឺមាត់ទឹក ជ្រលងភ្នំជាដើម យើងគួររៀបចានឆ្នាំង កន្ទេលនិងចំណីទាំងនេះអោយបានគ្រប់សមល្មមតាមសេចក្តីត្រូវការ។ ពេលដាំបាយ និងម្ហូបរួចហើយសូមកុំភ្លេចពន្លត់ភ្លើងសូមកុំចោលកំទេចអំបែងចាន រឺដប រឺឆ្អឹងឆ្អែងនៅពាលវាលពាលកាល ។ បើអ្នកបោះជំរុំនៅតាមឆ្នេរសមុទ្រក៏គួរកុំភ្លេចរឿងអនាម័យកុំបត់ជើងធំចោលមាត់ទឹក រឺទីណាមួយ ។

បើគ្មានសេចក្តីអនុញ្ញាត្តពីសាមីខ្លួនគេទេ យើងជាអ្នកថតរូបមិនគប្បីថតរូប ដឹតឃើញមុខគេច្បាស់ទេ។ ការថតទេសភាពផ្សេងៗទៀតជាសេចក្តីរីករាយគ្រប់គ្រាន់សំរាប់រូបអ្នកហើយ ដូច្នេះអ្នកមិនគប្បីសន្សំរឿងផ្សេងទៀតទេ។

បើអ្នកចូលចិត្តភ្លេងភ្លាត់ ដូចជាយកវិទ្យុ ហ្គីតា រឺក្រុមតន្ត្រីទៅរួមជាមួយត្រូវរកកន្លែងរបស់ខ្លួនអោយដាក់ឆ្ងាយពីគេព្រោះមានអ្នកខ្លះគេមិនចូលចិត្តភ្លេងនៅពេលដែលគេចង់បានសេចក្តីស្ងប់ស្ងាត់ រឺគេធុញទ្រាន់នឹងភ្លេងគ្មានសណ្តាប់ធ្នាប់របស់អ្នក ។

❁ ❁ ❁ ❁



Facebook : Entertainment And Knowledge

www.facebook.com/7khmer


# វិទ្យុ ទូរទស្សន៍

វិទ្យុ ទូរទស្សន៍ ជាគ្រឿងប្រដាប់យ៉ាងទាន់សម័យសំរាប់សំរួលដល់សេចក្តីត្រូវការរបស់យើងរាល់គ្នា ដូច្នេះយើងគប្បីប្រើប្រដាប់ប្រដាទាំងនេះអោយសមតាមឋានៈ របស់យើងជាម្ចាស់នៃសេចក្តីក្សេមក្សាន្តដែលកើតឡើងនេះ ។

អ្នកបើកវិទ្យុទទួលសំលេងគ្រប់រូបមិនគប្បី បើកចំហរអោយអស់សំលេងនាំអោយលឺគ្រលរ ហើយញរដល់ជញ្ជាំងផ្ទះ រីញ័រផ្ទៃដីនោះទេ ។

ត្រូវបើកអោយល្មមស្ដាប់បាន ចាប់តាំងពីម៉ោង ១១ យប់ទៅគេត្រូវបន្ថយសំលេងបន្តិច។ មុននឹងបើកប្តូរប៉ុស្តិមួយទៅប៉ុស្តិមួយគេត្រូវបិទសំលេងអោយនៅតូចល្មមលឺម្នាក់ឯង លុះរាវរកឃើញប៉ុស្តិ៍ដែលចូលចិត្តហើយ សឹមអ្នកបើកអោយលឺខ្លាំងជាងមុន តាមកំរិតសមគួរធម្មតាចុះ ព្រោះថាការលឺសំលេងចេចចាចរបស់វិទ្យុនាំអោយស្រគាត្រចៀកក្រៃលែង។ ឯការដែលបើករាវរកសំលេងបរទេសណាមួយ ក៏គប្បីរាវរកអោយតិចៗល្មមស្តាប់បាន។ ម្យ៉ាងទៀតភាសាខ្លះដែលមិនដឹងជាភាសាអ្វីផងនោះ មិនគប្បីបើកអោយលឺសូរខ្លាំងៗពេកទេ។ នៅពេលវិទ្យុបើកអស់សំលេងហើយ ភ្ញៀវរឺអ្នកក្នុងផ្ទះ មិនគប្បីនិយាយប្រណាំងនឹងវិទ្យុអោយលាន់រំពងមេឃទេ ត្រូវបិទវាអោយនៅសំលេងតូចសិន សឹមនិយាយគ្នាជាក្រោយ។ អ្នកបើប៉ុស្តិវិទ្យុផ្សាយសំលេង និងប៉ុស្តិទូរទស្សន៍គប្បីបំពេញករណីយកិច្ចរបស់ខ្លួនដោយទៅបង់ថ្លៃពន្ធអាករតាមសេចក្តីអំពាវនាវរបស់ក្រសួងឃោសនាការ ។

❁ ❁ ❁ ❁


Facebook : Entertainment And Knowledge

# សន្និសីទ

សន្និសីទជាការប្រជុំគ្នា ដោយអង្គុយចាំស្តាប់សេចក្តីរាយការណ៍ណាមួយ។ ពេលរកន្លែងអង្គុយអ្នកត្រូវគិតថា អ្នកអាចរក្សាសេចក្តីថ្លៃថ្នូរក្នុងពេលនោះបានទេ ។ បើបានសឹមរកកន្លែងនៅជួរខាងមុខគេ បើអ្នកយល់ថាសុន្ទរកថារបស់គេធ្វើអោយអ្នកផលយល់ថាយើងចាប់អារម្មណ៍ចំពោះពាក្យសំដីដែលគេនិយាយមក។ យើងមិនត្រូវអង្គុយសំឡឹងទៅអ្នកថ្លែងសុន្ទរកថា ហើយលូកដៃកេះអ្នកស្និទ្ធស្នាលខ្លួន ដើម្បីធ្វើមាត់អូចៗខ្សឹបគ្នាអោយថ្លែងមានការរងឿងឆ្ងល់ទេ ។

ពេលគេនិយាយរឿងអ្វី ដែលគួរអោយឈឺចិត្តខ្លោចផ្សា យើងយល់ស្របជាមួយគេហើយ យើងមិនត្រូវញញឹមរីករាយផ្ទុយនឹងចិត្តគំនិតដែលយើងត្រូវសំដែងទេ។ ពេលគេឡើងថ្លែងយោបល់យើងត្រូវសំឡឹងទៅរកគេ កុំមើលមេឃ រឺដំបូលពិតានធ្វើជាហី កុំដកដង្ហើមធំហើយលឺសូរដល់គេឯង បើឃើញគេនិយាយធ្វើកាយវិការរបៀបណាមួយ យើងជាអ្នកស្តាប់មិនត្រូវការដើរចេញមុខពេលបញ្ចប់ អ្នកត្រូវរកកន្លែងអង្គុយជិតមាត់ទ្វារ។ កុំអង្គុយស្ងាបញឹកញយពេកបើត្រូវការស្ងាបគេយកដៃខ្ទប់មាត់ កុំអោយគេមើលឃើញដល់គល់អណ្តាតដោយងើយស្ទើរក្រឡាប់ផែនដី កុំស្ងាបដូចគេស្រែក។

បើត្រូវត្រង់ចំណុចដែលគួរទះដៃ យើងត្រូវនាំគ្នាលើកទឹកចិត្តទីប្រជុំនិងអ្នកថ្លែង មិនត្រូវអង្គុយដូចអុកគ្មានព្រលឹងក្នុងខ្លួនទោះអ្នកណាទះដៃ អ្នកណាស្រែកជយោ ស្រែកអ្វីតាមតែគេនោះទេ។ រីឯអ្នកថ្លែងសុន្ទរកថាក៏ត្រូវថ្លែងអោយក្បោះក្បាយនិយាយអោយក្លាហាន ដើម្បីកុំអោយអ្នកស្តាប់គេធុញទ្រាន់ហើយនាំគ្នាដើរចេញព្រោះតែកាយវិការ និងសំលេងស្លាប់ស្លងរបស់ខ្លួន។

www.facebook.com/7khmer



# ពិធីភ្ជាប់ពាក្យលើកជំនូន

យើងទាំងអស់គ្នាជាយុវជន យុវតីក្នុងសម័យថ្មីតែងបានយល់ជាក់ច្បាស់ហើយថា តើដំណើរនៃចិត្តគំនិតរបស់មនុស្សក្នុងការរើសគូស្រករ បានដើរដល់ណាហើយ។

ដូច្នេះនៅពេលដែលយើងក្លាយជាមាតាបិតារបស់គេវិញតើយើងត្រូវគិតគូរយ៉ាងណា ដើម្បីរក្សាសេចក្ដីសុខសាន្តរបស់បុត្រាបុត្រីយើង ។

កាលពិសម័យមុន បុរសជាស្វាមីតែងចេញទៅធ្វើការដើម្បីយកកំរៃមកលៀងជីពជន្មគ្រួសារ ហើយចូលមកកាន់លំនៅស្ថានរបស់ខ្លួនវិញ តែនៅពេលណាដែលទំនេរសំរាប់សំរាកប៉ុននោះដូច្នេះការអប់រំបុត្រធីតាជាភារកិច្ចរបស់មាតាតែម្នាក់ប៉ុននោះ។ ដោយហេតុមាតាក្នុងគ្រួសារ ជាមនុស្សមិនបានរៀនអោយចេះដឹងបានជ្រៅជ្រះ មិនដែលបានអានដំណឹងពីមជ្ឈដ្ឋាននានា ខ្វះការពិសោធន៍គ្រប់គ្រាន់ក្នុងដំណើរជីវិត ហើយជាពិសេសទៅទៀត គេសង្កេតឃើញមាតាបិតា និងបុត្រធីតាតែងមានការលាក់គំនិតនឹងគ្នាព្រោះការខ្វាសអៀន រឺព្រោះអាងអំណាចជាដើម នេះហើយដែលបណ្ដាលអោយមានការខ្វែងគំនិតគ្នា ហើយមានគ្រោះថ្នាក់យ៉ាងធំនៅក្នុងគ្រួសារទៀតផង។

នៅក្នុងបច្ចុប្បន្នកាលនេះ គេសង្កេតឃើញមានការចំរើនលូតលាស់យ៉ាងច្រើនខាងផ្នែកវិទ្យាសាស្រ្ត តែគេមិនអាចនិយាយបានថា តើខាងផ្នែកចិត្តគំនិតនឹងមានការប្រែប្រួលទៅរកសេចក្ដីសុខ រឺសេចក្ដីទុក្ខនៅឡើយទេ។ ប៉ុន្តែទោះបីយ៉ាងណា ក៏យើងនៅមានចិត្តសង្ឃឹមថាដោយការចេះដឹងរបស់មនុស្ស គេនឹងអាចដើរទៅកាន់សេចក្ដីល្អ ដំណើរសុខសប្បាយបាន ប្រសិនបើមនុស្សលោកស្រឡាញ់សេចក្ដីសុខទាំងនោះដោយស្មោះ ហើយគ្មានការលោភលន់ហួសហេតុផង ។

មាតាសម័យថ្មី ជាមាតាដែលសុទ្ធសឹងតែបានទទួលការចេះដឹងស្មើរគ្រប់គ្នា ហើយមាតាតែងតែចេញទៅប្រកបការងារប្រចាំជីវិតដូចជាបិតាទាំងឡាយ



Facebook : Entertainment And Knowledge

ដែរ។ ដូច្នេះនៅក្នុងកាលៈទេសៈនេះ បិតាក្នុងគ្រួសារក៏មានការចាំបាច់ដើម្បីអប់រំបុត្រធីតារបស់ខ្លួនដែរ។

អាស្រ័យហេតុនេះយើងសង្ឃឹមថា មាតាបិតានឹងមិនប្រកាន់អំណាចផ្តាច់ការចំពោះកូនដូចសម័យមុនៗទៀតទេ។ ជាពិសេសក្នុងរឿងផ្សំផ្គុំបុត្រាបុត្រីអោយមានគូស្រករ។ យើងធ្លាប់ឃើញរួចមកហើយថា ដោយខ្វះសេចក្តីស្នេហារវាងគ្នានិងគ្នាដោយស្មោះត្រង់ គូស្វាមីភរិយាមិនអាចរក្សាគ្នាដោយសុខសាន្តរហូតអវសានជីវិតរៀងៗខ្លួនទេ ។

កាលបើឃើញបុត្រាបុត្រី យើងមានបំណងទាក់ទងជាមួយនឹងនារី-បុរសរូបណាហើយ យើងយល់ល្មមថាជីវិតគេអាចប្រព្រឹត្តទៅបានថ្លៃថ្នូរហើយ យើងគប្បីតាំងចិត្តជាមនុស្សប្រកបដោយសីលធម៌ និងមនុស្សធម៌ផង។ យើងមិនគប្បីពង្រាត់បំរាស់គ្នាព្រោះតែទុក្ខភាព ដែលវាសនាគ្នាបានស្តាយយកមកជាមួយនោះទេ បើយើងមិនពេញចិត្ត យើងគួរនិយាយពន្យល់បុត្រា បុត្រីយើងដោយប្រការផ្សេងៗ ល្មមៗ កុំតឹងរឹងដាច់ខាតពេក ព្រោះមានបុត្រាបុត្រីខ្លះមុខជាមិនហ៊ានលើកយករឿងដែលខ្លួនអៀនខ្មាស មកនិយាយជាលើកទីពីរទៀតឡើយ កាលបើយើងសង្កេតឃើញទឹកមុខបុត្រាបុត្រីយើងព្រួយបារម្ភ ព្រោះតែរឿងនេះហើយសង្កេតឃើញទឹកមុខបុត្រាបុត្រីយើងព្រួយបារម្ភ ព្រោះតែរឿងនេះហើយយើងជាមាតាបិតាធ្លាប់យល់និស្ស័យរបស់កូនដែលសុខចិត្ត ស៊ូប្តូរហើយយើងគប្បីបណ្តោយតាមវាសនាកូនទៅខុះ កុំទុកអោយគ្នារងទុក្ខវេទនាក្លាយទៅជាកំសាក រត់ចូលក្រោមរថយន្ត-រថភ្លើង-លោតទឹក-វិកលចរិត ព្រោះតែការរឹងរូសរបស់យើង យើងជាឪពុកម្តាយ កុំថ្នៃខ្លួនអោយទៅជាកម្មវត្ថុនៃការជេរស្តី ប្រទេចផ្តាសារបស់សីលធម៌ និងមនុស្សធម៌ដែលហូរចេញមកពីមតិមហាជន ។

យើងជាឪពុកម្តាយ មិនត្រូវខំប្រឹងតាំងខ្លួនធ្វើជាម្ចាស់ព្រេងវាសនារបស់កូនទេ យើងត្រូវអោយកូនធ្វើជាម្ចាស់ព្រេងវាសនារបស់ខ្លួនឯង ហើយយើងគ្រាន់តែជួយតំរង់បន្តិចបន្តួចប៉ុណ្ណោះ។ យើងជាឪពុកម្តាយ ត្រូវបំពេញករណីកិច្ចអោយកូនគឺត្រូវធ្វើអធិបតីនៃការរៀបមង្គលការអោយកូន។ មុននឹងរៀប

www.facebook.com/7khmer


មង្គលការគេត្រូវគោរពប្រពៃណីជាតិ គឺត្រូវធ្វើការភ្ជាប់ពាក្យដោយលើកជំនួន។

**ពិធីភ្ជាប់ពាក្យ**

ពិធីនេះជាកិច្ចលើកកិត្តិយសដល់កូនប្រុស ស្រី និងដើម្បីគោរពប្រពៃណីជាតិ ដោយមិនបណ្ដោយអោយកូនប្រុស ស្រីធ្លាក់ខ្លួនទៅជាមនុស្សដែលមិនខុសពីសត្វធាតុ។ តាមធម្មតាឪពុកម្ដាយគ្រួសារខាងប្រុសត្រូវនាំគ្នាធ្វើទស្សនាការតាមផ្លូវការក្នុងគ្រួសារឯផ្ទះរបស់គ្រួសារខាងស្រី បន្ទាប់ពិការសាកសួរគ្នាដឹងមាត់យល់សំដីរួចស្រេចហើយ។ ទស្សនាការជាផ្លូវការក្នុងគ្រួសារនេះតាមប្រពៃណីជាតិយើង តែងមាននាំយកទៅជាមួយនូវវត្ថុចាំបាច់តាមការគួរសមតាមកំរិតឋានៈគ្រួសារ និងតាមកិត្តិយសជូនទៅគ្រួសារខាងស្រីដែលនៅពេលនោះមាតាបិតាខាងស្រីតែងទទាក់ទទួលដោយស្មោះ ហើយចាត់ចែងការលៀងភោជនាហារតាមទំលាប់ ដើម្បីទទួលភ្ញៀវខាងប្រុសផង។

ចិញ្ចៀនជាអំណោយដួងចិត្តយ៉ាងសំខាន់ ដែលបុរសជាសង្សារតែងតែជូនចំពោះនារីជាអនាគតភរិយាខ្លួន។

នៅឱកាសនោះ បុរស និងនារីជាសាមីខ្លួនតែងធ្វើអំណោយវត្ថុអ្វីៗទៀតទុកជាអនុស្សាវរីយ៍ប្រចាំចិត្តរបស់ខ្លួនដោយប្ដូរគ្នាទៅវិញទៅមក ។

កំណត់ពេលដែលគេទៅស្ដីដណ្ដឹងទុកមុននេះ មានការកំណត់តាមកាលៈទេសៈ គឺតាមធម្មតាមានកំឡុងចន្លោះពីពីរអាទិត្យទៅទល់នឹងពីរឆ្នាំ។

ពិធីភ្ជាប់ពាក្យនេះ គេតែងអញ្ជើញភ្ញៀវខាងប្រុសខាងស្រីមានចំនួនតាមកិត្តិយសរបស់គ្រួសារទាំងសងខាង ហើយរបៀបអញ្ជើញគេតែងធ្វើដោយផ្ទាល់មាត់ រឺដោយប័ណ្ណអញ្ជើញ ។

❁ ❁ ❁ ❁


Facebook : Entertainment And Knowledge

www.facebook.com/7khmer



# សុជីវធម៌រវាងប្តីប្រពន្ធ

ប្តីប្រពន្ធដែលស្រុះស្រួលគ្នា តែងមានចិត្តសប្បាយរីករាយជាមួយគ្នាជានិច្ច គេមិនដែលធ្វើអោយល្អក់ចិត្តរវាងគ្នានិងគ្នាទេ។ ការងក់ដាក់គ្នាជាញឹកញយ មិនមែនសំរាប់បញ្ជាក់ចិត្តប្រាប់គ្នាថាព្រោះតែស្រឡាញ់គ្នានោះទេ ព្រោះតាមធម្មតាគ្មាននរណាគេឧស្សាហ៍ទ្រាំទ្រចិត្តខ្លួនដដែលៗបានឡើយ ។ សុខចិត្តធ្វើប្តីប្រពន្ធនឹងគ្នា បានសេចក្តីថាសុខចិត្តតស៊ូស្រណុកពិបាកគ្រប់យ៉ាងជាមួយគ្នាក្នុងដំណើរជីវិត។ ការឈ្លោះទាស់ទែងលែងលះគ្នាមិនមែនបានសេចក្តីថា ជាសក្ខីភាពនៃចិត្តគាំទ្របំណងអ្វីមួយទេ តែបានសេចក្តីថាខ្វះសមត្ថភាពនឹងរក្សាភាពជាប្តីប្រពន្ធនឹងគ្នា ។ គ្មានបញ្ហាណាដែលមនុស្សដោះស្រាយមិនរួចទេ មានតែមនុស្សមិនចូលចិត្ត និងដោះស្រាយប៉ុណ្ណោះ ដូច្នេះសុជីវធម៌រវាងប្តីប្រពន្ធ សរសើរតែអ្នកដែលស្រឡាញ់គ្នាដោយស្មោះត្រង់ មិនលបលួចមានសហាយស្មនណាមួយទៀត។ នារីជាភរិយាគួរយល់អោយច្បាស់អំពីករណីយកិច្ចជាប្រពន្ធរបស់គេ កុំចង់ធ្វើចៅហ្វាយនាយគេខ្លាំងពេក កុំប្រើប្តីដូចខ្ញុំកំដរកុំដេកសណ្តូកជើង រឺយោលអង្រឹងចាំមើលប្តីបោកខោអាវ ដណ្តាំស្លរីបោសផ្ទះ។ ជាការពិតណាស់បុរសជាស្វាមី ដែលស្រឡាញ់ប្រពន្ធចូលចិត្តយកចិត្តប្រពន្ធទោះគេអោយធ្វើអ្វីក៏ធ្វើទាំងអស់ តែមានភរិយាខ្លះមិនបានយល់ដល់ចិត្តស្វាមីឡើយ ស្មានតែគេជាទាសាររបស់ខ្លួនដាច់ថ្លៃ ម្ល៉ោះហើយក៏ហ៊ានពោលពាក្យអាក្រក់ៗថោកទាបខ្លះ ដល់បុរសជាប្តីរបស់ខ្លួន។ មាននារីសម័យខ្លះភ្លេចករណីកិច្ចរបស់ខ្លួនតាមច្បាប់ស្រីរបស់យើង។ ច្បាប់ស្រីថ្មីដែលចេញពីការនឹកឃើញតាមទំនើងចិត្ត អោយចិត្តអោយនារីខ្លះរំលោភមើលងាយស្វាមីខ្លួនឥតគណនា ។ ទោះបីក្នុងកាលៈទេសៈណាយើងជាភរិយាគេត្រូវតែគោរពគេក្នុងឋានៈជាប្តីដរាប។ ការបញ្ចេញយោបល់ផ្អែមល្ហែម ដើម្បីនាំផ្លូវស្វាមីនៅពេលដ៏គួរនឹងធ្វើអោយស្វាមីនាងមានចិត្តរីករាយ ហើយស្រឡាញ់ជាងលើកមុនៗទៀត។ នារីមាត់រឹងចចេស ចង់ឈ្នះមិនត្រូវកាលជានារីដែលបុរសទូទៅមានការព្រួយបារម្ភ



Facebook : Entertainment And Knowledge

ក្នុងការអប់រំ។

ចំពោះបើនារីជាភរិយា ត្រូវចេញទៅធ្វើការដូចបុរសជាស្វាមីដែរនាងមិនត្រូវអាងលើបុណ្យសក្តិរបស់នាង រហូតដល់បណ្តុះបង្អាប់បុណ្យសក្តិស្វាមីនាងទេ។ ការមិនឆ្លើយតបនឹងការដៀមដាមតិះដៀលរបស់នាង ជាការបញ្ជាក់អោយឃើញថាគេមានទស្សនៈខ្ពង់ខ្ពស់ជាងនាងឆ្ងាយណាស់ ទោះបីនាងមានឋានៈមុខងារជាអ្វីត្រូវនាងកុំភ្លេចថាជាភរិយា មេផ្ទះ និងជាមាតារបស់ទារក នារីត្រូវរក្សាកិត្តិយសរបស់ខ្លួនអោយថ្លៃថ្នូរទុកជូនស្វាមីរបស់នាង ការស្និទ្ធស្នាលជាមួយមិត្តប្រុស ជាមួយចៅហ្វាយនាយប្រុស បងប្អូនប្រុសៗទៀតមិនមែនជាការអាប់ឱនកិត្តិយសទេ តែក៏មិនមែនថ្លៃថ្នូរដែរ បើនាងប្រព្រឹត្តជ្រុលខុសខ្លាំងពេក។

ភរិយាមិនគប្បីមាត់ក ចេចចាចជាមួយស្វាមីដែលជាអកគិតច្រើននោះទេ។ កាលបើវិលត្រឡប់មកពីធ្វើការវិញ នាងជាភរិយាមិនគប្បីរករឿង នាំអោយសៅហ្មងដល់ស្វាមីជាទីស្រឡាញ់របស់ខ្លួនទេ។ តាមធម្មតាបុរសតែងចូលចិត្តមិត្តភក្តិខ្លះ រឺទៅជួបនឹងមិត្តភក្តិដែលធ្លាប់រាប់អានគ្នា ភរិយាមិនគួររំខានក្នុងរឿងនេះច្រើនពេកឡើយ ភរិយាត្រូវយល់ដល់អធ្យាស្រ័យចិត្តគំនិតរបស់ស្វាមីអោយបានពិតប្រាកដ។ ភរិយាត្រូវចាប់អារម្មណ៍ចំពោះកិច្ចការរបស់ស្វាមី ហើយត្រូវជួយសំរាលទុក្ខស្វាមីគ្រប់ពេលវេលា ។

ភរិយាត្រូវសួរខ្លួនឯងថា ៖

- តើខ្ញុំជាមេផ្ទះដ៏ចំណានម្នាក់រឺទេ ?
- ផ្ទះសំបែងរៀបចំមានសណ្តាប់ធ្នាប់រឺនៅ ម្ហូបអាហារបាយសម្ល ទុកដាក់ចង្ក្រានជើងឆ្នាំង ជួយធ្វើការប្តី និងដឹកនាំកូនសព្វគ្រប់រឺនៅ ?
- តើខ្ញុំមានចាប់អារម្មណ៍ចំពើកិច្ចការ សុខភាពរបស់ស្វាមីខ្ញុំទេ កិច្ចការរបស់ខ្ញុំ និងសុខភាពខ្ញុំល្អទេ ?
- តើខ្ញុំត្រូវនិយាយរឿងហេតុ អាថ៌កំបាំង រឺទុក្ខព្រួយណាមួយរបស់ប្រាប់ស្វាមីខ្ញុំទេ?
- តើខ្ញុំត្រូវរំខានស្វាមីខ្ញុំ រឺមួយខ្ញុំត្រូវជួយកុំអោយលោកនឿយហត់ព្រោះ

www.facebook.com/7khmer



តែរឿងហេតុបន្តិចបន្តួច ដែលមានដំណើរប្រហែលគ្នានឹង ឆ្មាលួចត្រីអាំងនោះ ។

- តើខ្ញុំនេះរឺ ជាមនុស្សដែលស្វាមីខ្ញុំ និងកូនខ្ញុំត្រូវទទួលសប្បាយរីករាយត្រជាក់ត្រជុំក្នុងសណ្ដានចិត្ត។
- តើខ្ញុំមានគិតសព្វគ្រប់ចំពោះថវិកា សំរាប់កំរិតឋានៈគ្រួសាររី នៅ?
- តើខ្ញុំមានកិរិយាមារយាទចំពោះអ្នកក្រៅពីស្វាមី និងកូនរបៀបណា។

ដូចជាញាតិខាងស្វាមី ញាតិរបស់ខ្លួន មិត្តភក្តិស្វាមីមិត្តភក្តិរបស់ខ្លួន មិត្តភក្តិរបស់កូន អ្នកជិតខាង ។ល។

នៅក្នុងគ្រួសារមួយ បើមានភរិយាចំណាន តែស្វាមីមិនចំណាន ដំណើរនៃគ្រួសារនោះមិនអាចប្រព្រឹត្តទៅបានល្អដែរ ដូច្នេះលោកជាស្វាមីមិនគប្បីប្រកាន់ចិត្តថា ក្នុងមួយជីវិតត្រូវរកភរិយាអោយបានច្រើននោះទេ ព្រោះថាបើខុសទាស់ឆ្គង់យ៉ាងណាភរិយាតែមួយស្រួលប្រដៅ ស្រួលពត់ចាងភរិយាពីរ បីដែលមិនដឹងជាគេមានចិត្តក្បត់ពុតត្បុតពេលណាឡើយ ឯការស្រឡាញ់ភរិយាប្រចាំជីវិតរបស់ខ្លួន លោកមិនត្រូវសំដែងអោយនាងឃើញថា លោកស្រឡាញ់ប៉ុណ្ណា ទាំងអស់តែម្ដងក្នុងកំឡុង ស្របកលុះដល់ទីបំផុត ក៏អស់រលីងសូន្យឈឹងនោះទេ។ សេចក្ដីស្រឡាញ់គ្មានអាណិតមិនមែនជាសេចក្ដីស្នេហា ដែលគេបណ្ដុះបណ្ដាលក្នុងថ្ពាលកសាងគ្រួសារទេតែសេចក្ដីស្រឡាញ់របៀប នោះជាសន្ទុះនៃភ្លើងចំបើងដែលនៅពេលរលត់ភ្លាម តាមតែសាកសពនៃផេះកំទេចកំទីប៉ុណ្ណោះ។ សូមលោកជឿចុះថា លំអឆើតឆាយជាទីដៅរបស់អារម្មណ៍ររើរវាយប៉ុណ្ណោះ ជំហានដែលបំរុងបោះគ្រាន់តែលើកមួយគ្រាសិនទៅចុះកុំទាន់ឈានធ្វើអ្វី។ ដើម្បីសេចក្ដីសុខសាន្តទៅថ្ងៃក្រោយ គួរយល់ហើយសួរបញ្ជាក់ខ្លួនឯងអោយច្បាស់លាស់ជាច្រើនដងថា តើនាងរូបនេះរឺជាភរិយាតែមួយ ហើយមួយគត់សំរាប់រូបលោក។ បើបានជាឈានហួសទៅហើយ ទោះបីយ៉ាងណាក្ដួរទ្រាំទ្រទៅចុះ ព្រោះគប្បីលោកនឹងអាណិតដល់បុត្រាបុត្រីដែលគ្មារងកម្មពៀរ ទឹកភ្នែកសស្រាក់រងទុក្ខវេទនា ទាំងផ្លូវកាយទាំងផ្លូវចិត្ត ព្រោះតែការព្រាត់ប្រាសរវាងលោក និងភរិយាលោក ត្រង់នេះហើយដែលជាប្រភពនៃ



Facebook : Entertainment And Knowledge

www.facebook.com/7khmer


មនុស្សធម៌ សុជីវធម៌គ្រប់យ៉ាងទាំងអស់ដែលលោកជាមនុស្សមួយរូប ដែលគួរដល់អោយច្បាស់មែនទែន។ កាលបើគ្មានចិត្តស្រឡាញ់ និងអាណិតក្នុងឋានៈជាប្តី ប្រពន្ធពិតប្រាកដទេ សូមកុំប្រថុយស្រើបស្រាលខ្វះវិចារណញ្ញាណអោយសោះ កុំអោយកំណើតទៅមនុស្សម្នាក់ អោយគ្នាកើតមកដើម្បីទទួលពាក្យអាស្រូវគ្រប់យ៉ាងបណ្តោយអោយប្រពន្ធធ្វើអ្វីតាមអំពើចិត្តនឹកឃើញនោះ មិនមែនមានឈ្មោះថាស្រឡាញ់ប្រពន្ធទេ ។ ធម្មតាបុរសជាអត្តទត្តបុគ្គល នារីជាប្រពន្ធច្រើនមិនសូវយល់ ដូច្នេះលោកគួរប្រាប់អាថ៌កំបាំង ដែលបណ្តាលអោយបុរសទៅជាអត្តទត្តបុគ្គល ព្រោះតែការស្រឡាញ់ប្រពន្ធ នាងជានារីដែលស្រឡាញ់លោកដោយស្មោះ មុខជាមិនប្រព្រឹត្តខុសបំណងលោកឡើយ ប៉ុន្តែសូមប្រយ័ត្នកុំធ្វើអោយប្រពន្ធបានចិត្តរីកថ្លើមខ្លាំងពេក ព្រោះមាននារីខ្លះអាងថាប្តីស្រឡាញ់ក៏ហ៊ានបំពានខ្លាំងដៃណាស់ដែរ ។

បុរសជាអ្នកដោះស្រាយបញ្ហាធំៗទាំងឡាយ ដែលចោទមកដល់គ្រួសារខ្លួន ត្រូវខំលើកដំកើងកំរិតជីវភាពគ្រួសារខ្លួន ធ្វើអោយនារីប្រពន្ធមានចិត្តកក់ក្តៅលើផែនទ្រូងរបស់ស្វាមី។

បុរសជាស្វាមី មិនប្រកានឬកស្រីម្ញិកម្ញក់ងងក់ទេ ព្រោះធម្មជាតិរបស់ស្ត្រីនឹងមិនចំណុះលោកប៉ុន្មានចំពោះកាយវិការនេះទេ ។

ស្ត្រីខ្លះជាមនុស្សដែលខ្លាំងពូកែ ចេះដឹងជ្រៅជ្រះ ប៉ុន្តែមានជួនកាលនាងជាមនុស្សមានសតិបញ្ញាទន់ខ្សោយក៏មានដែរហេតុនេះលោកជា ស្វាមីគួរយល់ដល់អធ្យាស្រ័យរបស់នាង។

ប្រពន្ធដែលចូលចិត្តការសប្បាយនៅខាងក្រៅផ្ទះ ទស្សនាខ្សែភាពយន្តល្ខោន មហោស្រពផ្សេងៗ ។ រាំច្រៀងញឹកញយក្នុងមួយអាទិត្យៗ សូមលោកជាស្វាមីប្រញាប់ដាស់សតិភរិយាប្រចាំជីវិតលោកអោយមែនទែន។ បើដឹងថាភរិយាលោករៀបក្បត់ចិត្តហើយលោកគួររកវិធីចាត់វិធានការយ៉ាងណា អប់រំអោយភរិយាលោក វិលមកកាន់សតិដើមវិញ ។ កើតជាប្រុសមិនត្រូវជាមនុស្សដែលគេតែងហៅថា "អាវែក" ទេមិនត្រូវទុកចិត្តប្រពន្ធខ្លួន អោយដើរលេងកំសាន្តជាមួយពួកម៉ាកប្រុសទេ ។


Facebook : Entertainment And Knowledge

www.facebook.com/7khmer


បុរសជាស្វាមី ត្រូវគោរពភរិយាលោក ដូចជាភរិយាលោកគោរពរូបលោកដូច្នោះដែរ។ ការវាយដំច្រំធាក់ទៅលើរូបប្រពន្ធជាភេទទន់ខ្សោយ ជាកិរិយារិកលចរិតលីលាផុតលេខ ដែលគួរតែស្វាមីទាំងឡាយច្រានមារយាទរបៀបនេះ អោយធ្លាក់ភក់ជ្រាំអោយអស់។ ស្វាមីមិនត្រូវតែពោលពីលំអភរិយាគេ រីនារីនាម្នាក់ប្រាប់ភរិយាខ្លួន ដើម្បីបង្កើតការអាក់អន់ស្រពន់ចិត្តរបស់ភរិយាខ្លួនទេ។ ស្ត្រីទាំងអស់សុទ្ធតែជាមនុស្សជោរ តែលោកមិនត្រូវបញ្ចេញកិរិយាអោយភរិយាលោកដឹងថាលោកបញ្ឆោរនាងដោយត្រង់ៗតែម្តងទេ។

លោកជាស្វាមី មិនត្រូវស្វះស្វែងរកស្រីញីបណ្តើរគ្នាលេងបង្ខិនថវិកាគ្រួសារ ដើម្បីសំរេចតាមទំនើងចិត្តរិកលមួយដងមួយគ្រានោះទេ ព្រោះនាំអោយអ្នកផងដែលមិនបានដឹងច្បាស់ គេអាចយល់ដោយច្រឡំថាភរិយាដ៏ត្រឹមត្រូវរបស់លោក ក៏ជាស្រីក្នុងចំណោមស្រីអាវ៉ាសែ ដែលរាជរដ្ឋាភិបាល ព្រោះលោកគាំទ្រអំពើពុករលួយ។

កើតមកជាអង្គប្រុស គេត្រូវអប់រំចិត្តខ្លួនគេអោយទៅជាមនុស្សប្រុសថ្លៃថ្នូរសមសួន គេមិនត្រូវធ្វើជាប្រុសអាវ៉ាសែខ្វាត់ខ្វាត់តាមផ្ទះកេតរកូតជាយក្រែង ដែលសំណាក់នៅដោយហ្វូងកង្កែបញីកាមគុណ លួចលាក់ដើម្បីរស់តែមួយភ្លែតៗនោះទេ ព្រោះគំនិតរបៀបនេះមិនមែនជាអ្នកស្វែងរកសេចក្តីសុខទេ តែជាការរកសេចក្តីសប្បាយផ្ទាល់ខ្លួន ហើយជាន់ពន្លិចគ្រួសារដ៏សុខសាន្តអោយធ្លាក់ជ្រោះអន្តរធាន។ បុរសជាស្វាមីមិនត្រូវមើលងាយភរិយាខ្លួនថា ជាអ្នកមករស់នៅដោយសារកំលាំងញើស កំលាំងក្បាលរបស់ខ្លួនទេលោកគួរពិចារណាអោយសមេហាតុផលចុះថា បើគេមិនព្រមទទួលលោកជាស្វាមីទេ ក៏អាចរស់នៅជាមួយស្វាមីគេរូបណាមួយទៀតដ៏សុខសាន្តដែរ កាលពីគ្រាមុនលុះដល់គ្រាគ្នាជាភរិយាមានកូនចៅទៅហើយទើបលោកលើករឿងដូច្នោះ មកនិយាយ បើលោកមិនស្រឡាញ់ តើលោករៀបការយកគ្នាមកចងកម្មពៀរធ្វើអ្វី? ។ គ្រប់ដំនើរជីវិតរបស់លោកលោកជាស្វាមីត្រូវសាកសួរខ្លួនលោកថា ៖

-តើខ្ញុំបានបំពេញករណីយកិច្ច ជាស្វាមីរបស់នារីម្នាក់នេះពិតប្រាកដទេ?


Facebook : Entertainment And Knowledge

-បាននិយាយពីមិត្តភក្តិល្អ ពីមុខរបររបស់លោកជាទីសណ្តាប់របស់ភរិយា?

-តើខ្ញុំគួរនិយាយរឿងអាថ៌កំបាំង ទុក្ខព្រួយ កិច្ចការសមរម្យក្នុងផ្ទះសំបែងប្រាប់ភរិយាទេ?

-តើខ្ញុំមានយកចិត្តទុកដាក់ អំពីកិច្ចការ និងសុខភាពរបស់ភរិយាខ្ញុំ និងកិច្ចកង្វល់របស់ភរិយាខ្ញុំទេ?

-តើខ្ញុំត្រឡប់ពីធ្វើការ ខ្ញុំមានទៅណាមុនចូលផ្ទះទេ?

-តើខ្ញុំត្រូវធ្វើយ៉ាងណា ដើម្បីធ្វើអោយភរិយាខ្ញុំទទួលខ្ញុំដោយសប្បាយរីករាយ ខ្ញុំបានលើកកំរិតជីវភាពគ្រួសារអោយសមរម្យរឺនៅ ?

-នៅពេលឈប់សំរាក តើខ្ញុំមានជួយមើលកិច្ចការក្នុងផ្ទះសំបែងដើម្បីជួយសំរាលភរិយាខ្ញុំទេ? មានមិនភក្តិណាគេរាប់រកខ្ញុំទេ? ចុះគ្រួសាររបស់ឪពុកម្តាយយើងទាំងពីរ ?

-ខ្ញុំមានលួងលោមបបោលអង្អែលប្រពន្ធខ្ញុំទេ?

-ចុះកូនរបស់ខ្ញុំវាស្រឡាញ់ខ្ញុំទេ វារៀនសូត្រដល់ណាដែរ វានៅទន់ខ្សោយត្រង់ណាទៀត។

-ពេលខ្ញុំដើរបាត់ផ្ទះ មនុស្សក្នុងផ្ទះខ្ញុំ គេព្រួយបារម្ភយ៉ាងណាទៅ?

-តើខ្ញុំនេះរឺជាប្រធាននៃសមាជិកគ្រួសារ?

សុជីវធម៌រវាងប្តីប្រពន្ធ ដែលបានរៀបរាប់មកនេះល្អមសមរម្យខ្លះហើយតែគេមិនអាចរក្សាសុជីវធម៌នេះតែក្នុងគ្រួសារហើយភ្លេចដល់អ្នកជិតខាងផ្សេងៗទៀតទេ។

មានគ្រួសារខ្លះ គេសប្បាយរីករាយក្អាកក្អាយតែក្នុងផ្ទះរបស់គេ គេមិនចាំបាច់ស្គាល់រាប់អានអ្នកជិតឆ្ងាយ មិត្តភក្តិបងប្អូនទៀតទេការគិតរបៀបនេះមិនត្រឹមត្រូវសោះឡើយ ព្រោះថាយើងមិនអាចរស់នៅដាច់តែឯកឯងបានទេយើងត្រូវទាក់ទងជាមួយអ្នកក្រៅដូចជាសាច់ញាតិ មិត្តភក្តិទៀតៗ ព្រោះអ្នកទាំងនោះគេមានជួយឈឺឆ្អាលយើងខ្លះៗដែរនៅពេលដែលយើងមាន ទុក្ខលំបាក ។

www.facebook.com/7khmer



# សុជីវធម៌ចំពោះមនុស្សក្រៅ

## គ្រួសារ

គ្រួសារមួយដែលមានឪពុកម្តាយស្រុះស្រួលគ្នា មានបុត្រាបុត្រី ប្រកបដោយសណ្តាប់ធ្នាបតាមដំបូន្មាន មានគេហដ្ឋានសមរម្យតាមរបៀប ហើយមនុស្សក្នុងគ្រួសារទាំងមូល ស្រឡាញ់គ្នាដោយស្មោះ លើគ្រួសារនេះបានទទួលការសប្បាយរីករាយហើយរឺ ?

តាមពិត គ្រួសារនេះត្រជាក់ត្រជុំតែផ្ទៃក្នុងប៉ុណ្ណោះ ដើម្បីរក្សាសេចក្តីសុខសប្បាយ ភាពត្រជាក់ត្រជុំនេះអោយមានសភាពថ្លៃថ្នូរ ហើយយឺនយូរផងគ្រួសារនេះត្រូវមានការទាក់ទងជាមួយអ្នកដែលនៅខាងក្រៅផង។

តើអ្នកក្រៅទាំងនោះមាននរណាខ្លះ?

អ្នកទាំងនោះជាអ្នកដែលមានការទាក់ទងជាមួយយើងធ្លាប់ជួប ប្រទះយើងនៅទីណា រឺតាមផ្លូវណាមួយ។

គឺជាគ្រួសារឯទៀតដែលយើងធ្លាប់ស្គាល់ អ្នកជិតខាងយើងមិត្តភក្តិនៅកន្លែងធ្វើការ មិត្តភក្តិរបស់កូន ឪពុកម្តាយ ភ្នាក់ងារ រាជការ នៅក្នុងសង្កាត់ដែលរស់នៅ ។

មានអ្នកខ្លះចូលចិត្តនិយាយថា រកពេលទំនេរគ្មានរវល់ខ្លាំងពេក ហត់នឿយពេក។ ល្អហើយ ប៉ុន្តែនៅពេលដែលយើងមានភារៈរវល់ សូមយើងកុំភ្លេចថា យើងមុខជាមានក្បាលតែម្នាក់ឯងនិងគ្រួសារឯងមួយប៉ុណ្ណោះ។

ដូច្នេះបុរស នារីជាប្រមុខគ្រួសារ ត្រូវចេះលៃពេលទាក់ទងជាមួយអ្នកទាំងនោះផង ការទំនេររបស់មនុស្សខ្ជិល និងកំណាញ់មិនដែលមានឡើយសូម្បីតែអង្គុយ រឺដេកក៏គេនិយាយថា រវល់អង្គុយ រឺរវល់ដេកដែរ ។ ពាក្យថា "រវល់" តែងជាប់នៅលើមនុស្សជានិច្ចតាំងពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់។

ទោះមានការរវល់របៀបណាមួយក៏ដោយ ក៏យើងគប្បីឆ្លៀតពេលដ៏ល្អ



Facebook : Entertainment And Knowledge

www.facebook.com/7khmer


ដើម្បីរាក់ទាក់ ជាមួយអ្នកដែលនៅក្រៅគ្រួសារយើងកុំខានអោយសោះ។

### មិត្តភក្តិនៅកន្លែងធ្វើការ

តាមធម្មតា មិត្តភាពតែងមាននៅក្នុងកន្លែងធ្វើការចិញ្ចឹមជីវិត។ រស់នៅទីណាគេត្រូវញ៉ាំងទីនោះអោយបរិយាកាសសប្បាយរីករាយ អោយសមគ្គីគ្នា គេត្រូវរាប់អានគ្នាដោយស្មោះគេមិនត្រូវធ្វើឈ្លើយសោះអង្គើយទេ។ ជាការល្អ គេត្រូវមានការទាក់ទងជាមួយគ្រួសាររបស់មិត្តភក្តិ ដែលធ្វើការជាមួយគ្នានេះ នារីជាសរិយាត្រូវគោរពគួរសមចំពោះមិត្តភក្តិរបស់ស្វាមី រីឯបុរសជាស្វាមីក៏ត្រូវរាប់អានមិត្តនារីរបស់ភរិយាលោកដោយស្មោះត្រង់ដែរ ។

ការទើសទែងក្នុងចិត្តមួយដង មួយគ្រា យើងត្រូវលើកលែងគ្នា កុំផ្តឹងផ្តល់ចាក់រុកចៅហ្វាយនាយ រឺអ្នកធំអោយមានគំនុំដល់មិត្តភក្តិរបស់យើង កុំបន្ថោកកិត្តិយសមិត្តភក្តិយើងអោយសោះ។ បើគេរាប់អានយើងដោយស្មោះយើងកុំប្រញាប់មើលងាយគេពេកយើងត្រូវគោរពគេវិញ។ កំហុសអ្នកដែលបានប្រព្រឹត្តលើកទីមួយលើកទីពីរ ហើយគេមិនលឺមាត់បន្តិចបន្តួចអ្នកគួរខ្លាចចិត្តគេអោយហើយជាស្រេច កំហុសលើកទីបីរបស់អ្នករបៀបផើមដែលគេមិនអាចលើកលែងទោសអោយបាន ក្រែងគេធ្វើអោយអ្នកខ្មាសគេក្នុងចំណោមមិត្តភក្តិទាំងឡាយ ។

បុរស និងស្ត្រីដែលធ្វើការជាមួយគ្នា ត្រូវប្រកាន់កិរិយាមារយាទអោយល្អកុំល្មើសនឹងច្បាប់សីលធម៌ និងភ្នែកអ្នកជិតខាង។

កន្លែងធ្វើការ ជាកន្លែងដែលគេខំប្រឹងរកលុយកាក់លៀងជីវិត មិនមែនជាផ្ទះបន ផ្ទះបៀ រោងល្ខោន រោងកុនឡើយ។ សំដីដែលនិយាយទៅកាន់គ្នាត្រូវនិយាយដោយសុភាពរមទម្យថ្លៃថ្នូរកុំរើសពាក្យអ៊ី អញ អាឯង ហងឯ រឺពាក្យចំអាសអាវាសែផតត្រកូលអោយសោះ ។

កុំទាត់ធាក់ វាយតប់ ដាល់គ្នានៅក្នុងការិយាល័យ។

កុំហួច និយាយឡូឡា រឺស្រែកច្រៀងតាមទំនើងចិត្ត។

### មិត្តភក្តិរបស់បុត្រាបុត្រី

មួយដងមួយកាល បុត្រាបុត្រីអាចនាំមិត្តភក្តិដែលធ្លាប់រៀនសូត្រជាមួយ


Facebook : Entertainment And Knowledge

www.facebook.com/7khmer


គ្នាទៅលេងឯផ្ទះរបស់ខ្លួន ។

ឪពុកម្តាយ ត្រូវជួយទទួលភ្ញៀវកូនដោយរីករាយរាក់ទាក់មាតាបិតាមិនចាំបាច់ចំណាយលុយកាក់អ្វីច្រើនទេ គ្រាន់តែញញឹមបន្តិចសំពះតបនឹងពួកម៉ាករបស់កូនវិញ ហើយសំណេះសំណាលបន្តិចបន្តួចផងនោះ ជាភារៈដែលមានតំលៃជាងចេញលុយកាក់អស់ច្រើនទៅទៀត។

ពេលភ្ញៀវរបស់កូនមកលេងលំនៅស្ថាន ឪពុកម្តាយត្រូវនិយាយពាក្យផ្អែមពិរោះ ទៅរកពួកម៉ាកមិត្តភក្តិរបស់កូន។ កុំនាំកូនគេនិយាយអាក្រក់ពីនរណាមួយ។ ត្រូវនិយាយតែអំពើល្អដែលដឹកនាំក្មេងអោយឆ្លាតវៀងវៃរៀនពូកែ។

ធ្វើដូច្នេះ កូនរបស់យើងនឹងសប្បាយរីករាយក្នុងចិត្តឥតឧបមា ហើយវាស្រឡាញ់ និងគោរពយើងជាងមុនទៅទៀត ។ ធ្វើជាឪពុកម្តាយរបស់ក្មេងណាម្នាក់ គេមិនត្រូវបញ្ចេញឫកអោយក្មេងហ៊ានមើលងាយ រឺអាងថាយើងស្រឡាញ់វាជ្រុលពេកទេ គឺត្រូវសំដែងកិរិយាជាចាស់ទុំថ្លៃថ្នូរជាទីគោរពរបស់វា។

## អ្នកជិតខាង

យើងជាអ្នកថ្លៃថ្នូរ ត្រូវរកសេចក្តីសុខជាមួយអ្នកជិតខាងនេះ ព្រោះអ្នកទាំងនោះហើយជាបងប្អូនយើង ជួយឈឺឆ្អាលយើងដូចបងប្អូនយើងដែរ។ យើងមិនត្រូវរាប់អានអ្នកនៅខាងមុខផ្ទះស្អប់អ្នកនៅអបសងខាង រឺអ្នកនៅខាងក្រោយផ្ទះទេ គឺយើងត្រូវរាប់អាន ហៅរកចែកចំណីចំណុកបន្តិចបន្តួចស្មើៗគ្នា ទោះមានបុណ្យទានរវល់អ្វី យើងមិនត្រូវភ្លេចអ្នកជិតខាងយើងទេ ។

កុំនិយាយចាក់រុក និយាយអាក្រក់ពីអ្នកជិតខាងណាមួយឡើយ បើអ្នកជិតខាងណាមួយនិយាយអាក្រក់ពីយើង អ្នកនោះឯងនឹងខ្មាស់អៀនស្ទើរស្លាប់មិនខាន នៅពេលដែលយើងមិននិយាយអាក្រក់ពីអ្នកនោះតបវិញ ហើយនៅតែបន្តចិត្តល្អស្មោះសតបអ្នកនោះវិញ។

ទោះបីយើងមានយ៉ាងណា បើយើងគ្មានការគាំទ្រពីអ្នកជិតខាងយើងនឹងគ្មានសេចក្តីសុខប៉ុន្មានឡើយ។ នៅពេលដែលយើងឃើញគេមានទុក្ខ មរណភាព អគ្គីភ័យ ចោរលួច ជាដើមយើងត្រូវជួយឈឺឆ្អាលគេតាមសមត្ថភាព។

យើងមិនត្រូវឈ្លោះទាស់ទែងជាមួយអ្នកជិតខាងព្រោះតែរឿង បន្តិច


Facebook : Entertainment And Knowledge

បន្ទួចនោះទេ ត្រូវចេះអត់អាស្រ័យគ្នាទៅវិញទៅមក។ បើអ្នកជិតខាងឈ្លោះគ្នាអំពីរឿងប្ដីប្រពន្ធគេ យើងជាអ្នកជិតខាងគ្មានសិទ្ធិអ្វីទៅឃាត់ឃាំងគេទេ ជារឿងរបស់គ្រួសារគេគ្រាន់តែនិយាយសរុះសំរួលគេបន្តិចបន្តួច នៅពេលគេអោយយើងធ្វើជាអ្នកដឹងលឺប៉ុណ្ណោះ ជាការសមល្មមណាស់ហើយ។ យើងមិនត្រូវនាំកូននាំចៅទៅឈរពពាក់ពពូនមើលគេឈ្លោះគ្នាទេ។ ពេលគេឈ្លោះគ្នាកុំដកកអើតតាមបង្អួច រឺអើតកអោយលេចក្បាលចេញមកក្រៅដើម្បីមើលគេអោយសោះ។ ការៈរបស់យើងត្រូវរក្សាសេចក្ដីស្ងប់ស្ងាត់ភាពថ្លៃថ្នូរ ដូច្នេះយើងស៊ូធ្វើគថ្លង់គ្រប់យ៉ាងអំពីរឿងគេឈ្លោះគ្នានេះកុំចង់ធ្វើធំដោយតាំងខ្លួនជា អាជ្ញាកណ្ដាលអោយសោះព្រោះកិត្តិយសនេះមិនមែនថ្លៃថ្នូរប៉ុន្មានទេ នៅពេលដែលគេមិនយល់ព្រម ។

យើងមិនត្រូវទៅអង្គុយផ្ទះគេហួសពេលវេលា ជាអ្នកថ្លៃថ្នូរនោះទេ ព្រោះយើងតោងគិតព្រួយដល់ការមិនចូលពីសមាជិកគ្រួសារយើង និងគ្រួសារគេ។

ចំណីអ្វីដែលគេអោយយើង គេយកមកអោយឯផ្ទះ យើងមិនត្រូវពកូនទៅឈរមើលគេធ្វើនំដើម្បីសុំគេនោះទេ។

លុយកាក់លើសខ្វះគ្នាមួយរៀល ពីររៀល អំពីរឿងទឹកភ្លើងរឺរឿងអ្វីមួយយើងត្រូវលះបង់ចោលទៅចុះ បើកំណាញ់ណាស់គួរនិយាយដោយស្រួលជាមួយគេ មិនត្រូវខ្សឹមខ្សៀវពេបជ្រាយបូញមាត់ ក និយាយស្វាត់ៗ បញ្ចិតងបញ្ចៀងដល់គេទេ។ យើងត្រូវរាប់រកអ្នកទាំងនោះទោះមានក្ដី ក្រក្ដី ក្នុងឋានៈជាមនុស្សស្និទ្ធស្នាលដូចគ្នាទាំងអស់ ។

❁ ❁ ❁ ❁

www.facebook.com/7khmer


# ល្បែង និងមនុស្ស

(ល្បែងក្នុងទីនេះ សំដៅទៅលើល្បែងដែលប្រព្រឹត្តផ្ទុយនឹងច្បាប់ ដូចជាបៀ អាប៉ោង ។ល។ ...។ល។)

មានមនុស្សភាគខ្លះខ្វះការពិចារណា តែងទុកល្បែងខាងលើនេះជាឱសថដ៏ចំណានសំរាប់ព្យាបាលជំងឺចិត្ត។ កាលបើខូចចិត្តដោយសាររឿងអ្វីមួយ ដូចជាវិបត្តិគ្រួសារជាដើម គេតែងតែបន្លប់ចិត្តរបស់គេដោយលេងល្បែងស៊ីសង។

ភរិយាខ្លះពេលប្តីចេញទៅធ្វើការ រឺទៅបំពេញបេសកកម្មនៅទីឆ្ងាយតែងខ្វល់ខ្វាយក្នុងចិត្ត បែកគំនិតចង់កំសាន្តខុសច្បាប់ខ្លួនជាមេផ្ទះ ហើយដើរតំរង់ទៅវង់ល្បែងលួចលាក់។ តាមធម្មតាគ្រប់វង់ល្បែងស៊ីសងលួចលាក់ គេមិនដែលអនុគ្រោះតាមច្បាប់សុជីវធម៌ជាសកលទេ ក្នុងសុជិវធម៌របស់គេ គេតែងចាត់មនុស្សគ្រប់វ័យអោយស្មើគ្នា មនុស្សចាស់សក់ស្កូវសព្រោង ក៏មានតំលៃស្មើក្មេងរលីមរលោមអាយុជាងដប់ឆ្នាំដែរ។ ការល-លូកនាយអាយអាចប្រព្រឹត្តបានស្មើគ្នារវាងប្រុស និងស្រីទោះស្រីក្រមុំក៏ដូចជាស្រីជាប្រពន្ធគេដែរ។ កាលបើនិយាយគ្នាស្តាប់មិនបាន មានតែកំលាំងបាយប៉ុណ្ណោះដែលជាអាជ្ញាកណ្តាលក្នុងវង់ល្បែងរបៀបនេះ។ នៅពេលមិនទាន់ក្រពុលមុខព្រោះចាញ់ គេអ្នកលេងល្បែងតែងដាក់វិន័យល្អណាស់ ប៉ុន្តែនៅពេលដែលជំងឺរលាក និងជំងឺស៊យមុខក្រៀមម្ជូរម៉ៅក្តៅស្លឹកត្រចៀកដល់គ្នា វិន័យរបស់គេក៏រត់បាត់អស់។ គឺនៅពេលនោះហើយ ដែលមានការឈ្លោះគ្នាដោយខានមិនបានហើយនៅពេលជាបន្ទាប់នោះ ដែលរាជការមានសមត្ថកិច្ចរកឃើញអ្នកលេងល្បែងស៊ីសង។

កើតមកជាមនុស្ស គេតែងរិះគិតដល់អនាគតរបស់ខ្លួននិងកូនរបស់ខ្លួន។

នៅពេលជាប់គុក គេរកឃើញកំណប់វាសនាយ៉ាងណាខ្លះទុកអោយកូន


Facebook : Entertainment And Knowledge

www.facebook.com/7khmer


ប្រពន្ធ ។

ឯស្ត្រីជាភរិយាវិញនោះ នៅពេលគេចាប់បានគេធ្វើមុខយ៉ាងណាដើម្បីបង្ហាញប្តីដែលវិលត្រឡប់មកពីធ្វើការ ។

អ្នកនាងជាភរិយាទាំងឡាយជឿចុះថា បុរសសម័យឥឡូវនេះ មានបុរសភាគខ្លះស្រឡាញ់កិត្តិយសថ្លៃថ្នូររបស់គេណាស់ ថ្វីបើគេស្រឡាញ់អ្នកនាងជាភរិយាគេមែន តែគេមិនអាចរក្សាកិត្តិយសស្អុយឆ្អាបរបស់ភរិយា ដែលសាហាស្មន់ និងល្បែងពាលានោះបានឡើយ ។

បុរសចៅកែល្បែង តែងតែជួបភរិយាកំបាក់បំពុកជាធម្មតា។ ធ្វើជាប្រមុខគ្រួសារនីមួយៗគេតែងតែអោយដំបូន្មានល្អដល់បុត្រធីតាដោយសំអាត ខ្លួនជាមុន ទើបប្រដៅបុត្រធីតាបានបទជាក្រោយ។ ជំងឺល្បែង មិនមែនជាជំងឺប្រចាំពូជដែលត្រូវតែឆ្លងទៅលើសមាជិកគ្រួសារទាំងអស់ក្នុងពូជនោះទេ ជំងឺល្បែងមិនអាចឆ្លងលើមនុស្សដែលមានឧត្តមគតិល្អបានឡើយ។

គេតែងសរសើរអ្នកដែលចេះល្បែង មិនប្រព្រឹត្តល្បែងជាងអ្នកមិនចេះហើយមិនប្រព្រឹត្តទៅទៀត ព្រោះមានអ្នកខ្លះមិនប្រព្រឹត្តតែពេលដែលខ្លួនមិនចេះ ហើយវក់ខ្លាំងនៅពេលដែលចេះបន្តិចបន្តួច។ ឧត្តមគតិដ៏ល្អប្រសើររបស់យើង គឺគោរពច្បាប់សំរាប់រដ្ឋរបស់យើងអោយសមជាពលរដ្ឋថ្លៃថ្នូរ ល្បែងផ្ទុយនឹងច្បាប់ជាល្បែងគួរអោយរអើម និងមើលងាយរបស់យើងគ្មានអ្នកលេងល្បែងស៊ីសងណាមួយ ដែលខំប្រឹងលួចលាក់នឹងច្បាប់ មិនចង់អោយឈ្នះគេដើម្បីបំប៉ោងហោប៉ៅរបស់ខ្លួននោះទេ។ ពិតមែនតែគេពោលថាកំសាន្ត-កំសាន្តតែគេចង់ឈ្នះអ្នកដទៃ។ បើកំសាន្តមែន ហេតុអ្វីក៏គេមិនលេងល្បែងដោយរបៀបមិនដាក់លុយ ?

ឱ! ចំណុចនេះទេតើ បានជាគេថាផ្ទុយនឹងច្បាប់។

ចូលឆ្នាំថ្មីជិតមកដល់ហើយ! ឆ្នាំនេះសម្តេចព្រះបិតាជាតិព្រះអង្គទ្រង់ព្រះរាជាអនុញ្ញាត្តអោយប្រជាពលករ គ្រប់ឋានៈបានសប្បាយរីករាយគគ្រឹកគ្រេង។ ដោយព្រះអង្គជាព្រះសទ្ទេនៈវិទូដ៏ចំណានប្រកបដោយ ព្រះបញ្ញាណញាណដែលមានការពិសោធគ្រប់គ្រាន់ទៅលើទឹកចិត្តបណ្តារាស្ត្រជាកូនចៅ ព្រះអង្គ


Facebook : Entertainment And Knowledge

ទើបស្តេចទ្រង់ព្រះរាជាអនុញ្ញាត្តអោយលេងល្បែងចំនួនបីថ្ងៃក្នុងឱកាស ចូលឆ្នាំថ្មីរបស់ខ្មែរ។ យើងជាកូនចៅព្រះអង្គគួរយល់ដល់ព្រះបំណងសម្តេចព្រះបិតាយើងអោយច្បាស់លាស់។

ព្រះទ័យសម្តេចព្រះបិតា គឺពិតជាចង់អោយកូនចៅបានសប្បាយតែក្នុងឱកាសចូលឆ្នាំថ្មីប៉ុណ្ណោះ។ ការសប្បាយនេះកើតឡើងនៅក្នុងក្រុមគ្រួសារមិត្តភក្តិក្តី បានសេចក្តីថាគេលេងដើម្បីអោយសប្បាយ ពុំមែនលេងដើម្បីបានផលរងទុក្ខវេទនានោះទេ ។

ការខំប្រឹងស្កាត់ពីកន្លែងមួយទៅកន្លែងមួយ ដើម្បីលេងល្បែងរហូតចាញ់ប្រាក់ម៉ឺនប្រាក់សែន លក់ផ្ទះសំបែង ដីធ្លី ពុំមែនបានសេចក្តីថាខ្លួនលេងអោយសប្បាយនោះទេ។ អ្នកលេងរបៀបនេះពិតជាគ្មានការពិចារណាអោយវែងឆ្ងាយសោះ ហើយជាពិសេសជាអ្នកមិនយល់ព្រះបំណងសម្តេចព្រះបិតាសោះ ។

ហេតុនេះនាទីសុជីវធម៌របស់យើង សូមអំពាវនាវអោយមិត្តអ្នកអានទាំងឡាយ ត្រិះរិះពិចារណាកុំបណ្តោយវាសនាលើល្បែងនោះអោយសោះ ។

❁ ❁ ❁ ❁



Facebook : Entertainment And Knowledge

# ទំលាប់គួរបោះបង់ចោល

គេសង្កេតឃើញ ឪពុកម្ដាយខ្លះស្រឡាញ់កូនជ្រុលពេកទំលាប់និយាយសែតព្រៃជាមួយកូនអោយកូនហ៊ានតមាត់ តាំងពីតូចអោយកូនហៅអាឪ អាកញ្ឆាស់ មីម៉ែ-មីកញ្ឆាស់...។

បង្រៀនកូនអោយជេរបញ្ចោរគេ តាំងពីចេះនិយាយមួយម៉ាត់ដំបូងតរៀបមក។ នៅពេលកូនចេះជេរបញ្ចោរពាក្យអាសអាភាស ឪពុកម្ដាយសប្បាយចិត្តណាស់ សប្បាយក្អាកក្អាយរកអ្វីផ្ទឹមគ្មាន នៅពេលវាធំឡើងវាក៏នៅចាំពាក្យជេរបញ្ចោរនោះដដែលនៅពេលហាមវាអោយឈប់ជេរ រឺក៏នៅពេលខឹងនឹងវាជេរខ្លួន ឪពុកម្ដាយក៏រត់ដេញវាយកូន ហាក់ដូចជាទើបនឹងមានអាយុស្របាលនឹងកូន។ ឪពុកម្ដាយខ្លះអួតប្រាប់អ្នកដទៃថាកូនខ្លួនកាចណាស់ ព្រហើនណាស់ មិនចេះខ្លាចខ្ញុំទេ កូនខ្ញុំរឹងទទឹងណាស់ មិនយូរប៉ុន្មានក្មេងនោះវាយល់និស្ស័យឪពុកម្ដាយវា វានឹងធ្វើដូចពាក្យពោលខាងលើនេះពុំខាន។ មានជីដូនជីតាខ្លះស្រឡាញ់ចៅខ្លាំងពេករហូតដល់មិនហ៊ានធ្វើអោយឃ្មើសចិត្តចៅ បន្តិចបន្តួចសោះឡើយសូម្បីចៅទារខោកក្បាល រឺផុះនោមប្រាសក៏ស៊ូទ្រាំអោយចៅពេញចិត្តដែរ អ្នកខ្លះទៀតធ្វើជាដំរី សេះអោយចៅជិះពីលើខ្នង រឺលើស្មាដោយអោយទាំងរំពាត់ទៅវាសំរាប់វាយទៀតផង ការស្រឡាញ់ក្មេងរបៀបនេះនាំអោយកើតការឆ្ងាំឆ្ងងខ្លាំងណាស់ ពីប្រភពអ្នករស់នៅជិតខាង។ ការស្រឡាញ់កូនចៅជាការគួរអោយសរសើរហើយ តែការដែលធ្វើអោយកូនចៅមានទំលាប់ខូច-អាក្រក់ជាការធ្វើអោយអ្នកផងគេមើលងាយទៅវិញ។

តាមធម្មតាគេតែងស្ងើចសរសើរដល់មាតាបិតា រឺជីដូនជីតាដែលស្រឡាញ់កូន-ចៅមិនអោយក្មេងនេះដឹងចិត្តរហូតដល់ក្លាយទៅជាព្រហើន។

# សុជីវធម៌នៅ

យើងជាអ្នកថ្លៃថ្នូរ គួរប្រកាន់អាកប្បកិរិយាជាអ្នកថ្លៃថ្នូរចំពោះអ្នកផងទាំងឡាយ កុំជ្រលើមហួសបទ មើលគេមើលឯងដែលមានជីវិតរស់នៅជុំវិញខ្លួន ។ កុំលាយដំណើប រឺលាយខ្សាយតែយើងជាក្មេងមិនគួរបំប៉នភាពភ្លឺបភ្លែតរលើមរលោមដោយខំវាយស្របតតអៀនខ្មាស ទៅតាមដំណើរអភិវឌ្ឍន៍របស់វិទ្យាសាស្រ្តទេព្រោះភាពសប្បាយ មិនមែនស្ថិតនៅលើឫកពាររបៀបរអិលលើខ្លាញ់ទាំងនេះទេ សភាពអស់នេះទេតើដែលធ្វើអោយគេនិយាយថាសប្បាយជាគូនឹងទុក។ សប្បាយដោយរបៀបសមរម្យ ថ្លៃថ្នូរ ជាសប្បាយដែលផ្ទុយគ្នានឹងទុក្ខ ។

នៅពេលដែលយើងឃើញគេរងទុក្ខ ដោយរអិលដួលគ្រេចដៃ ជើង ចុកទល់ផ្អក រឺរបួសដោយប្រការណាមួយ យើងមិនគួរចូលទៅគួរសមដោយបញ្ចេញវាចាថា "ម៉េចស្រួលខ្លួនទេ? ល្មមគ្រប់គ្រាន់ទេ?" ។ល។ នោះសោះឡើយ ។

យើងមិនត្រូវហៅអ្នកក្រ រឺអ្នកធ្វើខុសចិត្តរបស់យើងដោយប្រការណាមួយថា អាសំរេ មីសំរេ អាកុងត្រូវលីដងន័ង្គលនោះសោះឡើយ ព្រោះអ្នកស្រែអ្នកម្ចាស់ចងន័ង្គលទាំងនោះជាអ្នកប្រកបដោយឧត្តមគតិជាងយើង ជាអ្នកនិយាយច្រើនណាស់ខាងការរកភោជន៍ផលមកចិញ្ចឹមយើងរាល់រូប។ យើងមិនត្រូវស្ទាបហាវមាត់ច្រហរ ហើយបញ្ចេញស័ព្ទដូចខ្មោចចូលទេគេត្រូវយកដៃបិទមាត់ ហើយស្ទាប់តាមការគួរល្មម។ កុំធ្វើអោយអ្នកជិតខាងយល់ថាខ្លួនខ្ជិល រឺមិនចង់រស់នោះអោយសោះ ។

គេមិនត្រូវឈរអេះអាចម៍ច្រមុះរបៀបព្រងើយ ដោយមិនខ្វីអើពើចំពោះភ្នែកមហាជនដែលអាចសំឡឹងមកប៉ះទេ។ គេត្រូវយកកូនកន្សែងមកជូតត្បារដោយលាក់បំពួន។

គេមិនត្រូវហិះសំបោរ រហូតដល់ធ្វើអោយអ្នកជិតខាងខ្ញាត់ភ្លាត់ព្រលឹងទេ

www.facebook.com/7khmer


គឺទៅអោយឆ្ងាយពិគេឯង រឺធ្វើតាមសំរួលគួរសម។ នៅក្នុងទីប្រជុំទល់មុខគ្នាក្តី ប្រជុំអ្វីមួយក្តី គេមិនត្រូវជោមទំលាយខ្យល់សំអុយ អោយអង្គប្រជុំក្តៅក្រហាយចំពោះខ្លួនម្នាក់នោះទេគេត្រូវដើរចេញទៅឆ្ងាយដើម្បីទំលាយខ្យល់មិនស្រួលនេះ។ នៅពេលដែលធំក្លិនខ្យល់អាក្រក់នេះ គេមិនត្រូវសួររកមុខអ្នកជោមដើម្បីធ្វើអោយគ្នាខ្មាស់គេកណ្តាលទីជំនុំនោះទេ។

ប្រសិនបើមានអ្នកខ្វះសុជីវធម៌នេះសួររកអ្នកជោម អ្នកជោមខ្លួនឯងមិនគប្បីឆ្លើយដាក់គេឯង រកដោះខ្លួន រឺឆ្លើយដាក់ក្មេងនៅក្បែរនោះទេ ។

នៅពេលបែកញើស គេមិនត្រូវឈរ រឺអង្គុយខ្វេះអាចម៍ក្អៀកមកហិតដោយអាកប្បកិរិយាព្រងើយ បង្ហាញអ្នកជិតខាងអោយខ្ពើមរអើមនោះទេ។

គេមិនត្រូវដើរសើយលាត់សំពត់ រឺម្ងូរជើងខោងទាំងសងខាងនៅតាមផ្លូវសាធារណៈទេ ។

គេមិនត្រូវអង្គុយបែរខ្នង ដាក់មនុស្សដែលអង្គុយជិតនោះទេ។ គេមិនត្រូវធ្វើមុខក្រញូវស្មើកាប់បីពូថៅមិនចេញជ័រនោះទេ។ គេមិនត្រូវឈ្លោះគ្នាវាយតប់ ជេរគ្នា រឺកចៃប្រវាស់គ្នានៅតាមទីផ្សារទេ។ នៅទីណាចង្អៀតដូចជាទីផ្សារ កន្លែងទិញសំបុត្រកុនល្ខោន សំបុត្រមើលកីឡាផ្សេងៗជាដើម គេមិនត្រូវដើរបញ្ចេញគួយដៃបុកគេឯងពាសវាលសោះឡើយ ។

នៅពេលឃើញគេខុស យើងមិនត្រូវហៅគេថា អាឆ្កួតនោះទេ។ នៅពេលឃើញគេយំចេញទឹកភ្នែក រឺមុខស្លូតដោយប្រការណាមួយ អ្នកថ្លៃថ្នូរគេមិនទៅញញឹមញ៉ែម លឺបលរ រឺទៅគួរសមរបៀបច្រលើមដាក់គេទេ។

នៅបណ្ណាល័យនីមួយៗ រឺនៅទីណាដែលមានដាក់សៀវភៅ គេមិនត្រូវយកចង្អុលដៃលិទ្ធទឹកមាត់ដើម្បីបើកមើលនោះទេនៅបណ្ណាល័យគេមិន ឡូឡាធ្វើអោយធ្លាក់បន្ទាត់ សៀវភៅ ធ្លាក់នេះនោះអោយរំខានដល់អ្នកជិតខាងទេ។

បុរសអ្នកជិះស៊ីក្លូមិនត្រូវដេកលើស៊ីក្លូ សន្ធឹងស្តូកដូចបាត់ព្រលឹងអស់នោះទេ ។ នារីអ្នកជិះស៊ីក្លូមិនត្រូវអង្គុយកន្ធែកឥតខ្មាសទេ។ បើខ្ចីសៀវភៅគេត្រូវប្រញាប់យកមកសងគេវិញកុំទុកចាំគេសួររកអោយសោះ។ ពេលយកសៀវភៅគេទៅមើលត្រូវចេះថែរក្សាកុំបត់អោយបាក់ផ្នត់ចាស់របស់គេ កុំលួចហែក


Facebook : Entertainment And Knowledge

www.facebook.com/7khmer


សន្លឹកណាដែលខ្លួនចូលចិត្ត ។

ឃើញគេអាចសៀវភៅ រឺកាសែតយើងមិនត្រូវចូលទៅឆាឆៅគេ ដោយសួរពត៌មានកំទេចកំទីឡើយ បើរឿងនោះត្រូវនិយាយដោយខានមិនបាន ត្រូវសុំទោសគេជាមុនសិន។

បើគេខ្ចីសៀវភៅយើងមិនព្រមសង កំឡុង ៦ខែមកទៀតយើងអាចទៅសាកសួរគេបាន ដោយនិយាយប្រាប់មកថាមាននរណាម្នាក់ទៀតត្រូវការខ្ចីយើងដែរ ។

# ចប់

❁ ❁ ❁ ❁


Facebook : Entertainment And Knowledge